# មហាជនកជាតក



កាលព្រះមហាជនក លិចសំពៅហែលប្រាំពីរយប់ប្រាំពីរថ្ងៃ
ទើបទេវតាឈ្មោះមណីមេខលា មកជួយយកចេញពីមហាសាគរ


ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ

**កុល ផេង**



**ព.ស. ២៥៦៣**

**មហាជនកជាតកពិស្តារ**

**អធិបតីក្នុងការរៀបរៀង**
**បណ្ឌិត កុល ផេង**
*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*
*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*
*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**អ្នកបកប្រែពីអដ្ឋកថាភាសាបាលី**
*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**ក្រុមជំនុំពិនិត្យ**

*បណ្ឌិត* **កុល ផេង** *ប្រធាន*

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **ទ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*លោកគ្រូ* **លឹម លឿម**

*លោកគ្រូ* **ដុង សុភឿន**

*លោកគ្រូ* **ទិព្វ សៅ**

*លោកគ្រូ* **សំណាង សំណាក់**

*លោកគ្រូ* **ស៊ន់ គឹមឈន់**

*លោកគ្រូ* **ប៉ាល់ ចំរើន**

*លោកគ្រូ* **ហ៊ុន  ពិសេស**

*លោក* **ហាន សុខេមនុ** *លេខាធិការ*

**ក្រុមបច្ចេកទេស និងរចនា**

*លោក* **អ៊ិន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **ឈុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

*លោក* **ផុន សុគង់** *សមាជិក*

*លោក* **ម៉ម ម៉ានិត** *សមាជិក*

**រចនាសម្ពន្ធពុទ្ធិកបណ្ឌិតសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**ក្រុមប្រឹក្សាភិបាល និងស្ថាបនិក**

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ សាមឿន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សាវេន** *សមាជិក*

*សាស្ត្រាចារ្យ* **ជិត ជន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា គ្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុង សុវណ្ណា** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **កុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គួ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោកគ្រូ* **ហ៊ាត ណាហាំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមន្ទ** *សមាជិកគណៈកម្មការបច្ចេកទេស*

## **ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍**

*បណ្ឌិត* **កុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## **ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី**

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហំ** *សមាជិក*

*លោកគ្រូ* **ចាន់ ហួរ** *សមាជិក*

*លោកគ្រូ* **ហួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## **ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌**

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **សំណាង សំណាក់** *សមាជិក*

*លោក* **ដុង សុភឿន** *សមាជិក*

*លោក* **រស់ សិរីវណ្ណាត** *សមាជិក*

# បុព្វកថា

*មហាជនកជាតក ជាដំណើររឿងតំណាលពីបុព្វជាតិរបស់ព្រះសម្មា-សម្ពុទ្ធបរមគ្រូ កាលដែលព្រះអង្គយោនយកកំណើតជាព្រះមហាជនក មានសេចក្ដីព្យាយាមមោះមុត ហែលឆ្លងមហាសមុទ្រ ៧ យប់ ៧ ថ្ងៃ និងក្រោយមក បានសោយរាជ្យ ហើយលះបង់រាជ្យទៅ សាងផ្នួសជាតាបស ដោយពុំអាឡោះអាល័យព្រះអគ្គមហេសី ស្រីសុំ ដែលដើរតាមយំសោកស្ដាយស្រណោះ ព្រោះពុំបានឃើញព្រះភក្ត្រថ្ងៃនោះឡើយ ។ រឿងជាតកនេះ ពុទ្ធ-សាសនិកខ្មែរយើងដែលចូលចិត្តស្ដាប់ធម្មកថារបស់ធម្មកថិក សឹងតែបានជ្រាបគ្រប់ ៗ គ្នា ព្រោះលោកគ្រូធម្មាចារ្យ តែងសម្ដែងរឿងនេះទាក់ទងទៅនឹងការបំពេញសេចក្ដីព្យាយាម ។ រីឯសិស្សសាលាកម្រិតមធ្យម របស់ក្រសួងអប់រំយុវជន និងកីឡា ក៏បានយល់ដឹងរឿងមហាជនកនេះ ទៅតាមសៀវភៅទសជាតកសង្ខេប ដែលរៀបរៀងដោយបណ្ឌិត ឈឹម ស៊ុម ក្នុងព.ស. ២៥០២, គ.ស.១៩៥៩ ។*

*ពុទ្ធិកបណ្ឌិតសភា បានសម្រេចចិត្តបកប្រែរឿងព្រះមហាជនកជាតកពិស្ដារនេះពីអដ្ឋកថាភាសាបាលីជាថ្មីម្ដងទៀត ដោយប្រើពាក្យតាមវចនានុ-ក្រមខ្មែររបស់សម្ដេចព្រះមហាសុមេធាធិបតី* ***ជួន-ណាត ជោតញ្ញាណោ*** *។ វិធីសាស្ត្រក្នុងការបកប្រែ ពុំបានលើកយកមេពាក្យបាលីក្នុងគាថាមកដាក់ហើយទើបប្រែពន្យល់នោះទេ គឺប្រែយកសេចក្ដីទាំងក្នុងបាលីគាថាទាំងក្នុងសេចក្ដីអធិប្បាយនៃអដ្ឋកថាឲ្យចេញជាភាសាខ្មែរល្មមស្ដាប់បានតែម្ដង ។*

*គោលបំណងនៃការបកប្រែរៀបរៀងព្រះមហាជនកពិស្ដារនេះ គឺដើម្បី*

១- ជាជំនួយក្នុងកម្មវិធីអប់រំជាតិកម្រិតមធ្យមនិងឧត្តមសិក្សា
២- ជាឯកសារសិក្សាស្រាវជ្រាវសម្រាប់ពុទ្ធសាសនិកជនទូទៅ
៣- ជាការអភិវឌ្ឍផ្សព្វផ្សាយអក្សរសាស្ត្រ វប្បធម៌ និងអរិយធម៌ខ្មែរ
៤- ជាកេរមរតកតម្កល់ទុកសម្រាប់កុលបុត្រកុលធីតាជំនាន់ក្រោយ
៥- ជាការផ្សព្វផ្សាយព្រះពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យរីតតែបានទូលំទូលាយ ។

ព្រះមហាជនកពិស្តារនេះ ទោះបីក្រុមជំនុំបានត្រួតពិនិត្យលើខ្លឹមសារន័យសេចក្តី អក្ខរៈ ឃ្លាល្បះ ដោយយកចិត្តទុកដាក់និងប្រុងប្រយត្នបំផុតក៏ដោយ ក៏គង់នៅសល់សេចក្តីខុសឆ្គងខ្លះជាក់ជាពុំខាន ។ យើងខ្ញុំ សូមអភ័យទោសអំពីសម្នាក់លោកអ្នកប្រាជ្ញ កវីបណ្ឌិត ព្រឹទ្ធាចារ្យ និងលោកអ្នកអានជាទីគោរពទាំងអស់ ដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់ ។ ត្រង់ចំណុចនេះ យើងខ្ញុំបាននឹកឃើញនូវចំណាររបស់សម្តេចព្រះមហាសុមេធាធិបតី **ជួន-ណាត ជោតញ្ញាណោ** មួយប្រយោគថា ៖

**"ធម្មតា ការធ្វើអ្វីទាំងអស់ក្នុងលោក តែងតែមានភ្លាំងភ្លាត់ខ្លះ បើមិនច្រើនក៏តិចតួចពុំខាន នេះជាទម្លាប់នៃការធ្វើរបស់បុថុជ្ជន ព្រោះត្រូវជាគួគ្នានឹងខុស ប៉ុន្តែបើមានត្រូវច្រើន មានខុសតែបន្តិចបន្តួច ក៏គង់អាចប្រើការកើត គ្រាន់បើជាងគ្មានសោះទៅដែរ"** ។

ជាទីអវសាននៃបុព្វកថានេះ ដោយអានុភាពនៃកុសលដែលកើតពីការខិតខំប្រឹងប្រែងឲ្យបានចេញជាស្នាដៃដ៏ប្រពៃនេះ យើងខ្ញុំទាំងអស់គ្នាសូមឧទ្ទិសនូវឥដ្ឋមនុញ្ញផល ជូនចំពោះបុព្វបុរសខ្មែរ មាតាបិតា ជីដូនជីតា

បងប្អូន និងញាតិសាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ត ទាំងអតីតៈ បច្ចុប្បន្ន និងអនាគត សូមឲ្យមានសុខភាពល្អអាយុយឺនយូរ កម្លាំងកាយមាំមួន ប្រាជ្ញាវាងវៃ កុំបីមានជំងឺតម្កាត់អ្វីតិចតួច មកបៀតបៀនយាយីធ្វើទុក្ខបុកម្នេញឲ្យដល់សេចក្តីលំបាកតិចតួចឡើយ និងសូមបានជាឧបនិស្ស័យកំពូល គឺការរួចផុតចាកវដ្តទុក្ខដល់នូវបរមសុខ ពោលគឺព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញថ្ងៃទី ១ ខែកុម្ភៈ ព.ស. ២៥៥៧ / គ.ស. ២០១៤

កុល ផេង

ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

# មាតិកា

## ជំពូកទី ១

### កំណើតព្រះមហាជនក


និទានខាងដើម........................................................................ ១

សង្គ្រាមរវាងបងប្អូន.................................................................... ២

មហេសីភៀសខ្លួន........................................................................ ៦

សក្កទេវរាជដឹកព្រះអគ្គមហេសីទៅចម្ប៉ានគរ............................. ៨

អាចារ្យទិសាបាមោក្ខសង្គ្រោះម្តាយពោធិសត្វ…………………..១១

មហាជនកកុមារ…………………………………………………..១៥


## ជំពូកទី ២

### សេចក្តីព្យាយាមរបស់មហាជនក


មហាជនកធ្វើជំនួញទៅសុវណ្ណភូមិ......................................... ១៨

មហាជនកធ្លាយសំពៅ…………………………………………..២១

សេចក្តីសន្ទនារវាងទេពធីតាមណីមេខលានិងមហាជនក……..២៣

បណ្តាំមរណៈរបស់ព្រះបាទបោលជនក ………………………..៣១

សីវលីទេវីជាក់សេនាបតី …………………………………………៣៥

ពិធីផ្សងបុស្សរថ …………………………………………………៣៨

បុស្សរថចូលទៅរកមហាជនក ……………………………………..៤១

## ជំពូកទី ៣

### មហាជនកឡើងគ្រងរាជ្យនៅក្រុងមិថិលា


ពិធីអភិសេកព្រះមហាជនករាជា...................................... ៤៤

សីវលីទេវីសាកល្បងស្ដេចមហាជនក..................................៤៧

ព្រះបាទមហាជនកបង្ហាញសមត្ថភាពសោយរាជ្យ .................៥០

ព្រះបាទមហាជនកដោះប្រស្នាមហាកំណប់ ១៦ ..................៥៤

មហាកំណប់ទី ១ ..........................................................៥៤

មហាកំណប់ទី ២ ..........................................................៥៦

មហាកំណប់ទី ៣ .......................................................... ៥៧

មហាកំណប់ទី ៤ ..........................................................៥៧

មហាកំណប់ទី ៥ ..........................................................៥៧

មហាកំណប់ទី ៦ ..........................................................៥៧

មហាកំណប់ទី ៧ ..........................................................៥៨

មហាកំណប់ទី ៨-៩-១០-១១ ............................................៥៨

មហាកំណប់ទី ១២ ........................................................៥៨

មហាកំណប់ទី ១៣ ........................................................៥៩

មហាកំណប់ទី ១៤ ........................................................៥៩

មហាកំណប់ទី ១៥ ........................................................៥៩

មហាកំណប់ទី ១៦ ........................................................៥៩

## ជំពូកទី ៤


### ព្រះបាទមហាជនកលះបង់រាជ្យសាងផ្នួស

ដើមស្វាយពីរដើម ........................................................................៦៨

ស្តេចមហាជនកធ្វើសមណធម៌នៅលើប្រាសាទ......................៧០

ស្តេចមហាជនកយាងចេញសាងផ្នួស.................................៩៣


## ជំពូកទី ៥


### ចេតិយអនុស្សាវរីយ៍

សីវលីទេវីរត់តាមតាបសមហាជនក ....................................៩៦

សីវលីទេវីក្លែងធ្វើភ្លើងឆេះវាំង...........................................៩៩

សីវលីទេវីក្លែងធ្វើចោរប្លន់អ្នកស្រុក.......................................១០២

សីវលីទេវីយំបម្រះនឿល..................................................១០៤

មហាជនកជួបនារទតាបស ..............................................១០៦

មហាជនកជួបមិគាជិនតាបស...........................................១១១

សាច់សំណល់សុនខ........................................................១១៥

ស្នូរកងដៃទង្គិចគ្នា .......................................................... ១១៩

ដំបូន្មានដាងព្រួញ ........................................................... ១២២

ដំណាច់នៃស្មៅយាប្លង ......................................................១២៤

សីវលីទេវីសាងចេតិយអនុស្សាវរីយ៍ ....................................១២៦

ព្រះសាស្តាប្រជុំជាតក .....................................................១២៨

# ជំពូកទី ១

## កំណើតព្រះមហាជនក

### និទានខាងដើម

*កាលព្រះសាស្ដាគង់នៅក្នុងអារាមជេតពន ទ្រង់ប្រារព្ធមហាភិនេស្ក្រមណ៍[១] របស់ព្រះអង្គ ហើយបានសម្ដែងនូវធម្មទេសនាផ្ដើមដោយពាក្យជាអាទិ៍ថា "**កោយំ មជ្ឈេ សមុទ្ទស្មឹ**" ។*

*មានរឿងតំណាលថា ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយជួបជុំគ្នាក្នុងធម្មសភា[២] ពណ៌នាសរសើរនូវមហាភិនេស្ក្រមណ៍របស់ព្រះតថាគត[៣] ។*

---

*[១] ការចេញស្វែងរកគុណដ៏ធំក្រៃលែង ដើម្បីស្រោចស្រង់សត្វលោក គឺការចេញទ្រង់ព្រះផ្នួសរបស់ព្រះមហាសត្វក្នុងបច្ឆិមភព (ការចេញបួសធ្វើទុក្ករកិរិយាឲ្យបានត្រាស់ជាព្រះពុទ្ធ) ។*

*[២] សាលាជាទីនិយាយធម៌, សាលាសម្រាប់ប្រជុំប្រឹក្សាអំពីធម៌ គឺកន្លែងប្រជុំធម៌ កន្លែងសម្ដែងនិងស្ដាប់ធម៌; សាលាយុត្តិធម៌; សាលាជំនុំក្ដី ។ តាមសេចក្ដីតំណាលដែលមាននៅក្នុងគម្ពីរផ្សេង ៗ មានអដ្ឋកថាជាដើមថា សូម្បីនៅឋានទេវតាក៏មានធម្មសភាដែរ សម្រាប់ពួកទេវតាប្រជុំប្រឹក្សាធម៌ ។ ក្នុងរឿងសក្កទេវរាជ នៃគម្ពីរអដ្ឋកថាធម្មបទ បានចែងថា ក្នុងថ្ងៃទី៨ នៃខែ តែងមានការសម្ដែងនិងស្ដាប់ធម៌នៅក្នុងសុធម្មាទេវសភានោះ ។*

*[៣] ព្រះនាមវិសេសនៃព្រះសព្វញ្ញុពុទ្ធគ្រប់ព្រះអង្គៈ ព្រះតថាគត, ព្រះតថាគតទាំងឡាយ ។ល។ ប្រើជាបុរិសសព្វនាមផ្ទាល់ព្រះអង្គ ជាជំនួសពាក្យថា " ខ្ញុំ, អញ" ក៏បានៈ ម្នាលភិក្ខុទាំងឡាយ អញតថាគតនឹងសម្ដែងធម៌ដល់អ្នករាល់គ្នា ។*

ព្រះសាស្តាបរមគ្រូស្តេចយាងមក ទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ អ្នកទាំងឡាយប្រជុំគ្នានិយាយពីរឿងអ្វី ?" ។ កាលបើភិក្ខុទាំងឡាយក្រាបទូលរឿងនោះហើយ ព្រះអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនត្រឹមតែឥឡូវនេះទេ, សូម្បីពីអតីតជាតិ ក៏តថាគតធ្លាប់ចេញសាងមហាភិនេស្រ្កមណ៍ដូច្នេះដែរ" ។ បន្ទាប់ពីភិក្ខុទាំងឡាយ ក្រាបទូលអារាធនា[៤] ព្រះសាស្តាទ្រង់នាំអតីតនិទាន[៥] មកតំណាលឲ្យស្តាប់ដូចតទៅនេះ ៖

## សង្គ្រាមរវាងបងប្អូន

ក្នុងកាលកន្លងយូរលង់មកហើយ មានព្រះរាជាមួយអង្គព្រះនាមថា **មហាជនក** ទ្រង់សោយរាជសម្បត្តិនៅក្រុងមិថិលា ដែនវិទេហរដ្ឋ ។ ស្តេចអង្គនោះ មានព្រះរាជបុត្រពីរអង្គ គឺមួយនាមថា **អរិដ្ឋជនក** មួយទៀតនាមថា **បោលជនក** ។ ចំណេរកាលតមក ស្តេចមហាជនកទ្រង់សោយទិវង្គត[៦] ។ ព្រះរាជសពត្រូវបានព្រះរាជវង្សានុវង្ស[៧] និងពួក

---

[៤] និមន្តឬអញ្ជើញដោយក្តីគោរព ឲ្យសូត្រឬសម្តែងធម៌ ឲ្យនិយាយអធិប្បាយជាដើម ។ ពាក្យនេះ សម្រាប់គ្រហស្ថនិយាយទៅរកបព្វជិត ឬបព្វជិតនិយាយទៅរកបព្វជិត ។

[៥] រឿងតំណាលពីអតីតកាល ។

[៦] ទៅកាន់ទេវលោកហើយ (ស្លាប់), ដែលទៅកើតជាទេវតាហើយ ។ ខ្មែរយើងប្រើជារាជសព្ទ : ទ្រង់សោយព្រះទិវង្គតហើយ ។

នាហ្មឺន[៨]សព្វមុខមន្ត្រីចាត់ចែងពិធីថ្វាយព្រះភ្លើងបូជាធ្វើបុណ្យតាមព្រះរាជបវេណីក្នុងនគរ ។ លុះអំណើះ[៩]តតពីព្រះបាទមហាជនកអង្គនោះទៅ រាជបុត្រច្បងនាមថា អរិដ្ឋជនក ឡើងគ្រងរាជ្យជាព្រះមហាក្សត្រស្នងព្រះបិតា ហើយទ្រង់ប្រទានឋានៈដល់ព្រះអនុជបោលជនកជាព្រះឧបរាជ[១០] ។ ស្ដេចអង្គនោះមានអាមាត្យម្នាក់ពូកែខាងអែបអប គាត់ចូលទៅគាល់ព្រះមហាក្សត្រហើយក្រាបទូលញុះញង់ថា "បពិត្រព្រះ

---

[៧] វង្សស្ដេចឬវង្សដែលជាប់ក្រសែស្ដេច តែយារឬឃ្លាតក្លាយហើយ ។

[៨] មន្ត្រីមានបណ្ដាសក្តិ ១០ ហ៊ូពាន់ គឺសក្តិមួយម៉ឺន; ពាក្យនេះជាប់មកពីសម្ដីសៀមថា ន៉ាហ្មឺន "ស្រែមួយម៉ឺន", ន៉ាសែន "ស្រែមួយសែន"; បណ្ដាសក្តិមន្ត្រីធំក្នុងសម័យព្រេងនាយយូរមកហើយ ដែលមានមុខងារត្រូវស្ដីត្រួតត្រា ឬត្រូវបានស្រែមួយហ្មឺន, មួយសែន ជាមុខអាការ; ព្រោះហេតុនោះ ទើបមានពាក្យនិយាយថា នាហ្មឺននាសែន ឬ ន៉ាហ្មឺនន៉ាសែន ជាប់មកដល់សព្វថ្ងៃ : ធ្វើជានាហ្មឺន ។ ព. ផ្ទ. រាស្ត្រ ។

[៩] តមក ឬតទៅ, ចំណោរកាលតមក ឬចំណោរកាលតទៅ ឧ. ម្នាលអានន្ទ, អំណើះតតពីអញតថាគតទៅ ធម៌និងវិន័យជាសាស្ដារបស់អ្នកទាំងឡាយ ជាតំណាងអញតថាគត (ពុទ្ធបណ្ដាំ) ។

[១០] ព្រះរាជាបន្ទាប់ គឺក្សត្រិយ៍ដែលមានរាជសក្តិរងបន្ទាប់ក្សត្រិយ៍ទ្រង់រាជ្យ : សម្ដេចព្រះឧបរាជ ឬសម្ដេចព្រះមហាឧបរាជ (តាមបវេណីក្នុងកម្ពុជរដ្ឋ, នាទីរបស់សម្ដេចព្រះមហាឧបរាជជាឋានៈសម្រាប់ត្រី ទាំងមន្ត្រីធំតូចសម្រាប់ព្រះអង្គ ក៏តាំងក្នុងឋានៈសម្រាប់ត្រីដែរ ។

សម្មតិទេព[១១] ព្រះឧបរាជមានបំណងធ្វើឃាតព្រះអង្គ" ។ ព្រះរាជាហេតុតែត្រូវអាមាត្យនោះខ្សឹបដាក់ត្រចៀកញយ ៗ ពេក ព្រះអង្គបែរជាមានព្រះហឫទ័យ[១២]លែងស្រឡាញ់ទុកចិត្តចំពោះព្រះអនុជ ទ្រង់ចេញរាជបញ្ជាឲ្យកងសេនាទាហានទៅចាប់បោលជនកដាក់ខ្នោះបណ្ដើរយកមកដាក់ឃុំឃាំងក្នុងព្រះរាជដំណាក់មួយក្បែរព្រះរាជនិវេសន៍[១៣]របស់ព្រះរាជា ហើយចាត់វិធានការយាមល្បាតយ៉ាងតឹងរ៉ឹងបំផុត ។ ព្រះឧបរាជបោលជនក ធ្វើសច្ចាធិដ្ឋាន[១៤]ថា "ប្រសិនបើខ្ញុំមានគំនិតអាក្រក់ចង់ធ្វើឃាតចំពោះព្រះមហាក្សត្រជាបងមែន សូមឲ្យខ្នោះនិងច្រវាក់កុំរដោះចេញពីដៃជើងរបស់ខ្ញុំ, ទាំងទ្វារដំណាក់ឃុំឃាំងក៏កុំរបើកឲ្យសោះ ។ តែបើគ្មានវិញនោះ, សូមឲ្យខ្នោះនិងច្រវាក់របេះខ្ទាត់ខ្ទាយអំពីដៃខ្ញុំ ទាំងទ្វារក៏សូមឲ្យរបើកចំហចុះ" ។ រំពេចនោះឯង ស្រាប់តែខ្នោះច្រវាក់ដាច់ខ្ទាយជាកំណាត់ ៗ ទាំងទ្វារក៏របើកចំហឯង ។ ព្រះ

[១១] ទេព្ដាដោយសន្មតិ គឺមនុស្សដែលគេសន្មតទុកដូចជាទេវតារបស់មនុស្ស (ក្សត្រិយ៍ទ្រង់រាជ្យ) ឧ. បពិត្រព្រះសម្មតិទេព, សូមទ្រង់មានព្រះជន្មាយុយឺនយូរ ក្រៃលែងជាងរយវស្សា ! ។ សម្មតិទេពី ឬ --ទេវី ព្រះអគ្គមហេសីនៃក្សត្រិយ៍ ។

[១២] បេះដូង, ដួងចិត្ត, ចិត្ត; ទ្រូង ។ រាជសព្ទថា ព្រះហឫទ័យ ឬព្រះរាជហឫទ័យ ។

[១៣] លំនៅរបស់ព្រះរាជា (ព្រះរាជមន្ទីរ ឬព្រះរាជវាំង) ។

[១៤] ការតាំងចិត្តទៀងទាត់; ការតាំងប្រកាសពាក្យសច្ចៈ ធ្វើសច្ចាធិដ្ឋាន ប្រើជា សត្យាធិដ្ឋាន ក៏បាន ។

ឧបរាជបានរត់ចេញពីក្នុងដំណាក់ឃុំឃាំង ហើយធ្វើដំណើរទៅរហូតដល់ស្រុកចុងកាត់មាត់ញកមួយនៅឯជាយដែន[១៥] សម្រេចរស់នៅទីនោះតាមបែបប្រជារាស្ត្រសាមញ្ញ ។

អ្នកស្រុកជាយដែន ស្គាល់ព្រះឧបរាជ ក៏នាំគ្នាជួយផ្គត់ផ្គង់និងលាក់បាំងការពារ មិនឲ្យទាហានព្រះមហាក្សត្រចាប់បានឡើយ ។ ព្រះឧបរាជបានកៀងគរបញ្ចុះបញ្ចូលអ្នកស្រុកជនបទតាមជាយដែនឲ្យរួមកម្លាំងជាមួយនឹងខ្លួនជាលំដាប់រហូតដល់មានបរិវារ[១៦]ច្រើន ទៅណាមកណាមានអ្នកចោមរោមហែហម ជាហេតុឲ្យព្រះឧបរាជរលឹកឃើញថា "កាលដើមឡើយ ម្ចាស់បងចោទអញថា ក្បត់ព្រះអង្គ ទាំងដែលអញគ្មានគំនិតក្បត់ម្ចាស់បងបន្តិចទាល់តែសោះ ប៉ុន្តែឥឡូវនេះអញនឹងប្រកាសសង្គ្រាមជាមួយនឹងម្ចាស់បងវិញមើល" ដូច្នេះហើយព្រះឧបរាជមានមហាជនជាច្រើនចោមរោមជាបរិវារ ធ្វើដំណើរទៅកាន់ក្រុងមិថិលា បោះបន្ទាយស្នាក់នៅខាងក្រៅក្រុង ។ ពលទាហានរបស់ព្រះមហាក្សត្រអរិដ្ឋជនក ឮដំណឹងថាព្រះឧបរាជយាងមកដូច្នោះ ទាហានភាគច្រើននាំគ្នាយកដំរី សេះ ពាហនៈ ជាដើម មកចុះចូលនឹងព្រះឧបរាជ ។ មិនតែប៉ុណ្ណោះ សូម្បីពួកជនផ្សេង ៗ ទៀតក្នុង

---

[១៥] នៅក្បែរព្រំប្រទល់របស់ប្រទេស ។

[១៦] អ្នកចោមរោមកំដរ, អ្នកហែហមជាកិត្តិយស; អ្នកត្រៀមខ្លួនរង់ចាំបម្រើ, អ្នកបម្រើ ។

នគរមិថិលានោះ ក៏មករួបរួមនឹងព្រះឧបរាជដែរ ។ គ្រានោះ ព្រះឧបរាជបញ្ជូនសារលិខិតមួយច្បាប់ទៅថ្វាយព្រះរាជាជាបង ដែលមានសេចក្តីថា ៖

"កាលដើមឡើយ ទូលព្រះបង្គំជាខ្ញុំពុំដែលមានគំនិតអាក្រក់ចង់ក្បត់នឹងព្រះអង្គទេ ទើបតែឥឡូវនេះ ទូលព្រះបង្គំមានគំនិតចង់ដណ្តើមរាជ្យពីព្រះអង្គ តើព្រះអង្គយល់ព្រមប្រគល់រាជ្យដល់ទូលបង្គំទេ បើពុំព្រមទេ នឹងកើតសង្គ្រាមរវាងយើងទាំងពីរពុំខាន" ។

ព្រះមហាក្សត្រ ទ្រង់ជ្រាបសេចក្តីក្នុងសារលិខិតនោះហើយ មិនព្រមប្រគល់រាជ្យដល់បោលជនកដោយងាយ ៗ ទេ ព្រះអង្គបានសម្រេចព្រះទ័យធ្វើសង្គ្រាមវិញ ហើយបានផ្តាំព្រះអគ្គមហេសីថា "មហេសីអូនជម្ទាតា ការធ្វើសង្គ្រាម យើងមិនអាចដឹងជាមុនថា ជោគជ័យឬបរាជ័យទេ ដូច្នេះ ប្រសិនបើបងមានគ្រោះថ្នាក់អ្វីមួយក្នុងសមរភូមិ[១៧] មហេសីអូនគប្បីរក្សាបុត្រក្នុងផ្ទៃឲ្យបានគង់វង្ស" ។ ផ្តែផ្តាំរួចហើយ ស្តេចអរិដ្ឋជនករៀបក្បួនទ័ពជាពួកធំ ៗ ដើរហែជាក្បួនចេញអំពីព្រះនគរ ។

## មហេសីគៀសខ្លួន

គ្រានោះ ពួកទាហានរបស់ឧបរាជបោលជនក បានធ្វើឃាតព្រះ

---

[១៧] ទីបោះទ័ព, ទីចម្បាំង ។

បាទអរិដ្ឋជនកឲ្យសោយព្រះទិវង្គតក្នុងសមរភូមិ ។ ការសោយព្រះទិវង្គតរបស់ព្រះបាទអរិដ្ឋជនកនោះ បានបង្កើតឲ្យមានភាពច្របូលច្របល់ទូទាំងនគរថា "ព្រះរាជាសោយទិវង្គតហើយ ៗ" ។

រីឯព្រះអគ្គមហេសីរបស់ព្រះរាជាអរិដ្ឋជនក ដឹងថាព្រះស្វាមីខ្លួនអស់ព្រះជន្មហើយ បានប្រវេប្រវាយកវត្ថុមានតម្លៃមានមាស ជាដើមដាក់ក្នុងកញ្ជើ ស្នៀកពាក់សំពត់សៅហ្មង ជួតឈ្នួតកញ្ចាស់ ល្មមតែប្លែកចម្លែកដល់ភ្នែកអ្នកផងទាំងពួងមើលពុំស្គាល់ ។ ព្រះអគ្គមហេសីបានដាក់វត្ថុមានតម្លៃក្នុងកញ្ជើដោយចាក់អង្ករដាក់ពីលើ ហើយទូលយាងចេញពីព្រះរាជវាំងទាំងកណ្តាលថ្ងៃ គ្មាននរណាម្នាក់ស្គាល់ថាជាអគ្គមហេសីរបស់ព្រះរាជាឡើយ ។ ព្រះជាយាយាងចេញទៅតាមទ្វារខាងជើងនៃនគរ ហេតុតែជាក្សត្រីមិនធ្លាប់យាងទៅណាមកណា ម៉្លោះហើយ ព្រះជាយាមិនអាចនឹងកំណត់ទិសដៅថាត្រូវទៅទីណាបានទេព្រោះវង្វេងទិសអស់ ប៉ុន្តែព្រះជាយាធ្លាប់បានឮគេនិយាយថា "កាលចម្ប៉ានគរ[១៨]ៗ" ពីមុនមកដែរ ដូច្នេះហើយ ព្រះជាយាចេះតែយាងទៅបណ្តើរសួរគេឯងបណ្តើរថា "មានបងប្អូនណាធ្វើដំណើរទៅកាលចម្ប៉ានគរទេ" ដើរសួរគេរហូតទៅដល់សាលាមួយខ្នងនៅតាមផ្លូវហើយក៏ចូលទៅអង្គុយសម្រាកត្រមង់ត្រមោចម្នាក់ឯង ។ សូមបញ្ជាក់

[១៨] (ន.) (បា.),(សំ.) (ចំប៉ា) (ចម្បា) ឈ្មោះរាជធានីមួយរបស់ដែនអង្គៈ ក្នុងមជ្ឈិមប្រទេស (ឥណ្ឌា) ពីក្នុងបុរាណសម័យយូរហើយ ។

ថា បុត្រក្នុងផ្ទៃរបស់ព្រះអគ្គមហេសីអង្គនោះ គឺជាតួអង្គព្រះមហាសត្ត ដែលត្រូវជាព្រះសាស្តាបរមគ្រូនៃយើងនេះឯង កាលទ្រង់អន្ទោលវិលវល់ក្នុងវដ្តសង្សារ បំពេញនូវបារមីទាំងឡាយ ។

## សក្កទេវរាជដឹកព្រះអគ្គមហេសីទៅចម្ប៉ានគរ

ដោយអំណាចតេជះនៃព្រះមហាសត្ត[១៩] បណ្តាលឲ្យកពរបស់ស្តេចសក្កទេវរាជ[២០] កើតអាការរញ្ជួយស្ទើរក្រឡាប់ដួលរលំ ។ ព្រះអង្គរំពឹងមើលទៅទ្រង់ជ្រាបនូវព្រឹត្តិការណ៍នោះ ស្តេចទ្រង់ព្រះតម្រិះថា

"បុត្រដែលនៅក្នុងផ្ទៃនៃព្រះអគ្គមហេសីនោះ គឺជាអ្នកមានបុណ្យធំ, អញត្រូវតែទៅជួយ ទើបសម" ។

ទ្រង់ព្រះតម្រិះដូច្នេះហើយ ស្តេចសក្កទេវរាជបាននិម្មិត[២១]រទេះប្រក់ដំបូល មានគ្រែមួយខាងក្នុង ទ្រង់ប្រែកាឡាខ្លួនធ្វើជាមនុស្សចាស់បររទេះកាត់តាមទ្វារសាលា ដែលព្រះអគ្គមហេសីគង់ ទ្រង់ធ្វើជាឈប់ស្រែកអំពាវនាវថា ៖

"មានអ្នកដំណើរណា ត្រូវទៅកាលចម្ប៉ានគរឬទេ ?"

"មាន ៗ គឺខ្ញុំនេះឯងត្រូវទៅ លោក !" អគ្គមហេសីឆ្លើយតប ។

---

[១៩] នាមសម្រាប់ហៅនិយតពោធិសត្វ ដែលមិនទាន់ត្រាស់ដឹងជាព្រះពុទ្ធនៅឡើយ រាប់តាំងពីទទួលការព្យាករដំបូងពីព្រះពុទ្ធអង្គណាមួយមក ទើបហៅថា មហាសត្ត ។

[២០] ព្រះឥន្ទ្រាធិរាជ ។

[២១] បង្កើតដោយឫទ្ធិ, កាឡាខ្លួន, ដំណែងខ្លួន ។

"បើដូច្នោះ ចូរនាងឡើងមកអង្គុយក្នុងរទេះមក" សក្កទេវរាជមានបន្ទូល ។

"លោក ! ខ្ញុំមានគភ៌[២២] ជិតគ្រប់ខែ ខ្ញុំឡើងរទេះមិនរួចទេ ចាំខ្ញុំអង្គុយខាងក្រោយចុះ សូមលោកមេត្តាទុកកន្លែងទំនេរខាងក្រោយសម្រាប់ខ្ញុំផង" អគ្គមហេសីឆ្លើយ ។

"ថាម៉េចនាង ! ខ្ញុំជំនាញក្នុងការបររទេះណាស់ គ្មាននរណាដូចទេ, នៃនាងអើយ ! កុំខ្លាចអី, ឡើងអង្គុយលើរទេះមក" សក្កទេវរាជមានបន្ទូលតប ។

ព្រះអគ្គមហេសីយល់ព្រម ហើយព្រះនាងយាងតម្រង់មករទេះប្រុងលើកព្រះបាទឡើង រំពេចនោះស្រាប់តែផ្ទៃដីខាងក្រោយរទេះប៉ោងខ្ពស់ឡើង[២៣]ស្មើនឹងរទេះ ឲ្យព្រះនាងយាងឡើងយ៉ាងស្រួល ដោយសារតែអានុភាពរបស់សក្កទេវរាជ ។ លុះព្រះនាងឡើងជិះរទេះ ហើយទ្រង់ទម្រេតព្រះកាយសម្រាកសម្រាន្តលើស្រីសយនាដែលសក្កទេវរាជរៀបចំ ទ្រង់យល់ប្រាកដក្នុងព្រះទ័យថា "អ្នកបរនេះជាក់ជាទេវតា" ។

[២២] សត្វកើតក្នុងផ្ទៃ ។ ពាក្យសាមញ្ញថា មានផ្ទៃ, មានផ្ទៃពោះ, មានទម្ងន់ ជាដើម ។

[២៣] អដ្ឋកថាពន្យល់ថា អាការនៃដីដែលប៉ោងឡើងនោះ ដូចជាប៊ឺតប៉ោងដែលគេកំពុងផ្លុំខ្យល់បញ្ចូល ។

គ្រាន់តែបានផ្ទុំលើស្រីសយនាជាទិព្វមួយស្របក់ ព្រះនាងក៏និទ្រា[២៤] លង់លក់ទៅ ។

គ្រានោះ សក្កទេវរាជបររទេះអស់ចម្ងាយផ្លូវ ៣០ យោជន៍ ក៏ទៅដល់មាត់ស្ទឹងមួយ ទ្រង់តើនព្រះនាងឲ្យភ្ញាក់ ប្រាប់ថា ៖

"នៃនាង ! ចូរងូតទឹកឲ្យបានត្រជាក់កាយ, សម្លៀកបំពាក់មួយសម្រាប់នៅឯក្បាលដំណេក ងូតទឹកហើយ នាងយកស្លៀកពាក់ចុះ, បាយកញ្ចប់ក៏មាននៅខាងក្នុងរទេះនោះស្រាប់ដែរ, មើលយកបរិភោគទៅ" ។

ព្រះនាងបានស្រង់ទឹកសោយក្រយាហាររួច ទ្រង់ផ្ទុំលក់មួយសាទៀត ។ លុះដល់វេលារសៀល រទេះក៏ទៅដល់កាលចម្ប៉ានគរ ព្រះនាងតើនឡើងទតព្រះនេត្រទៅឃើញប៉មទ្វារនិងកំពែងនគរ ក៏ភ្ញាក់ខ្លួនព្រើតលាន់ព្រះឱស្ឋសួរអ្នកបររទេះថា ៖

"នុ៎ះ ជានគរអ្វី លោក ?"

"កាលចម្ប៉ានគរ នាង" សក្កៈឆ្លើយ ។

"មានប្រសាសន៍ថាម៉េច លោក, ក្រែងកាលចម្ប៉ានគរ នៅឆ្ងាយអំពីនគរយើងដល់ទៅ ៦០ យោជន៍មែនទេ ?" អគ្គមហេសីសួរ ។

"ពិតជាអ៊ីចឹងមែននាង, ប៉ុន្តែខ្ញុំស្គាល់ផ្លូវកាត់" សក្កៈឆ្លើយ ។

---

[២៤] (ន.) (សំ.),(បា.) (និត-ទ្រា) (និទ្ទា) ដំណើរដេកលក់ ។ ខ្មែរយើងប្រើជា កិ. ក៏មាន : កំពុងនិទ្រា គឺកំពុងដេកលក់; ច្រើនប្រើក្លាយជា និន្ទ្រា គួរកុំប្រើ ។

គ្រានោះ សក្កទេវរាជដាក់នាងចុះក្បែរទ្វារនគរខាងត្បូងប្រាប់ថា ៖

"នែនាង, ស្រុករបស់យើងនៅឯខាងមុខឯណោះ, នាងដើរចូលទៅខាងក្នុងនគរចុះ" ។

ប្រាប់ដូច្នេះហើយ សក្កទេវរាជបររទេះទៅខាងមុខបន្តិច ហើយក៏បំបាំងខ្លួនបាត់ពីទីនោះ វិលទៅកាន់លំនៅរបស់ព្រះអង្គនៅឋានតាវត្តិង្សវិញ ។

## អាចារ្យទិសាបាមោក្ខសង្គ្រោះម្ដាយពោធិសត្វ

ចំណែកព្រះទេវី[២៥] ទ្រង់មានខ្លួនតែមួយអង្គឯង ព្រះជាយាបានទៅសម្រាកក្នុងសាលាមួយខ្នង ។ ខណៈនោះ អាចារ្យទិសាបាមោក្ខ[២៦] ម្នាក់ ជាព្រាហ្មណ៍ស្វាធ្យាយមន្ត[២៧] រស់នៅក្នុងក្រុងកាលចម្ប៉ានគរនោះ

[២៥] (ន.) (សំ.),(បា.) ភរិយាធំរបស់ព្រះសម្មតិទេព គឺស្ត្រីជាភរិយានៃក្សត្រទ្រង់រាជ្យ ដែលស្ដេចបានអភិសេកតាំងពេញទីជាមហេសី ឬជាអគ្គមហេសី ។ ខ្លះប្រើជាទេពី ដោយផ្លាស់ ទេវី, វ > ព = ទេពី ។

[២៦] (ន.) (បា.) (ទិសាប៉ាម៉ោក) អាចារ្យជាប្រធានក្នុងទិស ឬអាចារ្យជាប្រធាននៃសិស្សគ្រប់ទិស គឺអាចារ្យធំដែលចេះវិជ្ជាច្រើនប្រភេទ សម្រាប់ប្រើតាមជាន់ តាមសម័យ, ជាអ្នកអាចបង្ហាត់បង្រៀនពួកសិស្សដែលកាត់មកពីគ្រប់ទិស (គ្រប់ប្រទេស) បានមិនទើសទាក់ : អាចារ្យទិសាបាមោក្ខ ។ រោងរៀនរបស់អាចារ្យធំនោះហៅថា សាលាទិសាបាមោក្ខ ឬរោងរៀនទិសាបាមោក្ខ ។

[២៧] ស្វាធ្យាយ គឺសូត្រឮបន្តិច ៗ ឬសូត្រខ្សឹប ៗ; ទន្ទេញ : ស្វាធ្យាយមន្ត, ស្វាធ្យាយបាលី គឺសូធ្យមន្ត, សូធ្យបាលី ។ មន្ត គឺពាក្យដែលចងក្រងជារបៀបសម្រាប់សូត្រ

ដែរ គាត់មានមាណព[២៨]ជាកូនសិស្ស ៥០០ នាក់ ដើរហែហមទៅរកងូតទឹក ក៏បានចោលភ្នែកអំពីចម្ងាយទៅ បានប្រទះឃើញនូវព្រះទេវីនោះដែលមានរូបឆោមលោមពណ៌ល្អ លើសនារីនានា កំពុងតែអង្គុយនៅក្នុងសាលានោះ ។ គ្រាន់តែបានឃើញព្រះជាយាភ្លាម គាត់កើតសេចក្ដីអាណិតស្រឡាញ់ដូចជាប្អូនស្រី នេះក៏ព្រោះតែអានុភាពនៃព្រះបរម-ពោធិសត្វនៅក្នុងព្រះឧទររបស់ព្រះជាយានោះឯង ។ គាត់ឃាត់មាណពទាំងអស់ឲ្យនៅចាំខាងក្រៅ ដើរចូលទៅតែម្នាក់ឯង រួចសួរថា ៖

"ប្អូនស្រី ! នាងនៅស្រុកណា ?"

"លោក ! នាងខ្ញុំជាអគ្គមហេសីរបស់ព្រះរាជាអរិដ្ឋជនក នៅក្រុងមិថិលា" ម្ដាយព្រះពោធិសត្វឆ្លើយ ។

"នាង ចុះហេតុដូចម្ដេចបានជានាងមកទីនេះ ?" អាចារ្យសួរ ។

"បពិត្រលោក ព្រះរាជាជាព្រះស្វាមីនាងខ្ញុំ ត្រូវប្អូនបង្កើតនាមបោលជនកធ្វើគត់ហើយ កាលបើដូច្នេះ នាងខ្ញុំមានសេចក្ដីភ័យខ្លាចខ្លាំងណាស់ មិនដឹងថានឹងទៅទីណាក៏មកទីនេះ ក្នុងគោលបំណងរក្សានូវបុត្រក្នុងផ្ទៃរបស់នាងខ្ញុំឲ្យបានល្អ" ម្ដាយព្រះពោធិសត្វឆ្លើយ ។

---

សែកស្ដោះផ្លុំ, អាគម; វេទ; ពាក្យសក្ដិសិទ្ធសម្រាប់សូត្រប្រសិទ្ធីឲ្យកើតសុខសួស្ដី... (ម. ព. ទិព្វមន្ត, ទឹកមន្ត, ពុទ្ធមន្ត ផង) ។

[២៨] ប្រុសកំលោះ ។

"នៃនាង ចុះនាងមានញាតិខ្លះទេ ក្នុងនគរនេះ?" អាចារ្យសួរ ។

"អត់មានទេ លោក" ម្តាយព្រះពោធិសត្វឆ្លើយ ។

អាចារ្យទិសាបាមោក្ខបង្គាប់ថា ៖

"បើអ៊ីចឹង កុំគិតអីនាង, ខ្ញុំជាឧទិច្ចព្រាហ្មណ៍មហាសាល ជាគ្រូធំបង្រៀនសិស្សមកពីគ្រប់ទិស, ខ្ញុំទុកនាងជាប្អូនស្រី ចាំខ្ញុំទំនុកបម្រុង, ចូរនាងហៅខ្ញុំថាបងប្រុស ៗ ចាប់ជើងខ្ញុំយំខ្សឹកខ្សួលទៅ" ។

ព្រះនាងទេវីក៏ចាប់ជើងរបស់អាចារ្យទិសាបាមោក្ខ ហើយយំខ្សឹកខ្សួលដោយសម្លេងខ្លាំង ៗ ។ អ្នកទាំងពីរនោះ យំខ្សឹកខ្សួលដាក់គ្នាទៅវិញទៅមក ។

គ្រានោះ អន្តេវាសិក[២៩] របស់អាចារ្យទិសាបាមោក្ខ ឮសំឡេងខ្លាំង ក៏នាំគ្នាស្ទុះរត់ចូលទៅយ៉ាងប្រញាប់ សួរថា ៖

---

[២៩] (ន.) (បា.),(សំ.) (អន្តេវាសិន៑ ឬ អន្តេវាសិន៑ "អ្នកច្រើនតែនៅក្នុងសម្នាក់ឬក្នុងទីជិតគ្រូ") សិស្ស, កូនសិស្ស (ប្រើជា អន្តេវាសិន ឬ អន្តេវាសិន ក៏បាន; សិស្សស្ត្រីជា អន្តេវាសិនី ឬ អន្តេវាសិនី) ។ អន្តេវាសិក (ដោយសង្ខេប) មាន ៥ ប្រភេទគឺ ១- បព្វជ្ជន្តេវាសិក សិស្សបំបួស (ឲ្យបានជាសាមណេរ); ២- ឧបសម្បទន្តេវាសិក សិស្សសូត្រ (ឲ្យបានជាភិក្ខុ); ៣- ឧទ្ទេសន្តេវាសិក សិស្សរៀនបាលី; ៤- និស្សយន្តេវាសិក សិស្សនិស្ស័យ (សិស្សសូមនិស្ស័យនៅអាស្រ័យផង); ៥- ធម្មន្តេវាសិក សិស្សរៀនធម៌អាថ៌ឬរៀនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេង ៗ (ហៅថា វិជ្ជន្តេវាសិក, សិប្បន្តេវាសិក ជាដើម តាមរូបសព្ទចំណេះដែលរៀនក៏បាន) ។ ម. ព. អន្តេ, សិស្ស និង អាចារ្យ ផង ។ អន្តេវាសី

"តើមានរឿងអ្វីកើតឡើង លោកគ្រូ ?"

អាចារ្យប្រាប់ថា ៖

"នេះជាប្អូនស្រីរបស់ខ្ញុំ, សម័យមួយនោះ យើងបានព្រាត់ប្រាសគ្នា" ។

គ្រានោះ អន្តេវាសិកទាំងឡាយជម្រាបលោកគ្រូថា ៖

"ពេលនេះ លោកគ្រូបានជួបនឹងប្អូនស្រីលោក សូមលោកកុំព្រួយបារម្ភអ្វី" ។

អាចារ្យទិសាបាមោក្ខ បានប្រើពួកមាណពឲ្យយករទេះដំបូលដឹកព្រះអគ្គមហេសីទៅផ្ទះ ដោយផ្តាំថា ៖

"ក្មួយ ៗ អើយ ទៅដល់ផ្ទះខ្ញុំហើយ ប្រាប់ព្រាហ្មណីប្រពន្ធខ្ញុំថា ស្រ្តីនេះជាប្អូនស្រីពៅរបស់ខ្ញុំ ហើយឲ្យ ប្រពន្ធខ្ញុំជួយរៀបចំកន្លែងនៅនិងអាហារហូបចុកសម្រាប់គាត់ផង" ។

មាណពទាំងនោះ បាននាំគ្នាជូនព្រះអគ្គមហេសីទៅដល់ផ្ទះព្រាហ្មណ៍ ហើយក៏បានជម្រាបពាក្យបណ្តាំរបស់អាចារ្យដល់ប្រពន្ធគាត់ ។ គ្រានោះ ព្រាហ្មណីដឹងថាជាប្អូនស្រីរបស់ប្តីខ្លួន ក៏អញ្ជើញប្អូនថ្លៃឲ្យងូតទឹកក្តៅឧណ្ហ[៣០] ៗ ឯខ្លួនគាត់ក៏មករៀបចំទីសម្រាក ហើយអញ្ជើញនាង

[៣០] (គុ.) (បា.),(សំ.) (អ៊ុន-ហ:) (ឧណ្ហ) ក្តៅ ។ ព. ផ្ទ. សីត ឬ សីតល ។ (ខ្មែរ អ. ថ. អ៊ុន) សំដៅសេចក្តីថា "ក្តៅបន្តិច ៗ, ក្តៅសង្កន់ ៗ" : ទឹកក្តៅឧណ្ហ ៗ (ដើម្បីកុំឲ្យច្រឡំ, សរសេរជា ឧណ្ហ៍ ក៏បាន : ក្តៅឧណ្ហ៍ ៗ) ។

សម្រាក ។ ព្រះអគ្គមហេសីក៏ផ្ទំលក់ទៅ ។ បន្ទាប់មក តាព្រាហ្មណ៍ងូត ទឹកស្រះរួចត្រឡប់មកផ្ទះវិញ ក៏ដល់ពេលបាយល្ងាច ហើយគាត់ប្រើ ប្រពន្ធទៅហៅប្អូនស្រី ទទួលទានបាយរួមគ្នាតែម្ដង ។ បន្ទាប់មក ពីរ នាក់ប្ដីប្រពន្ធបានធ្វើការរក្សានិងទំនុកបម្រុងនាង ខាងក្នុងគេហដ្ឋាន ខ្លួនដោយក្ដីអាណិតស្រឡាញ់ដោយសុទ្ធចិត្ត ។

## មហាជនកកុមារ

មិនយូរប៉ុន្មាន ព្រះអគ្គមហេសីបានសម្រាលបុត្រដែលមាន សម្បុរល្អភ្លឺថ្លាដូចជាមាស ហើយដាក់ឈ្មោះដូចនឹងជីតាថា "**មហាជនក-កុមារ**" ។ មហាជនកកុមារ ចម្រើនវ័យវឌ្ឍនាការ[៣១] ឡើង គេតែងលេង កម្សាន្តជាមួយនឹងកុមារដទៃ ៗ ក្នុងស្រុកជាមួយគ្នា ។ កុមារទាំងឡាយ ផ្សេង ៗ តែងលេងធាតៅរំខានដល់មហាជនកកុមារ ។ មហាជនកកុមារ តែងកើតការធុញទ្រាន់ ហើយចាប់ពួកគេពេញទំហឹង វាយធ្វើបាបឲ្យ ពួកគេយំ ដោយមហាជនកកុមារអាងខ្លួនមានកម្លាំងខ្លាំង ព្រោះជាប់ សែស្រឡាយពីខត្តិយត្រកូលនោះផង ដោយមានះរឹងត្អឹង ព្រោះគេ កើតនៅក្នុងផ្ទះតាព្រាហ្មណ៍ដែលជាអាចារ្យធំនោះផង ។ ពួកកុមារ ដែលមហាជនកកុមារវាយធ្វើបាប តែងស្រែកយំឮខ្លាំង ៗ ដល់ម្ដាយ ឪពុករបស់ពួកគេ ពេលម្ដាយឪពុកសួរទៅ ពួកគេតែងប្រាប់ថា ៖

---

[៣១] ចម្រើនធំ, ពេញវ័យ ។

"អាកូនមេស្រីមេម៉ាយវាយខ្ញុំ" ។

មហាជនកកុមារឮដូច្នោះ គិតថា ៖

"ម្ដេចក៏ពួក គេហៅអញថា កូនមេស្រីមេម៉ាយញឹកញាប់ម្ល៉េះ,

មិនអីទេ អញនឹងសួរម្ដាយអញមើល" ។

ក្នុងថ្ងៃមួយ មហាជនកកុមារសួរម្ដាយថា ៖

"ម៉ែ ! អ្នកណាជាឪពុករបស់ខ្ញុំ ?"

ម្ដាយឮកូនសួរដូច្នោះ បញ្ឆោតកូនថា ៖

"នែកូន, ឪពុករបស់កូនគឺតាព្រាហ្មណ៍ហ្នឹងឯង" ។

លុះថ្ងៃក្រោយ ៗ មកទៀត មហាជនកកុមារឮពួកកុមារដែលខ្លួនវាយ និយាយឡកឡឺយថា "អាកូនស្រីមេម៉ាយ" ដូចមុន គេក៏តបទៅវិញថា ៖

"ឪពុករបស់ខ្ញុំគឺតាព្រាហ្មណ៍ មិនអ៊ីចឹងអ្ហែ ?"

កុមារផ្សេង ៗ ចំអកថា ៖

"តាព្រាហ្មណ៍ហ្នឹង ជាឪពុករបស់ឯងពីអង្កាល់ ?"

មហាជនកកុមារក៏គិតថា "ពួកនេះចំអកឲ្យអញ ហើយតើ តើតាព្រាហ្មណ៍ហ្នឹងជាឪពុករបស់អញមែនឬមិនមែនហ្ន៎ ? ការណ៍នេះច្បាស់ជាម្ដាយអញប្រាប់មិនត្រង់ទេ មុខជាគាត់លាក់លៀមហើយ, មិនអីទេ អញនឹងប្រើឧបាយធ្វើឲ្យគាត់ប្រាប់ត្រង់ឲ្យខាងតែបាន ។

កាលម្ដាយកំពុងបំបៅដោះ មហាជនកកុមារខាំដោះម្ដាយ ហើយនិយាយថា ៖

"ម៉ែ ! នរណាជាឪពុករបស់ខ្ញុំពិតប្រាកដ, បើពុំប្រាប់ឲ្យត្រង់ទេ, ខ្ញុំនឹងខាំក្បាលដោះម៉ែឲ្យដាច់ពុំខាន" ។

ព្រះអគ្គមហេសីអស់ឧបាយបញ្ឆោតកូន ក៏រៀបរាប់តាមត្រង់ថា ៖

"ហៃកូនសម្លាញ់មាសម្ដាយ, កូនគឺជាព្រះរាជបុត្ររបស់ព្រះរាជា ព្រះបាទ**អរិដ្ឋជនក** នៅឯក្រុងមិថិលា ដែនវិទេហៈ, ព្រះបិតារបស់បុត្រត្រូវឧបរាជបោលជនក ជាព្រះបិតុលាធ្វើគុតហើយ ។ មាតាហេតុតែចង់រក្សាបុត្រឲ្យរួចផុតពីសេចក្ដីស្លាប់ ទើបបានភៀសខ្លួនមកនគរនេះ ។ ឯលោកអុំព្រាហ្មណ៍នោះ គាត់ទុកមាតាដូចប្អូនស្រីបង្កើតរបស់គាត់ ហើយជួយទំនុកបម្រុងយើងទាំងពីរនាក់រៀងដរាបមក" ។

តាំងពីមហាជនកកុមារស្ដាប់ការរៀបរាប់ដ៏ជួរចត់អំពីប្រវត្តិត្រកូលខ្លួនពីព្រះមាតាដូច្នោះហើយ ព្រះកុមារឈប់ប្រើកំហឹងជាមួយនឹងកុមារផងគ្នា បើទុកណាជាពួកគេស្ដីឲ្យថា ខ្លួនជាកូនស្រីមេម៉ាយក៏ដោយ ។

# ជំពូកទី ២

## សេចក្តីព្យាយាមរបស់មហាជនក

### មហាជនកធ្វើដំណើរទៅសុវណ្ណភូមិ

ក្នុងចន្លោះអាយុ ១៦ ឆ្នាំ មហាជនកកុមារបានរៀនចេះចប់ត្រៃវេទ[៣២]និងសិល្បវិជ្ជាទាំងអស់ លុះដល់អាយុ ១៦ ឆ្នាំបរិបូណ៌ហើយ មហាជនកពេញកំលោះរូបស្រស់សង្ហា ។ គ្រានោះ មហាជនកមាន

[៣២] (ន.) (សំ.),(បា.) (វេ-ទៈ ឬ វេត) សេចក្តីដឹង, វិជ្ជា, ចំណេះ ។ គម្ពីរសម្តែងបែបរបៀបផ្សេង ៗ ខាងសាសនាព្រាហ្មណ៍, ក្នុងសម័យដើម មានត្រឹមតែ ៣ យ៉ាងគឺ ១-ឫគ្វេទ ឬ ឥរុវេទ មានដំណើរសេចក្តីជាពាក្យឆន្ទសម្រាប់សូត្រសរសើរពួកទេវតា; ២-យជុវេទ ឬ យជ្ជុវេទ មានដំណើរសេចក្តីជាពាក្យពាយរណ្តំ សម្រាប់សូត្របូជាឬបួងសួង; ៣-សាមវេទ មានដំណើរសេចក្តីជាពាក្យឆន្ទសម្រាប់សូត្រក្នុងពិធីថ្វាយទឹកសោម... ។ វេទទាំង ៣ នេះសុទ្ធតែប្រើភាសាសំស្ក្រឹត ហៅដោយរួបរួមថា វេទត្រ័យ ឬ ត្រ័យវិទ្យា ឬក៏ ត្រៃវេទ; ពួកព្រាហ្មណិកប្រកាន់ជឿស៊ប់ថា មហាព្រហ្មប្រសិទ្ធីឲ្យកើតឡើង មិនមែនមនុស្សតាក់តែងទេ; លុះចំណេរតមក កើតមាន អថព៌វេទ ឬ អថព្វ--"វេទសម្រាប់សូត្រហៅឬបណ្តេញខ្មោចបិសាច..." មួយថែមទៀតរួមជាវេទមាន ៤ យ៉ាង ។ វេទកោសល (--ទៈកោសល់) សេចក្តីឈ្លាស, ស្ទាត់, ជំនាញ ក្នុងវេទ ។ វេទប្រទាន (--ទ័ប-ប្រៈ--) ការបង្រៀនវេទ ។ វេទមន្ត ឬ--មន្ត្រ (វេត-មន់) មន្តក្នុងវេទ ។ ខ្មែរច្រើននិយាយសំដៅមន្តអាគម, មន្តសម្រាប់សូត្រស្តោះផ្លុំ ។ វេទវិទ្យា (--ទៈវិត-ទ្យា) វិទ្យាក្នុងវេទ, ការចេះវេទ ។ វេទសាស្ត្រ (--ទៈសាស) គម្ពីរវេទ ។ល។

បំណាំងចង់ដណ្ដើមយករាជ្យជារបស់ព្រះបិតាខ្លួនមកវិញ ទើបលោកសួរម្ដាយថា ៖

"ម៉ែ តើម៉ែមានទ្រព្យអ្វីនៅក្នុងដៃខ្លះឬក៏អត់ ? បើពុំមាននោះទេ ខ្ញុំនឹងធ្វើជំនួញរកទ្រព្យឲ្យបានច្រើន ហើយទៅដណ្ដើមយករាជ្យជារបស់ព្រះបិតាមកវិញ" ។

ម្ដាយប្រាប់ថា ៖

"នែកូន ម្ដាយមកនេះមិនមែនដៃទទេទេ ទ្រព្យសំខាន់ ៗ ដែលម្ដាយយកមកមានតែ ៣ គឺ កែវមុក្ដា[៣៣] ១ កែវមណី[៣៤] ១ ពេជ្រ[៣៥] ១ ។ បណ្ដាទ្រព្យទាំង ៣ ប្រភេទនេះ ទ្រព្យមួយណាក៏ល្មមគ្រប់គ្រាន់ ដើម្បីដណ្ដើមយករាជ្យមកវិញបាន ។ កូនចូរយកទ្រព្យនោះ ទៅដណ្ដើមរាជ្យចុះ កុំធ្វើជំនួញអី" ។

មហាជនកស្នើសុំថា ៖

"ម៉ែ សូមម៉ែឲ្យទ្រព្យខ្ញុំពាក់កណ្ដាលបានហើយ ខ្ញុំនឹងយកទ្រព្យនោះធ្វើជាដើមទុនទៅរកស៊ីនៅឯសុវណ្ណភូមិ លុះសន្សំទ្រព្យបានច្រើនហើយ ខ្ញុំនឹងដណ្ដើមយករាជ្យ" ។

---

[៣៣] កែវមុក្ដា ឈ្មោះកែវ ឬត្បូងមានតម្លៃមួយប្រភេទ; ត្បូងដែលកើតអំពីខ្យង, គជ់ខ្យង; ខ្យងដាំ ។

[៣៤] កែវមណី ឈ្មោះកែវឬត្បូងវិសេសមួយប្រភេទ; ពេជ្រ, ខ្យងដាំ; ។

[៣៥] ពេជ្រ ឈ្មោះត្បូងពិសេសមួយប្រភេទមានសាច់រឹង មានពន្លឺចាំងផ្លុះព្រាត ៗ ។

មហាជនក បានទទួលទ្រព្យពាក់កណ្ដាលអំពីម្ដាយ ចងជាពង្វេច[៣៦] ហើយដើរទិញទំនិញលើកមកដាក់លើសំពៅ ជាមួយនឹងពួកឈ្មួញដទៃជាច្រើននាក់ទៀត ដែលពួកគេត្រូវធ្វើដំនួញទៅសុវណ្ណភូមិដែរ ។ លុះដញ្ជូនដាក់សំពៅរួចរាល់ហើយ មហាជនកត្រឡប់មកផ្ទះវិញ ក្រាបថ្វាយបង្គំម្ដាយជម្រាបលាថា ៖

"ម៉ែ ខ្ញុំសុំទៅសុវណ្ណភូមិ" ។

ម្ដាយឃាត់កូនថា ៖

"នែកូន ដែលហៅថាសមុទ្រ ៗ ជាទីមានទឹកល្វឹងល្វើយដាច់កន្ទុយភ្នែក មានរលកធំ ៗ ប្រកបដោយព្យុះនិងភ្លៀងជាដរាបមានអន្តរាយច្រើន ។ អ្នកដែលបានចុះសមុទ្រហើយ រួចជីវិតត្រឡប់មកវិញ មានតិចតួចណាស់ ។ កុំទៅអីកូន, ទ្រព្យរបស់យើងច្រើនល្មមសម្រាប់ទៅដណ្ដើមយករាជ្យវិញបាន" ។

មហាជនកនិយាយថា ៖

"ខ្ញុំខានទៅមិនបានទេ ម៉ែ, ខ្ញុំត្រូវតែទៅ" ។

ថាប៉ុណ្ណោះហើយ មហាជនកក្រាបថ្វាយបង្គំម្ដាយ ដើរចេញអំពីផ្ទះឡើងសំពៅចេញដំណើរទៅជាមួយឈ្មួញដទៃទៀត ។

---

[៣៦] (ន.) សំណុំក្រសោបដែលវេចអ្វី ៗ ។ ធ្លាប់ប្រើ បង្វេច ៗ យូរណាស់ហើយ ប៉ុន្តែគួរប្រើ ពង្វេច តាមប្រភពដើមថា វេច វិញ ។

## មហាជនកធ្លាយសំពៅ

ក្នុងថ្ងៃដែលមហាជនចុះសំពៅនោះ ព្រះបាទបោលជនក ទ្រង់ប្រឈួនក្នុងព្រះកាយរបស់ព្រះអង្គ ទ្រង់ផ្ទំតែលើក្រឡាព្រះបន្ទំប៉ុណ្ណោះ ស្ដេចមិនអាចយាងក្រោកទៅណាមកណាបានឡើយ ។ រីឯមនុស្ស ដែលជិះសំពៅធ្វើដំណើរនៅគ្រានោះ មានចំនួន ៧០០ នាក់ ។ ក្នុងរយៈពេលត្រឹមតែ ៧ ថ្ងៃ សំពៅចរលយទៅបានចម្ងាយ ៧០០ យោជន៍ ។ ដោយល្បឿនលឿនខ្លាំងពេក បន្ទះក្ដារសំពៅត្រូវបែកធ្លាយ ទឹកក៏ហូរចូល បណ្ដាលឲ្យសំពៅទៅមុខពុំរួច ទឹកក្នុងសំពៅកាន់តែច្រើនឡើង ៗ សំពៅក៏កាន់តែលិចចុះក្នុងមហាសមុទ្របន្តិចម្ដង ៗ ។ មនុស្សម្នាដែលនៅលើសំពៅទាំងអម្បាលម៉ាន[៣៧] មានសេចក្ដីរន្ធត់តក់ស្លុត ស្រែកទ្រហោយំ ខ្សឹកខ្សួល ស្ដាយប្រពន្ធកូន ម្នាក់ ៗ ខំសំបូងសង្រួង[៣៨]បន់ស្រន់ដល់អស់ទេវតាដែលឋិតនៅឋាននានា ។ ចំណែកព្រះមហាជនកតួអង្គព្រះពោធិសត្វ លោកពុំស្រែកទ្រហោយំ ខ្សឹកខ្សួល ឬក៏បន់ស្រន់ដល់ទេវតាទាំងឡាយឡើយ គ្រាន់តែដឹងថា សំពៅរកកល់នឹងលិចចុះ

---

[៣៧] អម្បាលម៉ាន ប៉ុន្មាន, ម្ល៉ា, យ៉ាងណា: ល្អអម្បាលម៉ានទៅ ?; ធំអម្បាលម៉ានក៏ដោយ ! ។

[៣៨] (កិ.) ពោលពាក្យបួងបាច់ប្រតិស្ឋអធិដ្ឋាន, ពោលពាក្យរំឭករំលើក ស្រាវជ្រាវពាវរកគុណឬអំពើល្អដែលបានធ្វើរួចមកហើយ, បួងសួងដើម្បីឲ្យបានសម្រេចការសមបំណង : សំបូងសង្រួងដល់គុណគ្រប់យ៉ាង, សំបូងសង្រួងទេវតា ។

ក្នុងមហាសមុទ្រភ្លាម លោកប្រញាប់ប្រញាល់ចាក់ស្គរលាយនឹងទឹក ដោះគោ ហើយផឹកឲ្យឆ្អែត រួចយកសំពត់សាដក[៣៩] ពីរផ្ទាំងដែលមាន សាច់ម៉ដ្ឋខៃជ្រលក់ប្រេងឲ្យជោកស្លៀកយ៉ាងខ្ជាប់ខ្ជួន ឈរផ្អែកខ្លួននឹង សសរក្ដោងសំពៅ ពេលសំពៅលិចចុះ លោកឡើងតាមសសរក្ដោង សំពៅ ។ រីឯមនុស្សម្នាទាំងឡាយស្រែកទ្រហោយំ មានទឹកភ្នែកហូរជោក ថ្ពាល់, ទោះបីខិតខំបន់ស្រន់ដល់ទេវតាឲ្យជួយយ៉ាងណាក៏ដោយ ក៏ ត្រូវពួកត្រីនិងអណ្ដើកធំ ៗ ខាំត្របាក់ជញ្ជែង[៤០] ដណ្ដើមគ្នាស៊ីអស់គ្មាន សល់រួចរស់ម្នាក់ណាឡើយ, នៅទីជុំវិញសំពៅលិចចម្ងាយប្រមាណ កន្លះឧសភៈ[៤១] ទឹកពណ៌ក្រហមត្រាដោយឈាមមនុស្ស ដែលត្រូវត្រី និងអណ្ដើកខាំត្របាក់ ។ ចំណែកព្រះមហាសត្ត ខំប្រតោងឡើងទៅ តាមសសរក្ដោង[៤២] រហូតដល់ចុងក្ដោង លុះឈរកំណត់ថា មិថិលានគរ ស្ថិតនៅត្រង់ទិសណាហើយ លោកក៏លោតបំប្លោងខ្លួនឲ្យរំលងហួសពី ហ្វូងត្រីនិងអណ្ដើក បានធ្លាក់ចុះនៅទីចម្ងាយមួយឧសភៈ ដោយសារ

---

[៣៩] សំពត់សម្រាប់ស្លៀកងូតទឹក ។

[៤០] ចឹក, ខាំ, ហែក ប្រដែងគ្នា : ត្មាតជញ្ជែងគម្រង់គោ ។

[៤១] ឈ្មោះរង្វាស់ឬមាត្រាវាស់មួយយ៉ាង (ប្រើក្នុងបុរាណសម័យ) ប្រវែងឬចម្ងាយ ២០ យដ្ឋិ (១៤០ ហត្ថ) : ចម្ងាយមួយឧសភ ។

[៤២] (ន.) (ជើង ដ) ប្រដាប់សម្រាប់ឲ្យជក់ខ្យល់មានសណ្ឋានផ្សេង ៗ ខ្លះស្រួច, ខ្លះ ទាល, ខ្លះជ្រុង : ក្ដោងទូក ។

លោកមានកម្លាំងខ្លាំង ។ រីឯព្រះបាទបោលជនក ទ្រង់សោយព្រះទិវង្គត ក្នុងថ្ងៃនោះដែរ ។ និយាយពីព្រះមហាសត្ត បន្ទាប់ពីលោតចុះទឹកហើយ លោកក៏ព្យាយាមហែលឆ្លងកាត់មហាសមុទ្រ មើលទៅដូចជាដុំមាស មួយដុំ កំពុងរសាត់អណ្តែតតែលតោល មុជងើប ៗ តាមចង្វាក់ចុះឡើង នៃរលកទឹកមហាសមុទ្រ ដែលមានពណ៌ដូចជាកែវមណី ។ ព្រះមហា-សត្តហែលអស់ ៧ ថ្ងៃ ក៏ងើយមើលទៅអាកាស ដឹងច្បាស់ថា ថ្ងៃនេះជាថ្ងៃពេញបូណ៌មី លោកក៏ខ្ពុរមាត់ដោយទឹកប្រៃ អធិដ្ឋានរក្សាឧបោសថ-សីល ។

## សេចក្តីសន្ទនារវាងទេពធីតាមណីមេខលានិងមហាជនក

សម័យនោះ ស្តេចចតុលោកបាល[៤៣]ចាត់នាងទេពធីតាមួយអង្គ ឈ្មោះ**មណីមេខលា** ឲ្យទៅរក្សាមហាសមុទ្រ ដោយដាក់បញ្ជាថា ៖

> "មនុស្សសត្វទាំងឡាយណាដែលប្រកបដោយគុណធម៌ មាន ការបម្រើមាតាជាដើម មិនត្រូវបណ្តោយឲ្យស្លាប់ក្នុងមហា-សមុទ្រទេ នាងត្រូវជួយសង្គ្រោះពួកគេដោយការជួយស្រង់ យកទៅដាក់លើគោក" ។

---

[៤៣] ស្តេចទេវតា ៤ អង្គជាធំក្នុងឋានចាតុម្មហារាជិកាសួគ៌ ជាអ្នករក្សាលោកគឺ ១- ព្រះបាទ **ធតរដ្ឋៈ** រក្សានៅទិសខាងកើត, ២- ព្រះបាទ **វិរុឡ្ហកៈ** រក្សានៅទិសខាងត្បូង, ៣- ព្រះបាទ **វិរូបក្ខៈ** រក្សានៅទិសខាងលិច, ៤- ព្រះបាទ **កុវេរៈ** (វេស្សវណ) រក្សានៅទិសខាងជើង ។

នៅពេលសំពៅលិច ទេពធីតាមណីមេខលាអាល័យតែ[៤៤]សប្បាយ នឹងការសោយទិព្វសម្បត្តិ ភ្លេចគិតថាខ្លួនមានតួនាទីមើលថែមហា-សមុទ្រ ម៉្លោះហើយនាងបានខកខានក្នុងការមើលថែមហាសមុទ្រ អស់រយៈពេល ៧ ថ្ងៃ ។ ត្រង់នេះ អាចារ្យខ្លះនិយាយថា នាងរវល់ទៅចូលរួមប្រជុំក្នុងចំណោមទេវតា (ទេវសមាគម) ។ គ្រានោះ ទេពធីតាមេខលា រំពឹងទៅភ្នាក់ខ្លួនថា ៖

"អស់រយៈពេល ៧ ថ្ងៃហើយតើ ដែលអញខកខានមិនបាន នៅមើលថែមហាសមុទ្រ តើនឹងមានព្រឹត្តិការណ៍អ្វីខ្លះកើតឡើងទៅហ្ន៎ ?"

លុះប្រមើលទៅ ស្រាប់តែឃើញព្រះមហាសត្តកំពុងហែលទឹកសមុទ្រតែម្នាក់ឯង នាងកើតសេចក្តីព្រួយក្នុងចិត្តថា ៖

"ប្រសិនបើមហាជនកត្រូវស្លាប់ក្នុងមហាសមុទ្រ អញច្បាស់ជាគ្មានសិទ្ធិចូលរួមប្រជុំក្នុងទេវសមាគម[៤៥]តទៅទៀតឡើយ" ។

---

[៤៤] (និ.) (--ល៉ៃ--) (រវល់តែ, ជាប់ដៃតែ, អាត់តែ : អាល័យតែស្តាប់គេនិយាយភាំងភ្លេចខ្លួន គេទៅចោលអស់ !; ឯងអាល័យតែលេង គេស៊ីនំអស់ ! ។

[៤៥] (ន.) (សំ.),(បា.) (សៈម៉ាគំ) (< សំ "ព្រម", ំ > ម + អាគម "ការមក") ការមកចួបជុំ, ការប្រជុំ; ការរួមគំនិតគ្នា, ដំណើររួបរួមកិច្ចការជាមួយគ្នា ។ ខ្មែរប្រើសំដៅសេចក្តីថា "ការចូលហ៊ុនគ្នា, ក្រុមហ៊ុន" ក៏បាន : សមាគមជំនួញ ក្រុមចូលហ៊ុនធ្វើជំនួញ (ហៅ ពាណិជ្ជសមាគម ឬ ពាណិជ្យ-- ក៏បាន) ។ សមាគមញាតិ ការប្រជុំញាតិ ឬការចួបជុំពួកញាតិ (ហៅ ញាតិសមាគម ក៏បាន) ។ ថេរសមាគម (ថេរ៉:--) ការប្រជុំពួកព្រះថេរៈ

គិតឃើញដូច្នេះហើយ ក៏ហោះមកឈរឰដ៏អាកាស ទាំងមានសរីរៈមិនទាន់បានតុបតែងស្អាតបាតនៅឡើយ នាងស្ថិតមិនឆ្ងាយអំពីព្រះមហាសត្តប៉ុន្មានទេ រួចបានសួរសាកល្បងព្រះមហាសត្តថា ៖

"កោយំ មជ្ឈេ សមុទ្ទស្មិំ  អបស្សំ តីរមាយុហេ
កំ ត្វំ អត្ថវសំ ញត្វា  ឯវំ វាយមសេ ភុសំ" ។

"យីអើ ! អ្នកណាគេនេះ ម្ដេចក៏ខំប្រឹងហែលក្នុងមហាសមុទ្រអ្វីម៉្លេះ បើសមុទ្រសែនធំល្វឹងល្វើយ មិនឃើញកោះត្រើយផង ? តើអ្នកឃើញប្រយោជន៍ដូចម្ដេច បានជាព្យាយាមហែលយ៉ាងដូច្នេះ ? "

គ្រានោះ ព្រះមហាសត្តឮពាក្យរបស់ទេពធីតាមណីមេខលាដូច្នោះ ក៏គិតថា ៖

"អញហែលឆ្លងមហាសមុទ្រមកទល់ថ្ងៃនេះ អស់រយៈពេលគម្រប់ ៧ ថ្ងៃហើយ មិនដែលឃើញនរណាម្នាក់គ្រាន់នឹងបានជាគ្នាសោះ ចុះសំឡេងនរណាគេហ្នំ និយាយមករកអញ ?"

---

ក្រុមជំនុំសង្ឃ (ប្រជុំដើម្បីវិនិច្ឆ័យអធិករណ៍ ឬដើម្បីប្រឹក្សាអំពីកិច្ចការរបស់សង្ឃ ។ ពុទ្ធិកសមាគម (ពុត-ធិ-ក:--) ការរួបរួមគំនិតគ្នារបស់អ្នកកាន់ពុទ្ធសាសនា (ដើម្បីទំនុកបម្រុងពុទ្ធសាសនាឲ្យរុងរឿងចម្រុងចម្រើន) ។ល ។

ហើយលោកងើយមើលទៅអាកាស ឃើញទេពធីតា លោកក៏បានឆ្លើយតបថា ៖

"និសម្ម វត្តំ លោកស្ស    វាយាមស្ស ច ទេវតេ
តស្មា មជ្ឈេ សមុទ្ទស្មិំ    អបស្សំ តីរមាយុហេ" ។

"នៃទេពធីតា ខ្ញុំបានពិចារណានូវវដ្ដៈ[៤៦]នៃសត្វលោកទាំងឡាយ និង អានិសង្សនៃសេចក្ដីព្យាយាមរួចហើយ ហេតុដូច្នោះ ខ្ញុំត្រូវតែព្យាយាមហែលឆ្លងសមុទ្រ បើទោះបីជាសមុទ្រសែនធំល្វឹងល្វើយមិនឃើញកោះត្រើយក៏ដោយចុះ" ។

ទេពធីតាកាលបានស្ដាប់នូវធម្មកថា[៤៧]របស់ព្រះមហាសត្តហើយ នាងមានបំណងនឹងស្ដាប់បន្ត ក៏ពោលបន្ថែមទៀតថា ៖

"គម្ភីរេ អប្បមេយ្យស្មិំ    តីរំ យស្ស ន ទិស្សតិ

---

[៤៦] (គុ.) (បា.),(សំ.) (វ័ត-ដៈ) (វដ្ដ; វ្ឫត្ត) ដែលវិល; មូល, ដែលជារង្វង់មូល ។ ន. ការវិលទៅមក; ដំណើរវិលកើតវិលស្លាប់; រង្វង់មូល; តម្លៃសម្រាប់ចាយប្រើស្បៀង ។ វដ្ដទុក្ខ ទុក្ខក្នុងវដ្ដៈ គឺទុក្ខសម្រាប់សត្វដែលវិលកើតវិលស្លាប់ ។ វដ្ដភ័យ ភ័យអំពីការវិលកើតវិលស្លាប់ ។ វដ្ដមូល ទីតាំងរបស់វដ្ដៈ, ឫសរបស់វដ្ដៈ ។ វដ្ដលោក លោកគឺការវិលកើតវិលស្លាប់ ។ វដ្ដសង្សារ (បា. --សំសារ) ដំណើរអន្ទោលវិលកើតវិលស្លាប់ ។ វដ្ដសន្និតំណវដ្ដៈ ។ល។

[៤៧] សម្ដីដែលជាធម៌; ការសម្ដែងធម៌; វាចាប្រកបដោយធម៌ ។

មោឃោ តេ បុរិសវាយាមោ　　អប្បត្វាវ មរិស្សសិ” ។

“មហាសមុទ្រដ៏សែនធំល្វឹងល្វើយមិនឃើញកោះត្រើយ ទាំងមានជម្រៅជ្រៅមិនអាចវាស់បាន អ្នកព្យាយាមហែលតាមតែកម្លាំងបាយ ការព្យាយាមរបស់អ្នកនោះឥតបានការអ្វីសោះនឹងសូន្យទទេ ព្រោះថា អ្នកនឹងស្លាប់មុនដល់ត្រើយ” ។

គ្រានោះ ព្រះមហាសត្តនិយាយនឹងនាងទេពធីតាថា ៖

“ទេវតេ កិំ ឆាមេតំ កថេសិ
វាយាមំ កត្វា មរន្តោបិ គរហាតោ មុច្ចិស្សាមិ” ។

“នែទេវធីតា, នាងនិយាយថាម៉េចនុ៎ះ, ខ្ញុំបានបំពេញព្យាយាមហើយ បើទោះបីខ្ញុំត្រូវស្លាប់ ក៏គង់ស្លាប់ទៅដោយគ្មានពាក្យតំណិះដំណៀល[៤៨]អំពីអ្នកផងទាំងពួងដែរ” ។

បន្ទាប់មកលោកពោលបន្តទៀតថា ៖

“អនណោ ញាតិនំ ហោតិ　　ទេវានំ បិតុនញ្ច សោ
ករំ បុរិសកិច្ចានិ　　ន ច បច្ឆានុតប្បតិ” ។

---

[៤៨] តំណិះតិះដៀល (ច្រើនតែនិយាយរិះគន់ក្នុងទីកំបាំងមិនចំពោះមុខ) ។

"បុរសត្រូវព្យាយាមបំពេញកិច្ចដែលជាតួនាទីរបស់ខ្លួនឲ្យបាន ទើបឈ្មោះថា ជាអ្នកមិនជំពាក់បំណុលពួកញាតិ ពួកទេវតា និងពួកបិតា (ព្រហ្ម) កាលបើបានបំពេញកិច្ចរបស់ខ្លួនរួចរាល់ហើយ រមែងមិនមានសេចក្តីក្តៅក្រហាយស្តាយក្រោយឡើយ" ។

ទេពធីតាតបនឹងព្រះមហាសត្តថា ៖

"អបារនេយ្យំ យំ កម្មំ អផលំ កិលមថុទ្ទយំ
តត្ថ កោ វាយាមេនត្ថោ មច្ចុ យស្សាភិនិប្បតំ" ។

"ការងារដែលគេព្យាយាមធ្វើហើយ តែមិនបានសម្រេច សេចក្តីព្យាយាមនោះចាត់ទុកថាពុំមានផលអ្វីទេ ទទួលបានតែសេចក្តីលំបាកជាកម្រៃប៉ុណ្ណោះ ។ សេចក្តីព្យាយាមធ្វើការងារនោះ តើនឹងបានប្រយោជន៍អ្វី បើបុគ្គលអ្នកព្យាយាមធ្វើនោះ ស្លាប់បាត់ទៅហើយ" ។

នាងទេពធីតានិយាយដល់ឃ្លានេះ ស្រាប់តែព្រះមហាសត្តនិយាយកាត់នាង ដើម្បីកុំឲ្យនាងនិយាយតទៅទៀត, លោកពោលថា ៖

"អបារនេយ្យមច្ចន្តំ យោ វិទិត្វាន ទេវតេ
ន រក្ខេ អត្តនោ បាណំ ជញ្ញា សោ យទិ ហាបយេ" ។

"នៃទេវតា អ្នកណាដឹងថា ព្យាយាមធ្វើហើយ មិនអាចសម្រេចផល ហើយបើបុគ្គលចេះតែបោះបង់សេចក្ដីព្យាយាមចោលគ្រប់ករណីយកិច្ចនោះ ឈ្មោះថា មិនរក្សាជីវិតរបស់ខ្លួន បុគ្គលនោះគង់ដឹងនូវផលនៃសេចក្ដីខ្ជិលនោះមិនខាន" ។

"អធិប្បាយផលំ ឯកេ អស្មឹ លោកស្មិ ទេវតេ
បយោជយន្តិ កម្មានិ តានិ ឥជ្ឈន្តិ វា ន វា" ។

"ម្នាលទេវតា បុគ្គលពួកខ្លះក្នុងលោកនេះ កាលឃើញនូវផលនៃសេចក្ដីប្រាថ្នាហើយ ក៏ប្រកបកិច្ចការទាំងឡាយមានកសិកម្មនិងពាណិជ្ជកម្មជាដើម ការងារនោះ ចួនក៏សម្រេចផលតាមសេចក្ដីប្រាថ្នា ចួនក៏អត់" ។

"សន្ទិដ្ឋិកំ កម្មផលំ ននុ បស្សសិ ទេវតេ
សន្នា អញ្ញេ តរាមហំ តញ្ច បស្សាមិ សន្តិកេ" ។

"ម្នាលទេវតា ក្រែងអ្នកបានឃើញផលនៃសេចក្ដីព្យាយាមច្បាស់នឹងភ្នែកហើយតើ ! មើលហ៎ ជនទាំងឡាយដ៏ច្រើនបានលង់នៅក្នុងមហាសមុទ្រ ក្លាយជាចំណីពួកត្រីនិងអណ្ដើក ព្រោះតែមិនបានធ្វើសេចក្ដីព្យាយាម នៅសល់តែខ្ញុំម្នាក់គត់ដែលខំហែលឆ្លងហើយបានមកជួបនឹងនាងនៅជិតខ្ញុំទៀត" ។

"សោ អហំ វាយមិស្សាមិ  យថាសត្តិ យថាពលំ
គច្ឆំ ចារំ សមុទ្ទស្ស  កស្សំ បុរិសការិយំ" ។

"តាំងពីកើតមក ខ្ញុំពុំដែលបានឃើញទេវតាមានរូបទិព្វមកជិតខ្ញុំយ៉ាងនេះទេ ។ ខ្ញុំនឹងព្យាយាមហែលឲ្យអស់ពីកម្លាំងកាយចិត្ត បើខ្ញុំបានទៅដល់ត្រើយសមុទ្រហើយ ខ្ញុំនឹងបំពេញកិច្ចដែលបុរសគួរធ្វើ" ។

ក្រោយពេលឮពាក្យប្រកបដោយការប្ដេជ្ញាចិត្តដ៏មុឹងម៉ាត់របស់ព្រះមហាសត្តហើយ ទេវតាជញ្ជក់មាត់សរសើរថា ៖

"យោ ត្វំ ឯវំ គតេ ឱឃេ  អប្បមេយ្យេ មហណ្ណវេ
ធម្មវាយាមសម្បន្នោ  កម្មុនា នាវសីទសិ
សោ ត្វំ តត្ថេវ គច្ឆាហិ  យត្ថ តេ និរតោ មនោ" ។

"មហាសមុទ្រមានអន្លង់ទឹកដ៏ជ្រៅប្រមាណមិនបានយ៉ាងនេះ អ្នកមានសេចក្ដីព្យាយាមប្រកបដោយធម៌ រមែងមិនលិចលង់ឡើយ ព្រោះសេចក្ដីព្យាយាមដ៏អស្ចារ្យនោះ ចូរអ្នកទៅទីណាដែលអ្នកប្រាថ្នាចុះ" ។

លុះពោលយ៉ាងនេះរួចហើយ ទេពធីតាសួរថា ៖

"បពិត្របណ្ឌិតអ្នកមានព្យាយាម តើអ្នកមានបំណង នឹងទៅទីណា ? ខ្ញុំនឹងនាំអ្នកទៅទីនោះ" ។

ព្រះមហាសត្តប្រាប់ថា ៖

"សូមមេត្តានាំខ្ញុំទៅនគរមិថិលាផងចុះ" ។

## បណ្ដាំមរណៈរបស់ព្រះបាទបោលជនក

រំពេចនោះ ទេពធីតាមណីមេខលាស្រង់ព្រះមហាសត្តឡើង បីត្រកងដោយដៃទាំងពីរផ្អឹបឲ្យជេកនឹងដើមទ្រូង មើលទៅដូចជាសំណុំបាច់ផ្កា បីហោះកាត់អាកាសវេហាស៍ ប្រៀបដូចស្ត្រីបីនូវកូនតែមួយជាទីស្រឡាញ់ ។ មហាជនកហត់នឿយអស់កម្លាំងជាពន់ពេកក្នុងការហែលត្រាំខ្លួនក្នុងទឹកប្រៃអស់ពេល ៧ ថ្ងៃ លុះបានមកប៉ះនឹងសម្ផស្សទិព្វនៃស្រីសួគ៌ា លោកក៏លង់លក់យ៉ាងស្រួលនៅលើព្រះហស្តទាំងទ្វេរបស់ទេពធីតាមណីមេខលា ។

បន្ទាប់មក ទេពធីតាបានហោះទៅដល់ឧទ្យាន[៤៩] ស្វាយមួយ ក៏បានផ្ដេកព្រះមហាសត្តបំបែរព្រះភក្ត្រទៅខាងស្ដាំ លើផ្ទាំងមង្គលសិលាក្នុងឧទ្យាននោះ និងបានផ្ដាំពពួកទេវតាក្នុងឧទ្យាននោះ សូមឲ្យជួយ

---

[៤៩] (ន.) (សំ.) (អ៊ុត-ទ្យាន) (< ឧត៑ > ឧទ៑ + យាន; បា. ឧយ្យាន "ទីសម្រាប់កម្សាន្តមានដើមឈើខ្ពស់ ៗ ដែលគេចូលដល់ គេដើរបណ្ដើរងើយមើលលើបណ្ដើរ") សួនដែលមានឈើខ្ពស់ ៗ មានផ្កាផ្លែនិងលម្អគួរឲ្យចង់ដើរមើលកម្សាន្តចិត្ត, សួនមានឈើជាម្លប់សម្រាប់ដើរលេងកែអផ្សុក (ខ្មែរច្រើនប្រើក្លាយជា ឱទ្យាន) ។

យកចិត្តទុកដាក់រក្សាព្រះមហាសត្តឲ្យបានហ្មត់ចត់ ហើយខ្លួនព្រះនាង ក៏វិលទៅកាន់លំនៅឋានអាត្មាវិញ ។

ថ្វៃងពីព្រះបាទបោលជនកឯណោះវិញ ព្រះអង្គពុំមានព្រះរាជបុត្រមួយព្រះអង្គគ្រាន់នឹងបានស្នងរាជ្យបន្តអំពីព្រះបិតាឡើយ មានតែព្រះរាជធីតាមួយអង្គប៉ុណ្ណោះ នាមថា **សីវលីទេវី** ។ ព្រះរាជធីតាសីវលីនេះ មានប្រាជ្ញាឆ្លាតវាងវៃណាស់ ។ កាលដែលព្រះរាជាទ្រង់កំពុងប្រឈួនខ្លាំង មុននឹងសោយព្រះទិវង្គត ពួកនាហ្មឺនសព្វមុខមន្ត្រីទាំងឡាយក្រាបទូលសួរព្រះអង្គថា ៖

"បពិត្រព្រះករុណាថ្លៃវិសេស បើព្រះអង្គសោយទិវង្គតទៅ តើនឹងឲ្យពួកទូលព្រះបង្គំជាខ្ញុំថ្វាយរាជាណាចក្រដល់នរណា ?"

ព្រះរាជាទ្រង់មានព្រះរាជបណ្តាំដល់អស់នាហ្មឺនសព្វមុខមន្ត្រីទាំងនោះថា ៖

"ហៃអស់លោកនាហ្មឺនសព្វមុខមន្ត្រីទាំងឡាយ, អស់លោកចូរឲ្យរាជាណាចក្រដល់បុគ្គលអ្នកមានសមត្ថភាពធ្វើឲ្យសីវលីបុត្រីយើងសប្បាយហឫទ័យ, ពុំនោះទេ ឲ្យដល់អ្នកណាដែលដឹងនូវក្បាលដំណេកនៃរាជបល្ល័ង្កដែលមានជ្រុង ៤, ពុំនោះទេ ឲ្យដល់

អ្នកណាដែលអាចលើកសហស្សថាមធ្នូ[៥០], ពុំនោះសោតទេ ឲ្យ

ដល់អ្នកណាដែលអាចរកឃើញមហាកំណប់ទាំង ១៦" ។

ពួកនាហ្មឺនសព្វមុខមន្ត្រីក្រាបទូលស្នើថា ៖

"បពិត្រព្រះសម្មតិទេព, សូមព្រះអង្គមេត្តាប្រាប់បញ្ជីសរុបនៃ

ចំនួនកំណប់ទ្រព្យទាំង ១៦ នោះ" ។

គ្រានោះ ព្រះរាជាទ្រង់ត្រាស់ប្រាប់សមត្ថភាព ៣ យ៉ាងរបស់បុរសអ្នកគួរទទួលរាជ្យ ព្រមទាំងមហាកំណប់ ១៦ កន្លែង ដូចទៅ ៖

"សូរិយុគ្គមនេ និធិ អថោ ឱក្កមនេ និធិ
អន្តោ និធិ ពហិ និធិ ន អន្តោ ន ពហិ និធិ ។
អារោហនេ មហានិធិ អថោ ឱរោហនេ និធិ
ចតូសុ មហាសាលេសុ សមន្តា យោជនេ និធិ ។
ទន្តគ្គេសុ មហានិធិ វាលគ្គេសុ ច កេបុកេ
រុក្ខគ្គេសុ មហានិធិ សោឡសេតេ មហានិធី ។
សហស្សថាមោ បល្លង្កោ សីវលិអារាធនេន ច" ។

មហាកំណប់ ១៦ នោះគឺ ៖

១- **សូរិយុគ្គមនេ និធិ** កំណប់ត្រង់ទីព្រះអាទិត្យរះ

---

[៥០] ធ្នូដែលមានទម្ងន់ធ្ងន់ គឺតម្រូវឲ្យបុរសមាឌធម្មតាចំនួន ១ ពាន់នាក់ ទើបអាចលើករួច ។

២- **ឱក្កាមនេ និធិ** *កំណប់ត្រង់ព្រះអាទិត្យលិច*

៣- **អន្តោ និធិ** *កំណប់ខាងក្នុង*

៤- **ពហិ និធិ** *កំណប់ខាងក្រៅ*

៥- **ន អន្តោ ន ពហិ និធិ** *កំណប់មិនមែនខាងក្នុងមិនមែនខាងក្រៅ*

៦- **អារោហនេ មហានិធិ** *កំណប់ត្រង់ទីឡើង*

៧- **ឱរោហនេ និធិ** *កំណប់ត្រង់ទីចុះ*

៨, ៩, ១០, ១១- **ចតូសុ មហាសាលេសុ** *កំណប់ត្រង់ដើមសាលព្រឹក្ស*[៥១] *ធំទាំងបួន*

---

[៥១] (ន.) (សំ.),(បា.) (*សាល៉ៈព្រឹក*) (*សាល + វ្ឫក្ស; សាល + រុក្ខ*) *ឈ្មោះឈើមួយប្រភេទមានស្លឹកវែង ៗ ស្រួច ៗ ជាឈើធំ មានផ្កាចេញទងពីតួដើម និងពីមែកធំ ៗ ផ្កាមូល ៗ ធំ ៗ (មានសណ្ឋានស្រដៀងនឹងនាគម៉ុងសាយចិន) សម្បុរក្រហមលាយលឿង មានក្លិនក្រអូបឈ្ងប់ រីកហើយធាប់រោយទៅវិញ ជ្រុះត្របកនិងកេសរមករោយរាយលើផែនដី ផ្លែមូល ៗ ធំ ៗ ជាងផ្លែក្រពៅ ក្នុងមួយឆ្នាំ ៗ ជ្រុះស្លឹកអស់រលីងច្រើនដងហើយលាស់ត្រួយខ្ចីភ្លាម ៗ មិនបង្អង់យូរ ។ល។ ព្រះសិទ្ធត្ថសក្យមុនីគោតម ទ្រង់ប្រសូតទាំងទ្រង់បរិនិព្វានផងដែរនៅក្រោមដើមសាលព្រឹក្ស (ខ្មែរធ្លាប់យល់មកថា ដើមរាំងភ្នំ ផ្ទុយពីការពិត) ។ ឈើនេះមានឈ្មោះហៅបានបីយ៉ាងគឺហៅថា សាលព្រឹក្ស ក៏បាន, ហៅ អស្សកណ្ណព្រឹក្ស ក៏បាន, ហៅ សជ្ជព្រឹក្ស ក៏បាន ។ កាលពីក្នុងបុរាណសម័យ ឈើនេះមានតែឯប្រទេសឥណ្ឌា, សព្វថ្ងៃនេះ មានសម្បូរណ៍ក្នុងប្រទេសកម្ពុជា ច្រើនតែក្នុងវត្តអារាមនៃភិក្ខុសង្ឃ, ជាឈើមានគ្រាប់ងាយបណ្តុះងាយដាំតាមតែដីបែបណាក៏ដាំបានដែរ ។*

១២- **សមន្តា យោជនេ និធិ** *កំណប់ត្រង់ទីមួយយោជន៍ជុំវិញ*

១៣- **ឧន្តត្ថេសុ មហានិធិ** *កំណប់ធំត្រង់ចុងភ្លុកដំរីទាំងពីរ*

១៤- **វាលគ្គេសុ** *កំណប់ត្រង់ចុងកន្ទុយដំរី*

១៥- **កេបុកេ** *កំណប់ក្នុងទឹក*

១៦- **រុក្ខគ្គេសុ មហានិធិ** *កំណប់ធំត្រង់ចុងឈើ ។*

*សមត្ថភាព ៣ យ៉ាងគឺ ៖*

១- **សហស្សថាមោ** *បុរសលើកសហស្សថាមធ្នូរួច*

២- **បល្លង្កោ** *ដឹងក្បាលដំណេកនៃបល្លង្កជ្រុង ៤*

៣- **សីវលិអារាធនេន** *បុរសញុំាងសីវលីរាជបុត្រីឲ្យសប្បាយព្រះហឫទ័យ" ។*

*ព្រះបាទបោលជនក ទ្រង់ប្រាប់នូវចំនួនសរុបនៃមហាកំណប់ទាំង ១៦ ព្រមទាំងសមត្ថភាព ៣ យ៉ាងដូច្នេះហើយ ទ្រង់ក៏សោយទិវង្គតទៅ ។*

## សីវលីទេវីតាក់សេនាបតី[៥២]

*អាមាត្យនិងពួកនាហ្មឺនសព្វមុខមន្ត្រីទាំងឡាយ បានចាត់ចែងពិធីថ្វាយព្រះភ្លើងបូជាព្រះបរមសពរបស់ព្រះមហាក្សត្រ ។ បន្ទាប់អំពីព្រះមហាក្សត្រសោយទិវង្គតកន្លងទៅបាន ៧ ថ្ងៃ ពួកមន្ត្រីរាំងទាំង*

---

[៥២] *សេនាបតី (សំ. បា.) ចៅហ្វាយសេនាគឺមហាមាត្យ; មន្ត្រីសក្តិធំទីចតុស្តម្ភ (ខ្មែរសម័យបុរាណហៅ ព្រះបាទអស់ជំនុំ) ។*

ឡាយ បានជួបជុំជជែកពិភាក្សាគ្នាថា ៖

"នែអស់លោក, ព្រះរាជាបានផ្តាំថា រាជាណាចក្រត្រូវឲ្យដល់បុគ្គលណាដែលមានសមត្ថភាពញ៉ាំងរាជធីតាព្រះអង្គឲ្យត្រេកអរបាន, តើនរណាទៅហ្ន៎ ដែលមានសមត្ថភាពយ៉ាងនេះ" ។

លុះប្រឹក្សាគ្នាដូច្នេះហើយ ជ្រើសយកលោកសេនាបតីឈ្មោះ **វល្លភៈ** ដោយគិតថា លោកសេនាបតីវល្លភៈនឹងអាចញ៉ាំងព្រះរាជធីតាឲ្យត្រេកអរបាន រួចបានបញ្ជូនដំណឹងទៅជម្រាបលោក ។ បន្ទាប់ពីឮនូវដំណឹងនោះភ្លាម លោកសេនាបតីយល់ព្រម ហើយបានធ្វើដំណើរទៅដើម្បីទទួលនូវរាជសម្បត្តិ លុះដល់ទ្វារព្រះបរមរាជវាំង បានប្រើទាហានឲ្យឡើងទៅក្រាបទូលដំណឹងដល់រាជធីតាថា ខ្លួនមកដល់ហើយ ។ រាជធីតាទទួលដំណឹងថា សេនាបតីវល្លភៈអញ្ជើញមកដល់ហើយ ព្រះនាងគិតសាកល្បងលោកសេនាបតីនោះថាតើមានសេចក្តីអង់អាចក្នុងការទ្រទ្រង់ស្វេតច្ឆត្រ[៥៣]ដ៏មានស្រីសួស្តីបានឬក៏អត់ រួចបានឲ្យអ្នកបម្រើទៅអញ្ជើញលោកសេនាបតីចូលគាល់ជាប្រញាប់ ។ លុះឮថាព្រះនាងអនុញ្ញាតឲ្យចូលគាល់ដូច្នោះ លោកសេនាបតី មានបំណងញ៉ាំងព្រះនាងឲ្យគាប់ព្រះទ័យ ក៏ប្រញិបប្រញាប់ស្ទុះឡើងទៅគាល់ព្រះរាជធីតាក្នុងរាជដំណាក់របស់ព្រះនាង ។ ភ្លាមនោះព្រះនាងមានរាជបំណងសាកល្បងលោកសេនាបតី ដោយបញ្ជាលោកសេនាបតីឲ្យ

[៥៣] ឆត្រស ។

រត់ក្នុងមហាតលដ្ឋាន[៥៤]លមើល ។ លោកសេនាបតីនឹកស្មានថា ការធ្វើបែបនោះនឹងញ៉ាំងឲ្យព្រះរាជធីតាគាប់ព្រះទ័យ ដូច្នេះហើយក៏រត់យ៉ាងពេញទំហឹងក្នុងមហាតលដ្ឋាននោះ ។ ព្រះនាងឃើញដូច្នោះ ក៏ចេះតែបញ្ឆោតថា ៖

"លោកសេនាបតីអញ្ជើញរត់មកណេះ លោកសេនាបតីអញ្ជើញរត់ទៅណោះវិញ" ។

លោកសេនាបតី ក៏ចេះតែរត់មកណេះផង ទៅណោះផង តាមតែព្រះនាងបញ្ជា ដោយប្រឹងយ៉ាងពេញទំហឹង ។ ព្រះរាជធីតាយល់ថា លោកសេនាបតីវល្ងក:នេះ គ្មានភាពអង់អាចក្លាហានអ្វីបន្តិចទាល់តែសោះ ។ លុះព្រះនាងយល់ដូច្នេះហើយ ក៏ហៅថា ៖

"មកណេះ បងសម្លាញ់ សូមច្របាច់ជើងឲ្យខ្ញុំបន្តិច" ។

ដើម្បីញ៉ាំងព្រះរាជធីតាឲ្យត្រេកអរ សេនាបតីនោះមកអង្គុយច្របាច់ជើងព្រះនាង ។ ស្រាប់តែព្រះនាងធាក់មួយជើងចំកណ្ដាលដើមទ្រូងរបស់លោកសេនាបតី បណ្ដាលឲ្យគាត់ផ្ងារពោះប្រចាំងផ្ងាកទៅក្រោយ ព្រះនាងក៏ឲ្យសញ្ញាដល់ពពួកទាសីថា ៖

"ហ៏ពួកនាង ចូរនាំគ្នាសំពងអាប្រុសអន្ធពាល[៥៥]កំសាកនេះទាញ-កវាអូសចេញទៅ" ។

[៥៤] សាលប្រជុំធំ, ព្រះរាជមន្ទីរក្នុងព្រះបរមរាជវាំង ។

[៥៥] លូងផងផឹតសូន្យឈឹង (ដូចមនុស្សខ្វាក់) : ជនអន្ធពាល ។

ពេលសេនាបតីមកដល់ខាងក្រៅ ត្រូវនាហ្មឺនមន្ត្រីផងគ្នាសួរថា ៖

"តើមានរឿងអ្វីកើតឡើង សេនាបតី ?"

"កុំដេញដោល, រាជធីតានុ៎ះជាយក្ខិនី[៥៦] មិនមែនមនុស្សស្រីធម្មតាទេវ៉ុយ" សេនាបតីប្រាប់ ។

បន្ទាប់មក អ្នកកាន់ឃ្លាំងទៅម្តង, ក៏ត្រូវព្រះរាជធីតាធ្វើឲ្យអាម៉ាស់មុខដូច្នោះដែរ ។ បន្ទាប់មក លោកសេដ្ឋី, មន្ត្រីកាន់ស្វេតច្ឆត្រ, មន្ត្រីកាន់ព្រះខាន់, មន្ត្រីទាំងអស់នេះ សុទ្ធសឹងតែត្រូវព្រះរាជធីតាធ្វើឲ្យអាម៉ាស់មុខគ្រប់ ៗ គ្នា មានទំនងដូចសេនាបតីអ៊ីចឹងដែរ ។

## ពិធីផ្សងបុស្សរថ[៥៧]

គ្រានោះ អាមាត្យទាំងឡាយ ជួបជុំពិភាក្សាគ្នាថា ៖

"បុគ្គលដែលមានសមត្ថភាពញុំាងព្រះរាជធីតាឲ្យត្រេកអរ រកពុំបានទេ, យើងនឹងឲ្យរាជ្យដល់បុគ្គលណាដែលមានសមត្ថភាពលើកសហស្សថាមធ្នូបាន" ។

---

[៥៦] ស្រីយក្ស, យក្សស្រី (ព. កា. ប្រើជា យក្សី ក៏បាន) ។

[៥៧] រថ-ស សម្រាប់ជិះរំហើយកំសាន្តចិត្ត ។ តាមរឿងតំណាលក្នុងគម្ពីរជាតកច្រើនអធិប្បាយថា រថមានបុស្បុកពណ៌សដែលទឹមសេះឲ្យអួសដើរជាមុន, ពួកសេនាបតីមន្ត្រីធំតូចទាំងអស់នាំគ្នាដើរអមហែហមតាមក្រោយ, ផ្សងរកអ្នកមានបុណ្យកព្វអស្ចារ្យដែលគួរទទួលឋានៈជាក្សត្រិយ៍ទ្រង់រាជ្យបាន, ក្នុងកាលដែលផុតគ្មានព្រះរាជវង្សសោះ ឬមានតែព្រះរាជបុត្រីដែលនឹងមិនគួរទទួលរាជ្យបាន ...ហៅថា ផ្សងបុស្សរថ ។

សហស្សថាមផ្ទះនោះ ក៏រកអ្នកណាមួយដែលមានសមត្ថភាពលើករួច ពុំបានដែរ ។

បន្ទាប់មក ពួកអាមាត្យប្រឹក្សាគ្នាថានឹងឲ្យរាជ្យដល់បុគ្គលណា ដែលដឹងក្បាលដំណេកនៃបល្ល័ង្កជ្រុង ៤ ហើយក៏គ្មាននរណាដឹងអំពី ក្បាលដំណេកនោះសោះ ។

បន្ទាប់មក ពួកអាមាត្យប្រឹក្សាគ្នាថានឹងឲ្យរាជ្យដល់បុគ្គលដែល មានសមត្ថភាពរកឃើញនូវមហាកំណប់ ១៦ ហើយក៏គ្មាននរណាមួយ ដែលមានសមត្ថភាពរកកំណប់ទាំងនោះបានសោះ ។

បន្ទាប់មក ពួកអាមាត្យប្រឹក្សាគ្នាថា ៖

"ម្នាលគ្នាយើងអើយ, ដែនដីអត់ស្ដេច មិនអាចនៅគង់វង្សបាន ទេ, យើងត្រូវធ្វើដូចម្ដេចតទៅទៀតហ្ន៎ ?"

គ្រានោះ លោកបុរោហិត[៥៨]ប្រាប់អាមាត្យទាំងនោះថា ៖

"បពិត្រអស់លោក សូមអស់លោកកុំគិតខ្វល់ឡើយ គួរណាស់ តែយើងប្រើវិធីរថបុស្សក ដើម្បីផ្សងរកអ្នកមានបុណ្យដែលមាន សមត្ថភាពគ្រប់គ្រងរាជ្យទូទាំងជម្ពូទ្វីប យើងនឹងទទួលបាន

[៥៨] ព្រាហ្មណ៍អ្នកបំពេញប្រយោជន៍ដល់បុរី ឬអ្នកធ្វើនូវសេចក្ដីទំនុកបម្រុងដល់នគរ គឺព្រាហ្មណ៍ដែលជារាជគ្រូ ឬព្រាហ្មណ៍ជាអ្នកចាត់ការធ្វើយញ្ញពិធីក្នុងរាជត្រកូល តាមលទ្ធិព្រាហ្មណ៍ ។ ប្រើក្លាយឃ្លាតជា បរោហិត (ប-រ៉ោហិត) ក៏មាន, គួរប្រើ បុរោហិត វិញ ។

ស្ដេចដែលមានសមត្ថភាពតាមបំណងប្រាថ្នាពុំខានឡើយ” ។ ពួកនាហ្មឺនសព្វមុខមន្ត្រីទាំងអស់យល់ស្របតាមយោបល់របស់លោកបុរោហិត រួចបានឲ្យគេរៀបចំតុបតែងលម្អនគរ ទីមសេះមានសម្បុរដូចផ្កាកុមុទ ៤ នឹងរថមង្គលដែលក្រាលដោយកម្រាលដ៏ល្អវិចិត្រលើកគ្រឿងកកុធភណ្ឌ[៥៩] ទាំង ៥ មកដាក់លើរថ មានទាំងក្រុមចតុរង្គ-សេនា ចោមរោមហែហមជាបរិវារ ។ ពួកគេបានរៀបឲ្យក្រុមតន្ត្រីករ

---

[៥៩] គ្រឿងប្រដាប់សម្រាប់រាជ្យ ឬគ្រឿងឥស្សរិយយសសម្រាប់ក្សត្រិយ៍ទ្រង់រាជ្យមាន ៥ យ៉ាងគឺ មកុដ ១, ព្រះខ័ន (ព្រះខ័ឌ្គ) ១, ស្វេតច្ឆត្រ ១, សុពណ៌បាទុកា ១ និងវាលវីជនី ១; មានន័យមួយផ្សេងថា មកុដ ១, ព្រះខ័ន (ព្រះខ័ឌ្គ) ១, សុពណ៌បាទុកា ១, ព្រះទណ្ឌៈ ១ និងចាមរ ១ ។ នៅក្នុងអបណ្ណកជាតកថែងថា ***ឯវំ ចតស្សោ ទិសា, ចតស្សោ អនុទិសា, ហេដ្ឋា, ឧបរីតិ ទស ទិសា អនុវិលោកេត្វា អត្តនា សទិសំ កញ្ចិ អទិស្វា - “អយំ ឧត្តរាទិសា”តិ សត្តបទវីតិហារេន អគមាសិ, មហាព្រហ្មុនា សេតច្ឆត្តំ ធារិយមានោ, សុយាមេន វាឡពីជនឹ, អញ្ញាហិ ច ទេវតាហិ សេសរាជកកុធភណ្ឌហត្ថាហិ អនុគម្មមា-នោ ។ តតោ សត្តមបទេ ឋិតោ “អគ្គោហមស្មិ លោកស្សា”តិអាទិកំ អាសភឹ វាចំ និច្ឆារេន្តោ សីហនាទំ នទិ*** ។ ព្រះរាជកុមារប្រមើលមើលទិសទាំង ១០ គឺ ទិសធំ ៤ ទិសតូច ៤ ទិសខាងក្រោម ១ ទិសខាងលើ ១ ។ កាលមិនឃើញនរណាម្នាក់ស្មើនឹងខ្លួន ព្រះរាជកុមារកំណត់ថា “នេះជាទិសខាងជើង” ហើយយាងទៅបាន ៧ ជំហាន ។ មហាព្រហ្មបាំងស្វេតច្ឆត្រថ្វាយ ចំណែកសុយាមទេវបុត្របក់ផ្ចិតវាលវីជនីថ្វាយ ទេវតាដទៃ ៗ ទៀតកាន់គ្រឿងប្រដាប់រាជ្យផ្សេង ៗ ដើរទៅតាម ។ ព្រះរាជកុមារឈប់យាងក្នុងជំហានទី ៧ ហើយបន្លឺសូរសីហនាទជាអាសភិវាចាថា “យើងជាកំពូល គឺជាអ្នកប្រសើរជាងគេក្នុងលោក” ដូច្នេះ ជាដើម ។

មួយវង់ប្រគំពីខាងមុខបង្អស់ និងមួយក្រុមទៀតប្រគំពីខាងក្រោយបង្អស់នៃក្បួនដង្ហែ ។ រីឯនឹមរថនិងជន្ទញវិញ បានប្រដាប់ទៅដោយមាស ពួកអាមាត្យបានផ្តាំថា ៖

"សូមអ្នកភ្លេង គប្បីប្រគំតន្ត្រីទាំងអស់តាមពីក្រោយ" ហើយក៏ព្រលេងរថបុស្សរកឲ្យចេញដំណើរទៅ ដោយផ្សងថា ៖

"បុគ្គលណាមានបុណ្យសោយរាជ្យបាន ចូរទៅកាន់សម្នាក់របស់បុគ្គលនោះចុះ" ។

គ្រានោះ រថបុស្សរកដើរប្រទក្សិណ[៦០]រាជវាំងហើយបានឡើងទៅរកមហាវិថីយ៉ាងលឿន ។

## បុស្សរថចូលទៅរកមហាជនក

ពួកមន្ត្រីនាហ្មឺនទាំងឡាយ មានសេនាបតីជាដើម ម្នាក់ ៗ គិតថា "សូមឲ្យរថបុស្សរកដើរសំដៅមករកលំនៅឋានខ្លួន រៀងរាល់អាត្មា" ។ ប៉ុន្តែមិនដូច្នោះឡើយ រថបុស្សរកបានដើរហួសពីផ្ទះរបស់អស់លោកមន្ត្រីទាំងអស់នោះ រួចដើរប្រទក្សិណនគរ ចេញទៅតាមទ្វារខាងកើត

[៦០] (ន.) (សំ.), (បា.) (ប្រទ័ក-សិន) (បទក្ខិណា) ការសម្តែងសេចក្តីគោរពឬសេចក្តីស្រឡាញ់ដោយដើរពទ្ធជុំវិញបុគ្គលឬវត្ថុអ្វី ៗ ឲ្យបុគ្គលឬវត្ថុនោះនៅជាខាងស្តាំដៃ : ធ្វើប្រទក្សិណវិហារ ៣ ជុំ...។ ប្រើជា កិ. វិ. ក៏បាន : ដើរប្រទក្សិណ; កាលដែលជូជកគាត់រៀបនឹងចេញពីផ្ទះគាត់បានដើរប្រទក្សិណផ្ទះនិងនាងអមិតតាបនាបី ៗ ជុំហើយទើបគាត់ចេញទៅ... ។

ដើរឆ្ពោះមុខទៅរកឧទ្យាន ។ កាលបើឃើញបុស្បុកដើរតម្រង់ទៅឧទ្យានលឿនដូច្នោះ ពួកអាមាត្យប្រាប់គេឲ្យបំបែរមកវិញ ។ លោកបុរោហិតស្រែកជំទាស់ថា ៖

"កុំបំបែរ, ទុកឲ្យវាទៅតាមដំណើរចម្ងាយប្រមាណ ១០០ យោជន៍សិន, កុំអាលរារាំងវាអី" ។

រថបុស្បុកចូលទៅកាន់ឧទ្យាន ដើរប្រទក្សិណផ្ទាំងមង្គលសិលា[៦១] លុះបានរៀបរយហើយវាក៏ឈប់នៅមួយកន្លែង ។ បុរោហិតមើលឃើញព្រះមហាសត្វកំពុងផ្ទំនៅទីនោះ ក៏ហៅអស់ពួកអាមាត្យមកប្រាប់ថា ៖

"អស់លោក ! អស់លោកឃើញទេ បុរសម្នាក់កំពុងដេកលើផ្ទាំងថ្មមង្គលសិលា មានពិតប្រាកដមែន, ប៉ុន្តែប្រាជ្ញារបស់គេអាចសមគួរដល់ស្វេតច្ឆត្រដែរឬក៏អត់នោះ យើងនៅមិនទាន់ដឹងបាននៅឡើយទេ, ប្រសិនបើបុរសនេះប្រាកដជាក់ជាមនុស្សមានបុណ្យវាសនា[៦២]ខ្ពស់មែននោះ គេនឹងមិនក្រឡេកមើលយើងឡើយ, តែបើជាមនុស្សកាឡកណ្ណី[៦៣]វិញនោះ ប្រាកដជានឹងងើបក្រោក

---

[៦១] ផ្ទាំងថ្មជាមង្គល, ផ្ទាំងថ្មដ៏មានសិរីសួស្តី ។

[៦២] អំពើល្អដែលបានធ្វើទុកពីព្រេងនាយ, -ពីបុព្វជាតិ ដែលនាំឲ្យមានព្រេងសំណាងជួបប្រទះរឿងល្អ ៗ ក្នុងបច្ចុប្បន្ន ។

[៦៣] បា.; សំ. កាល-កាន់-ណី, (ន.) (កាលក្ណ្ណី) < កាឡ + ករ៍-ធា.+ ណ្បី-ប. ។ វិ. **អត្តនោ និស្សយំ កាឡវណ្ណសទិសំ ករោតិ អប្បកាសកត្តាតិ > កាឡកណ្ណី** មនុស្សធ្វើនូវនិស្ស័យ-

សស្វន់សស្មោ សម្ទឹងមើលញ៉ូវខ្លួនទទ្រើកមិនខាន, ព្រោះដូច្នោះអស់លោកខាងក្មេង ចូរប្រញាប់ប្រញាល់ដេញដំប្រគុំកូតតូរ្យ-តន្ត្រីគ្រប់យ៉ាង" ។

វំពេចនោះឯង តន្ត្រីរាប់រយវង់ ត្រូវបានក្រុមតន្ត្រីករប្រគុំឡើងរួមគ្នា ឮសូរពីរោះរងំរណ្ដំលាន់ឮទ្រហឹង ប្រៀបដូចជាសំឡេងរលកបោកបក់នៃមហាសាគរ[៦៤] ដូច្នោះឯង ។

---

នៃខ្លួនឲ្យប្រាកដស្មើដោយវត្ថុពណ៌ខ្មៅ ហៅថា កាឡកណ្ណី គឺមនុស្សឥតបុណ្យ, មនុស្សចង្រៃ, មនុស្សចិត្តខ្មៅ : ស្រីកាឡកណ្ណី គឺស្រីចិត្តខ្មៅ, ស្រីចង្រៃ : មេស្រីកាឡកណ្ណី, មនុស្សកាឡកណ្ណី ។ **សិរី ច កាឡកណ្ណី ច ន សមេន្តិ កុទាចនំ** ក្នុងកាលណាក៏ដោយ មនុស្សមានសិរីសួស្ដី និងមនុស្សកាឡកណ្ណី មិនស៊ីសង្វាក់គ្នាឡើយ ។

[៦៤] (ន.) (សំ.),(បា.) សមុទ្រ ។ មានសេចក្ដីតំណាលក្នុងរឿងរាមាយណៈថា សមុទ្របានជាហៅ សាគរ ព្រោះកើតអំពីពួកព្រះរាជបុត្ររបស់ព្រះបាទ សគរៈ កែនពលឲ្យជីក ។ ព. កា. សាគរា, សាគរេស, សាគរោ សមុទ្រ ។ សាគរេ ក្នុងសមុទ្រ ។

# ជំពូកទី ៣

# មហាជនកឡើងគ្រងរាជ្យនៅក្រុងមិថិលា

## ពិធីអភិសេកព្រះមហាជនករាជា

*ពេលនោះ ព្រះមហាសត្តទ្រង់ភ្ញាក់ពីដំណេកឡើងដោយសារសំឡេងនោះ បើកមុខអើតមើល ឃើញនូវមហាជនជួបជុំគ្នាមីរដេរដាសដូច្នោះ ក៏នឹកគិតថា "ស្វេតច្ឆត្រនេះ ប្រាកដជាមករកអញច្បាស់ណាស់" ។ លុះគិតដូច្នេះហើយ ក៏យកសំពត់ឃ្លុំមុខវិញ ប្រែខ្លួនដេកផ្អៀងទៅខាងឆ្វេងម្តង ។ បុរោហិត បើកជើងមហាជនកកុមារពិនិត្យមើល ក៏ឃើញនូវចំណុចគួរឲ្យកត់សម្គាល់ជាច្រើនថា ៖*

*"កុំថាឡើយទ្វីប[៦៥] ១ សូម្បីមហាទ្វីបទាំង ៤ ក៏បុរសនេះមានសមត្ថភាពពេញលេញក្នុងការគ្រប់គ្រងបានដែរ"*

---

*[៦៥] ប្រទេសដែលឋិតជាក់ស្តែងក្នុងកណ្តាលទឹក (កោះ) ។ ទ្វីបធំ ៗ ហៅថា មហាទ្វីបមាន ៤ គឺ ៖ ១- បុព្វវិទេហទ្វីប គឺទ្វីបរបស់ពួកមនុស្សអ្នកវិទេហ: នៅទិសខាងកើត; ២- ជម្ពូទ្វីប គឺទ្វីបរបស់មនុស្សខាងជម្ពូ ដែលនៅទិសខាងត្បូង គឺជាទ្វីបដែលរុងរឿងត្រដែតត្រដឹម ដែលកំណត់ហៅដោយផ្អែកទៅតាមឈ្មោះដើមជម្ពូធំមួយជាគោលដុះនៅនាភ្នំសុមេរុ (បា. ភ្នំសិនេរុ) ។ កាលពីសម័យបុរាណ លោកសំដៅចំពោះត្រង់មជ្ឈិមប្រទេស គឺប្រទេសឥណ្ឌាទាំងមូល ហៅថា ជម្ពូទ្វីប ។ ជាកន្លែងដែលសមគួរដល់ការត្រាស់ដឹងរបស់ព្រះពុទ្ធទាំងឡាយ; ៣- អបរគោយានទ្វីប គឺជាទ្វីបដែលនៅទិសខាងលិចភ្នំសិនេរុ; ៤- ឧត្តរកុរុទ្វីប គឺទ្វីបដែលនៅទិសភាគខាងជើងភ្នំព្រះសិនេរុ ។*

ដូច្នេះហើយ បុរោហិតក៏អញ្ជើញអស់ក្រុមតន្ត្រីករឲ្យប្រគំតន្ត្រីគ្រប់មុខមួយសាទៀត ។ គ្រានោះ ព្រះមហាសត្តបើកមុខ ប្រែខ្លួនដេកផ្អៀងទៅខាងស្តាំវិញ ហើយចោលភ្នែកមើលមហាជន ទាំងមានអាការនៅដេកដដែល ។ ពេលនោះ បុរោហិតអញ្ជើញបរិស័ទ[៦៦] ឲ្យថយក្រោយបន្តិច រួចខ្លួនគាត់ផ្គងអញ្ជលី[៦៧] បន្ទន់ខ្លួនពោលថា ៖

---

មហាទ្វីបទាំង ៤ នេះ មានទីតាំងនៅជុំវិញភ្នំសិនេរុ ដែលជាស្នូលនៃផែនដី ពោលគឺទ្វីបនៅគ្រប់ទិសធំទាំង ៤ ។ ទ្វីបទាំងអស់នោះមានការបរិវត្តខុស ៗ គ្នា ដូចជាមនុស្សដែលរស់នៅខាងជម្ពូទ្វីបមនុស្សមានផ្ទៃពោះ ចំនួន ៩ ខែ ១០ ថ្ងៃ ទើបកើត ។ ចំណែកនៅទ្វីបបីទៀតមនុស្សពពោះតែ ៧ ថ្ងៃប៉ុណ្ណោះ ក៏ប្រសូតបុត្រធីតាហើយរយៈពេល ៧ ថ្ងៃក៏ធំពេញវ័យ ។ តាមលទ្ធិសព្វថ្ងៃនេះ ថាមហាទ្វីបចាស់គឺទ្វីប ដែលគេស្គាល់ជាក់មកជាយូរហើយមាន ៣ គឺទ្វីបអាស៊ី ទ្វីបអឺរ៉ុប និងទ្វីបអាហ្វ្រិក ។ មហាទ្វីបថ្មីគឺគេទើបតែរកឃើញហើយស្គាល់ក្នុងសម័យក្រោយមកទៀតមាន ២ ទៀតគឺ ទ្វីបអាមេរិក និងទ្វីបអូសេអានី រួមទាំងទ្វីបចាស់និងទ្វីបថ្មីមាន ៥ ។

[៦៦] (សំ.),(បា.) (បរិស័ត) (បរិបទិ; បរិសា) ពួកជនដែលប្រជុំគ្នា : ថ្ងៃនេះ មានបរិស័ទមកជួបជុំច្រើនគ្នា ។ ពួកជនដែលស្ម័គ្រចិត្តរួមគំនិតធ្វើការរបរចូលគ្នា, ក្រុមហ៊ុន, សមាគម : បរិស័ទសាមគ្គីមិត្ត...។ ភិក្ខុសាម័ញ្ញធម្មតាក្រៅពីលោកចៅអធិការនិងសាមណេរ ក៏ហៅថា បរិស័ទ ដែរ (អ. ថ. ប-ស័ត) : ក្នុងវត្តនេះមានលោកបរិស័ទ ៥០ អង្គ ។ សរសេរជា បរិសទ្យ ដូច្នេះក៏បាន ។

[៦៧] (ន.) (បា.),(សំ.) (អ័ញ-ជៈ--) (អញ្ជលិ ឬប្រើជា អញ្ជលី ក៏មាន) ក្រពុំម្រាមដៃ (ទាំង ១០), ការផ្គុំម្រាមដៃទាំង ១០ គោរព : ប្រណម្យអញ្ជលី, លើកកំបង់អញ្ជលីប្រណម្យ (ពាក្យកាព្យប្រើក្លាយកាត់ខ្លីត្រឹមតែ ជុលី ក៏មាន : ប្រណម្យជុលី ដាក់លើសិរសី...។

"សូមស្តេចតើន[៦៨] ក្រោកឡើង ព្រះសម្មតិទេព, រាជសម្បត្តិមកដល់ព្រះអង្គហើយ" ។

គ្រានោះ ព្រះមហាសត្តសួរបុរោហិតថា ៖

"ចុះព្រះរាជារបស់ពួកលោកយាងទៅឯណា ?"

"ព្រះរាជារបស់ពួកទូលព្រះបង្គំ ទ្រង់សោយទិវង្គតហើយ ក្រាបទូល" បុរោហិតក្រាបទូល ។

"ចុះរាជបុត្រឬបងប្អូនប្រុសនៃស្តេចអង្គនោះ មិនមានទេឬ ?" ព្រះមហាសត្តសួរ ។

"មិនមានទេ ព្រះសម្មតិទេព" បុរោហិតទូលតប ។

ព្រះមហាសត្តទ្រង់ឮដូច្នោះ ក៏ពោលគាថាថា ៖

"បើដូច្នោះ ជាការប្រពៃណាស់ ខ្ញុំនឹងឡើងគ្រងរាជ្យ" ។

លុះទ្រង់មានបន្ទូលដូច្នេះហើយ មហាជនកបត់ព្រះភ្នែនពេនព្រះបាទគង់ប្រថាប់លើផ្ទាំងថ្មមង្គលសិលា ។ អស់លោកអាមាត្យ នាហ្មឺនសព្វ

---

អញ្ជលិកម្ម ឬ --ករ ការធ្វើអញ្ជលី គឺការលើកក្រពុំម្រាមដៃទាំង ១០ សំពះគោរព ។ អញ្ជលិករណីយ (--ក:រ៉:ណី) បុគ្គលដែលគួរឲ្យលើកអញ្ជលីសំពះគោរព (បុគ្គលដែលគួរឲ្យគេចង់សំពះ) : អរិយបុគ្គលជាអញ្ជលិករណីយ ។ល។

[៦៨] (ន.) (ស.) ភ្ជាក់ពីដេក ខ្មែរយើងប្រើចំពោះតែ រ. ស. និង ស. ស. : ព្រះករុណាទ្រង់តើនហើយ; លោកគ្រូតើនហើយ ។

មុខមន្ត្រី ក៏បានរៀបចំពិធីអភិសេក[៦៩] ព្រះមហាជនកនៅទីនោះឯង ។ មហាជនក ក៏បានឡើងទៅជាស្ដេចផែនដី មានព្រះនាមប្រាកដថា **មហាជនករាជា** ឬ **ព្រះបាទមហាជនក** ។

ក្រោយពីឡើងឋានៈជាស្ដេចហើយ មហាជនករាជាឡើងគង់លើរាជរថបុស្សកដ៏បវរចូលទៅកាន់នគរដោយសិរីរាជសម្បត្តិ[៧០] ដ៏ធំ មុននឹងយាងឡើងទៅរាជនិវេសន៍ ទ្រង់ពិចារណាថា ៖

"មន្ត្រីទាំងឡាយមានសេនាបតីជាដើម
ចូរបាននូវឋានៈនេះ នូវឋានៈនោះ"

ដូច្នេះហើយ ទើបទ្រង់យាងឡើងទៅមហាតលដ្ឋាន ។

## សីវលីទេវីសាកល្បងស្ដេចមហាជនក

ចំណែករាជធីតាវិញ ហេតុតែចង់សាកល្បងស្ដេចមហាជនក

---

[៦៩] (ន.) (បា.),(សំ.) (អៈភិសែក) (អភិសេក) ការស្រោចទឹកក្ងស់ទឹកសង្ខ (លើព្រះសិរ្ស៍លោកអ្នកមានបុញ្ញាភិនីហារ) សន្មតឲ្យឡើងពេញទីជាក្សត្រិយ៍ទ្រង់រាជ្យ ។ ការប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរថ្វាយពរថ្វាយជ័យចំពោះព្រះពុទ្ធរូបដែលកសាងថ្មី ក៏ហៅ អភិសេក ដែរ : អភិសេកព្រះ (ធ្វើតាមដំណើររឿង កាលដែលព្រះសក្យមុនីគោតម ទ្រង់បានត្រាស់ជាព្រះពុទ្ធរួចស្រេចហើយ, ក្នុងវេលាភ្លាម ៗ នោះ, ពួកទេវតានាំគ្នាមកប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរទិព្វថ្វាយពរសព្ទសាធុការថា "ព្រះពុទ្ធឈ្នះមារហើយ ! មារមានចិត្តបាបចាញ់ព្រះអង្គហើយ !" ។ ពាក្យ អភិសេក នេះខ្មែរប្រើជា ភិ. ក៏មាន ។

[៧០] រាជសម្បត្តិដ៏មានសិរី, សម្បត្តិសម្រាប់ស្ដេចទ្រង់រាជ្យ ។

តាមលម្អានមុន ៗ ដែលខ្លួនធ្លាប់សាក ក៏ប្រើបុរសម្នាក់ថា ៖

"នែអ្នក, អ្នកចូរទៅគាល់ព្រះរាជា ក្រាបទូលព្រះអង្គយ៉ាងនេះ ថា 'បពិត្រព្រះសម្មតិទេព រាជធីតាសីវលីទេវីសូមយាងព្រះអង្គ ទៅកាន់សម្នាក់របស់ព្រះនាងជាប្រញាប់' ។

អ្នកបម្រើនោះបានទទួលព្រះសវនីយ៍ ហើយទៅក្រាបទូលព្រះបាទមហា-ជនកឲ្យស្ដេចយាងទៅជួបព្រះរាជធីតា ។ ចំណែកស្ដេចមហាជនក ទ្រង់ធ្វាតយល់ហេតុការណ៍ ទោះបីព្រះអង្គបានឮពាក្យរបស់អ្នកបម្រើក្រាបទូលយ៉ាងនោះក៏ដោយ តែទ្រង់ធ្វើដូចជាពុំឮអ្វីសោះ បែរជាមានព្រះរាជឱង្ការ[៧១] សរសើរដល់ប្រាសាទឯណោះទៅវិញថា ៖

"ឱះឱ ! ប្រាសាទនេះមានសោភណភាព[៧២]អ្វីម៉្លេះហ្ន៎" ។

អ្នកបម្រើទាល់តម្រិះមិនអាចយាងព្រះអង្គបាន ក៏ត្រឡប់ទៅរាយការណ៍ដល់ព្រះរាជធីតាតាមដំណើរហេតុវិញថា ៖

"បពិត្រព្រះនាងម្ចាស់, ព្រះរាជាទ្រង់ពុំឮព្រះសវនីយ៍[៧៣]របស់ព្រះនាងទេ ទ្រង់បែរជាពោលសរសើរអំពីប្រាសាទឯណោះវិញ,

---

[៧១] សម្ដីក្សត្រទ្រង់រាជ្យ ។ តាមច្បាប់រាជសព្ទខ្មែរថា សំបុត្ររបស់ម្ចាស់ផែនដីចេញឲ្យប្រជារាស្ត្រដឹងគ្រប់គ្នាទូទៅ ហៅថា ព្រះរាជឱង្ការនូវព្រះបន្ទូលសូរសីហនាទ ។

[៧២] ភាពប្រសើរក្រៃលែង ភាពល្អកន្ទង់ ។

ព្រះសវនីយ៍របស់ព្រះនាង ហាក់ដូចជាដើមស្មៅទៅវិញទេ ទ្រង់ពុំយកព្រះទ័យទុកដាក់ទាល់តែសោះ" ។

ព្រះរាជធីតាឮពាក្យអ្នកបម្រើប្រាប់ ទ្រង់មានព្រះចិន្តាថា ៖

"យីអើ ! បុរសនោះ អីក៏ថ្មើមធំពាសមេឃម្ល៉េះ"

ហើយក៏បញ្ជូនអ្នកបម្រើឲ្យទៅក្រាបទូលម្ដងទៀត ជា ២ លើក, ជា ៣ លើក ។ ម្ដងនេះ ទើបព្រះរាជាទ្រង់យាងឡើងប្រាសាទ ដោយដំណើរប្រក្រតីតាមសេចក្ដីគាប់ព្រះទ័យរបស់ព្រះអង្គ មើលទៅហាក់ដូចជារាជសីហ៍[៧៤] កំពុងតែក្រោកក្រឡាខ្លួនលោតឡើងទៅលើយ៉ាងអង់អាច

---

[៧៣] ដែលគួរស្ដាប់, ដែលត្រូវស្ដាប់ ។ ន. សម្ដីដែលគួរឬត្រូវស្ដាប់ ។ ខ្មែរប្រើជា រ. ស. ចំពោះតែព្រះបន្ទូលរបស់សម្ដេចព្រះវររាជជននី ឬសម្ដេចព្រះអគ្គមហេសី, សម្ដេចព្រះមហាក្សត្រិយានី : ទទួលព្រះសវនីយ៍ ។

[៧៤] សត្វចតុប្បាទពួកមួយជាម្រឹគមានអំណាចអង់អាច ។ ក្នុងគម្ពីរពុទ្ធសាសនាថា សីហ: មាន ៤ ប្រភេទគឺ ១- តិណសីហ: សីហ:មានសម្បុរប្រផេះ ស៊ីតិណជាតិជាអាហារ; ២- កាឡសីហ: សីហ:មានសម្បុរខ្មៅស៊ីតិណជាតិជាអាហារដែរ; ៣- បណ្ឌុសីហ: សីហ:មានសម្បុរលឿងចាស់ (សម្បុរត្នោត) ស៊ីសាច់សត្វជាអាហារ; ៤- កេសរសីហ: សីហ:មានកេសរ គឺត្រង់កមានសំណុំរោមសម្បុរក្រហម, មានឆ្នូតក្រហម៣ ស្រស់ក្រឡាញពីត្រឹមក្បាលកាត់ចំមកលើខ្នង គឺឆ្នូតមួយកណ្ដាលបង្ហូតត្រង់ចុះតាមខ្នងដង់កន្ទុយ ឆ្នូតពីរសង់ខាងផាកចុះតាមកៀនត្រគាកទាំងពីរ (ម្ខាងមួយ) វិលវៀនពទ្ធជាទក្ខិណាពត៌, ត្រង់មុខនិងចុងជើងទាំងបួននិងចុងកន្ទុយមានសម្បុរក្រហមស្រស់, សរីរប្រទេស ក្រៅពីនោះមានសម្បុរ-សដូចសម្បុរខ្យង់ស័ង្ខដែលខាត់, ស៊ីសាច់

ក្លាហាន កាលបើស្តេចមហាជនក កំពុងតែបោះជំហានឈានមួយ ៗ យាងចូលទៅរក, ព្រះរាជធីតាគ្រាន់តែបានទតឃើញភ្លាម ទ្រង់ពុំអាចទប់ទល់តម្កល់អាត្មាឲ្យមានជំហររឹងប៉ឹងបានឡើយ ព្រះនាងទ្រង់ញ័រព្រះកាយទទ្រើក ដោយអំណាចតេជៈនៃព្រះមហាក្សត្រទ្រង់រាជ្យ ព្រះនាងក៏យាងមកទទួល ហើយហុចព្រះហស្តថ្វាយព្រះមហាក្សត្រទ្រង់តោងចាប់ ខណៈដែលទ្រង់យាងឡើងជិតផុតកាំជណ្តើរ ។

## ព្រះបាទមហាជនកបង្ហាញសមត្ថភាពសោយរាជ្យ

ស្តេចមហាជនកតោងចាប់ហត្ថារបស់រាជធីតាសីវលី ហើយទ្រង់យាងឡើងកាន់មហាតលដ្ឋាន ប្រថាប់គង់លើរាជបល្ល័ង្ក ដែលបាំងដោយព្រះស្វេតច្ឆត្រ ។ ភ្លាមនោះ ព្រះអង្គហៅអស់នាហ្មឺនសព្វមុខមន្ត្រីមកសាកសួរថា ៖

"ហៃអស់លោក, ព្រះមហាក្សត្ររបស់អស់លោក មុននឹងសោយទិវង្គត មានបានផ្តល់ឱវាទ ឬរាជបណ្តាំអ្វីខ្លះទេ ?"

ពួកមន្ត្រីក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព មានរាជបណ្តាំមួយចំនួន ក្រាបទូល" ។

មហាជនករាជាទ្រង់មានរាជតម្រាស់ថា ៖

---

សត្វជាអាហារ (ច្រើនមាននៅក្នុងហិមវន្តប្បទេស), កេសរសីហៈនេះមានអានុភាពជាងសីហៈ ៣ ប្រភេទខាងលើ; ហៅសីហរាជ ឬ រាជសីហ៍ "ស្តេចសីហៈ" ក៏បាន ។

"បើដូច្នោះ ចូរអស់លោកប្រាប់រាជបណ្ដាំនោះដល់យើង" ។

ពួកមន្ត្រីទូលថា ៖

"បពិត្រព្រះសម្មតិទេព, ស្ដេចបានផ្ដាំឲ្យពួកទូលបង្គំថ្វាយរាជា-ណាចក្រ[៧៥]ដល់ជនណាដែលមានសមត្ថភាពញ៉ាំងព្រះរាជធីតាសីវលីទេវីឲ្យគាប់ព្រះទ័យបាន" ។

ព្រះមហាសត្តតបថា ៖

"សីវលីទេវីមកហុចដៃឲ្យយើងចាប់តោងហើយទេតើ តែប៉ុណ្ណោះចាត់ថាជាការញ៉ាំងព្រះនាងឲ្យគាប់ព្រះទ័យបានហើយ, តើមានរឿងអ្វីដែលព្រះរាជាពួកអ្នកផ្ដាំទៀតទេ ?"

"មានទៀតព្រះសម្មតិទេព, ព្រះរាជាបានផ្ដាំថា ឲ្យពួកទូលបង្គំថ្វាយរាជ្យដល់នរណាដែលដឹងថាខាងណាជាក្បាលដំណេកនៃបល្ល័ង្ក[៧៦] ៤ ជ្រុង" ពួកមន្ត្រីទូល ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ៖

"ប្រស្នានេះលំបាកយល់, លុះតែប្រើឧបាយកល ទើបអាចយល់បាន" ។

---

[៧៥] អំណាចនៃព្រះរាជាដែលប្រព្រឹត្តិទៅក្នុងទីជុំវិញខេត្តដែន គឺអំណាចនៃការគ្រប់គ្រងប្រទេសមួយ ៗ ផ្សាយទៅជុំវិញប្រទេសនោះរបស់ព្រះអង្គ អាណាចក្រជាភារៈលើព្រះមហាក្សត្រ។

[៧៦] គ្រែន; ទែនសម្រាប់អង្គុយពែន; ព្រះទែនសម្រាប់ព្រះពុទ្ធ ឬព្រះរាជាទ្រង់គង់ពែនព្រះបាទ ។ បល្ល័ង្ករត្ន ឬ រតនបល្ល័ង្ក បល្ល័ង្ករតនៈ គឺបល្ល័ង្កដាំត្បូង ឬបល្ល័ង្កពេជ្រ ។

លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ព្រះអង្គក៏ដកស្នៀតសក់មាសអំពីព្រះកេសា ហុចទៅព្រះហស្តរបស់ព្រះនាងសីវលីទេវី បង្គាប់ឲ្យទុកស្នៀតសក់នោះលើបល្ល័ង្ក ៤ ជ្រុង ។ ព្រះនាងក៏ទទួលស្នៀតសក់នោះ យកទៅទុកលើក្បាលដំណេកនៃបល្ល័ង្ក ។ ស្តេចមហាជនកទ្រង់យល់បានតាមសញ្ញានោះថា "ឱ! ខាងនុ៎ះឯងទេតើជាក្បាលដំណេកនៃបល្ល័ង្ក" ទ្រង់ធ្វើដូចជាស្តាប់ពុំឮនូវសម្តីរបស់ពួកអាមាត្យ ទ្រង់ធ្វើជាសួរបញ្ជាក់ម្តងទៀតថា "អស់លោកនិយាយថាម៉េច ?" កាលបើពួកអាមាត្យក្រាបទូលអំពីប្រស្នានោះម្តងទៀត ទ្រង់ក៏ចង្អុលបង្ហាញភ្លាម ៗ ថា ៖

> "នុ៎ះជាក្បាលដំណេកនៃបល្ល័ង្ក, ប្រស្នានេះមិនលំបាកយល់ទាល់តែសោះ, ហើយចុះមានរឿងអ្វីដែលត្រូវប្រាប់យើងទៀតទេ ចូរនិយាយមកចុះ ?"

ពួកមន្ត្រីក្រាបទូលថា ៖

> "បពិត្រព្រះសម្មតិទេព ព្រះរាជាទ្រង់បានផ្តាំពួកទូលព្រះបង្គំថាឲ្យរាជសម្បត្តិដល់ជនណាដែលមានសមត្ថភាព លើកសហស្សថាមធ្នូបាន" ។

ស្តេចមហាជនក ក៏ប្រើមនុស្ស ១.០០០ នាក់ឲ្យទៅលើកសហស្សថាមធ្នូនោះមកថ្វាយទ្រង់, លុះពួកគេលើកយកមកដល់ ព្រះអង្គប្រថាប់គង់

លើរាជបល្ល័ង្កដដែល ចាប់ធ្នូនោះលើកឡើង ហាក់ដូចជាលើកធ្នូថ្លេចកប្បាស[៧៧]របស់ពួកស្រី ៗ ហើយសួរទៀតថា ៖

"តើមានរាជបណ្តាំអ្វីផ្សេងទៀតទេ ?"

ពួកមន្ត្រីក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព ព្រះរាជាផ្តាំពួកទូលព្រះបង្គំថា ឲ្យរាជ-សម្បត្តិដល់បុគ្គលណាដែលមានសមត្ថភាពរកឃើញនូវកំណប់ទ្រព្យធំ ៗ ទាំង ១៦" ។

ព្រះបាទមហាជនកត្រាស់សួរថា ៖

"ចុះព្រះរាជារបស់ពួកលោកបានប្រាប់បញ្ជី[៧៨]សរុបនៃកំណប់ទាំងនោះខ្លះទេ ?"

ពួកមន្ត្រីទូលថា ៖

"ក្រាបទូលព្រះអង្គ ស្តេចទ្រង់មានព្រះបន្ទូលប្រាប់ដែរ" ។

ព្រះបាទមហាជនក ទ្រង់បង្គាប់ពួកមន្ត្រីឲ្យប្រាប់អំពីបញ្ជីសរុបនៃកំណប់ទ្រព្យ ។ ពួកអាមាត្យក៏ក្រាបទូលស្តេចមហាជនក នូវបញ្ជីសរុបនៃកំណប់ទ្រព្យដែលព្រះរាជាបានផ្តាំ មានកំណប់នៅត្រង់ទីព្រះអាទិត្យរះជាដើមរហូតគ្រប់ទាំង ១៦ ។

---

[៧៧] ប្រដាប់ធ្វើដោយឈើឬឫស្សី មានសណ្ឋានដូចធ្នូ សម្រាប់ថ្លេចកប្បាស ឬ សំឡី។

[៧៨] កំណត់ដែលកត់ឈ្មោះ, ដែលកត់ទ្រព្យរបស់, ដែលកត់អ្វី ៗ មានរបៀបមានចំនួន : ធ្វើបញ្ជី, ចុះបញ្ជី ។

កាលទ្រង់បានព្រះសណ្ដាប់នូវប្រស្នានោះភ្លាម អាថ៌កំបាំងនោះក៏ប្រាកដជាក់ច្បាស់ដល់ព្រះអង្គ ហាក់ដូចព្រះចន្ទពេញវង់ក្នុងថ្ងៃពេញបូណ៌មី[79] បញ្ចេញរស្មីចិញ្ចែងចិញ្ចាច[80] ឰដ៏កណ្ដាលនភាល័យ[81] ។

គ្រានោះ ពួកនាហ្មឺនសព្វមុខមន្ត្រី ដែលអង្គុយគាល់ត្រៀបត្រាបានស្ដាប់និងបានឃើញដំណោះស្រាយប្រស្នារបស់ព្រះរាជាថ្មីដូច្នោះម្នាក់ ៗ សង្ឃឹមថានឹងទទួលបានការបកស្រាយថ្មីមួយទៀត ស្រាប់តែព្រះរាជាផ្អាកការដោះស្រាយប្រស្នា ដោយទ្រង់ត្រាស់ថា ៖

"ហៃអស់លោក, មួយថ្ងៃនេះ យើងមិនមានពេលទំនេរហួតទេ, ចាំថ្ងៃស្អែកសិន សឹមយើងយកកំណាប់ទ្រព្យផ្សេង ៗ ទៀត" ។

## ព្រះបាទមហាជនកដោះប្រស្នាមហាកំណាប់ ១៦

### មហាកំណាប់ទី ១

លុះថ្ងៃបន្ទាប់ ស្ដេចមហាជនកក៏អញ្ជើញអស់មន្ត្រីនាហ្មឺនឲ្យមកជួបជុំគ្នា ក្នុងកន្លែងប្រជុំមួយ ហើយទ្រង់ត្រាស់សួរថា ៖

---

[79] តិថី ឬថ្ងៃដែលមានព្រះចន្ទពេញវង់, ថ្ងៃ ១៥ កើត : ថ្ងៃពេញបូណ៌មីខែកត្តិក ជាថ្ងៃធ្វើពិធីសំពះព្រះខែ តាមប្រពៃណីពីបុរាណកាលរៀងមក ។

[80] ត្រដែតជាក់ស្ដែង ។ បើប្រើជាពាក្យប្រៀបថា ខ្ពង់ខ្ពស់, ថ្កើងថ្កាន ។ ចិញ្ចែងចិញ្ចាច ចិញ្ចែងភ្លឺស្វាច; រុងរឿងថ្ងៃថ្លា ។

[81] (ន.) (សំ.),(បា.) (នៈភាលៃ) (នភ + អាលយ) លំនៅពពក គឺមេឃ, អាកាស : អណ្ដែតត្រសែតកណ្ដាលនភាល័យ ។

"ព្រះរាជារបស់ពួកលោក ដែលធ្លាប់និមន្តព្រះបច្ចេកពុទ្ធ[៨២]មក ឆាន់បង្ហាន់ឬទេ ?"

ពួកមន្ត្រីក្រាបទូលថា៖

"បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស[៨៣]" ។

ស្ដេចមហាជនកគិតថា ៖

"ពាក្យព្រះរាជាដែលថាព្រះអាទិត្យនោះ មិនមែនជាព្រះអាទិត្យដែលកំពុងរះដោយត្រង់នោះទេ, ព្រះអាទិត្យ ៗ នោះ បានដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ពីព្រោះព្រះបច្ចេកពុទ្ធប្រៀបបានទៅនឹងព្រះអាទិត្យ ដូច្នេះកំណប់ទ្រព្យប្រាកដជាមានក្នុងទីដែលព្រះរាជាទ្រង់ក្រោកទទួលធ្វើបដិសណ្ឋារកិច្ច[៨៤]ចំពោះព្រះបច្ចេកពុទ្ធ ដែលនិមន្តមកនោះ" ។

តមក ព្រះរាជាត្រាស់សួរថា ៖

"កាលដែលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក តើព្រះរាជាទ្រង់ក្រោកទៅទទួលនៅកន្លែងណា ?"

---

[៨២] (ន.) (បា.),(សំ.) (ប៉័ច-ចេកៈ ពុទ្ធ) (ប្រត្យេក--) លោកអ្នកត្រាស់ដឹងចំពោះបានតែខ្លួនមួយ សម្ដែងធម៌ប្រៀនប្រដៅអ្នកដទៃផងមិនកើត : ព្រះបច្ចេកពុទ្ធ ។

[៨៣] (ន.) (បា.),(សំ.) ពាក្យសម្រាប់មន្ត្រី ឬបណ្ដារាស្ត្រទាំងពួងឆ្លើយស្ដេច បើឆ្លើយស្ដេចទ្រង់រាជ្យថា : ព្រះករុណាវិសេស ឬ ព្រះករុណាថ្លៃវិសេស ។

[៨៤] (ន.) (បា.) (បដិសន់ឋារ៉ៈ) (បដិសណ្ឋារ ឬ--សន្ថារ) កិច្ចទទួលរាក់ទាក់ភ្ញៀវ ឬចំពោះនរណាម្នាក់ ។

ក្រោយពីអាមាត្យក្រាបទូលអំពីទីកន្លែងដែលព្រះរាជាស្ដេចយាងទៅទទួលព្រះបច្ចេកពុទ្ធហើយ ស្ដេចមហាជនកក៏បញ្ជាឲ្យគេទៅជីកត្រង់កន្លែងនោះ ហើយក៏ឃើញកំណប់ទ្រព្យមែន រួចឲ្យនាំយកមកទុកក្នុងព្រះបរមរាជវាំង ។

## មហាកំណប់ទី ២

ព្រះបាទមហាជនកទ្រង់សួរទៀតថា ៖

"ចុះក្នុងកាលព្រះបច្ចេកពុទ្ធនិមន្តទៅវិញ តើព្រះរាជាស្ដេចទ្រង់ជូនដំណើរទៅប្រថាប់ឈរនៅកន្លែងណា ?"

ក្រោយពេលអាមាត្យក្រាបទូលអំពីទីកន្លែងដែលព្រះរាជាទ្រង់ឈរ ស្ដេចមហាជនក ក៏ទ្រង់បញ្ជាឲ្យទៅជីកយកកំណប់ទ្រព្យអំពីទីនោះទៀតយកមកទុក ។

នៅគ្រានោះផងដែរ មានប្រជានុរាស្ដ្រមិនតិចនាក់ទេ ដែលចង់បានកំណប់ទ្រព្យ ពួកគេពួតដៃគ្នា[៥៥]រាប់ពាន់នាក់ នាំគ្នាទៅជីករកកំណប់ទ្រព្យត្រង់ទិសមានថ្ងៃរះ ដោយយោងតាមព្រះរាជឱង្ការបោលជនកថា "កំណប់ទ្រព្យមាននៅត្រង់ទីព្រះអាទិត្យរះ", មួយទៀត ដោយយោងតាមព្រះរាជឱង្ការថា "កំណប់ទ្រព្យ ត្រង់ទីព្រះអាទិត្យលិច" ដូច្នេះ

---

[៥៥] ចូលគំនិតស្រុះគ្នាធ្វើការប្រណាំងប្រជែងយកឈ្នះ, ចូលគំនិតរួបរួមកម្លាំងគ្នាសម្រេចកិច្ចអ្វីមួយ ។

មនុស្សមួយក្រុមក៏នាំគ្នាដើរជីកត្រង់ទិសព្រះអាទិត្យលិច ។ លុះឮថា "កំណាប់ទ្រព្យនេះគេជីកបានទីឯណោះវិញ" ពួកគេក៏កើតបីតិសោមនស្ស ថាព្រះប្រាជ្ញារបស់ព្រះរាជាថ្មី ចម្លែកអស្ចារ្យអ្វីម៉្លេះហ្ន៎ ! ។

**មហាកំណប់ទី ៣**

ព្រះរាជបណ្ដាំថា "កំណាប់ទ្រព្យខាងក្នុង" ស្ដេចមហាជនកបានបញ្ជាឲ្យយកកំណាប់ទ្រព្យអំពីខាងក្នុងធរណីទ្វារ[៩៦]ធំ ក្នុងបរមរាជវាំង ។

**មហាកំណាប់ទី ៤**

ត្រង់រាជបណ្ដាំថា "កំណាប់ទ្រព្យខាងក្រៅ" ស្ដេចមហាជនកបញ្ជាឲ្យទៅយកកំណាប់ទ្រព្យអំពីខាងក្រៅធរណីនៃទ្វារធំ ក្នុងព្រះបរមរាជវាំងដែរ ។

**មហាកំណាប់ទី ៥**

ត្រង់រាជបណ្ដាំថា "កំណាប់ទ្រព្យមិនមែនខាងក្នុងមិនមែនខាងក្រៅ" ស្ដេចមហាជនកបញ្ជាឲ្យជីកយកកំណាប់ទ្រព្យអំពីខាងក្រោមធរណីទ្វារ ។

**មហាកំណាប់ទី ៦**

ត្រង់រាជបណ្ដាំថា "កំណាប់ទ្រព្យត្រង់ទីសម្រាប់ឡើង" គឺស្ដេចមហាជនកឲ្យទៅយកកំណាប់ទ្រព្យពីកន្លែងក្រាលកម្រាលព្រំត្រង់

---

[៩៦] (ន.) (ធរៈនី--) មេទទឹងទ្វារដែលដាក់ផ្ទាល់នឹងផែនដីឬនឹងផ្ទៃខាងក្រោម ។

បង្អោង[៨៧]មាស ក្នុងពេលស្ដេចទ្រង់ឡើងជិះដំរីមង្គល[៨៨] ។

**មហាកំណប់ទី ៧**

ត្រង់រាជបណ្ដាំថា "កំណប់ត្រង់ទីសម្រាប់ចុះ" គឺស្ដេចមហាជនក បង្គាប់ឲ្យគេទៅយកកំណប់ត្រង់កន្លែងស្ដេចចុះអំពីកដំរី ។

**មហាកំណប់ទី ៨-៩-១០-១១**

ត្រង់រាជបណ្ដាំថា "កំណប់ត្រង់ដើមសាលព្រឹក្សធំទាំង ៤" គឺស្ដេចមហាជនកបង្គាប់ឲ្យគេទៅយកកំណប់ទ្រព្យ ៤ ឆ្នាំង ពីក្រោមជើងគ្រែទាំង ៤ កន្លែង ដែលជាងធ្វើដោយដើមសាលព្រឹក្ស ជាក្រឡាព្រះបន្ទំ ដ៏មានស្រីសួស្ដី[៨៩] នៅកន្លែងគាល់បម្រើនៅលើដី ។

**មហាកំណប់ទី ១២**

ត្រង់រាជបណ្ដាំថា "កំណប់នៅត្រង់ទីមួយយោជន៍ជុំវិញ" គឺស្ដេចមហាជនកបញ្ជាឲ្យទៅយកកំណប់ក្នុងទីប្រមាណមួយជួរនឹមដោយ

---

[៨៧] (ន.) ឈើឬឬស្សីមានកាំសម្រាប់ដាក់ឡើងឈើខ្ពស់ : បង្អោងត្នោត, ឡើងតាមបង្អោង ។

[៨៨] ដំរីដែលនាំឲ្យមានសិរីសួស្ដីដល់ព្រះនគរ និងប្រជានុរាស្ត្រ ។

[៨៩] ពាក្យនេះដូចគ្នានឹងពាក្យថា សិរីសួស្ដី ដែរ ដែលមានន័យថា សេចក្ដីសុខស្រួល; ការប្រព្រឹត្តទៅស្រួល; សេចក្ដីចម្រើនដោយសុខ; សេចក្ដីសុខចម្រើន, គ្រោះល្អ; ដំណើរមានជោគ : មានសួស្ដី, ទៅមកដោយសួស្ដី ។ ពាក្យឲ្យពរគ្នាបានរាល់ពេល (ប្រើតាមសម័យនិយម) ។

ជុំវិញ នៃទីក្រឡាព្រះបន្ទំដ៏មានសិរី ពីព្រោះពាក្យថា យោជន៍ ៗ ក្នុងទីនេះ គឺស្ដេចបោលជនកសំដៅយកមួយជួរនឹម[៩០]រទេះ ។

**មហាកំណប់ទី ១៣**

ត្រង់រាជបណ្ដាំថា "កំណាប់ធំត្រង់ចុងភ្លុកដំរីទាំងពីរ" គឺស្ដេចមហាជនកប្រើគេឲ្យទៅយកកំណាប់ត្រង់ចុងភ្លុកទាំងពីររបស់ដំរី នៅកន្លែងដំរីមង្គល ។

**មហាកំណប់ទី ១៤**

ត្រង់រាជបណ្ដាំថា "កំណាប់នៅត្រង់ចុងកន្ទុយ" គឺស្ដេចមហាជនកឲ្យទៅយកកំណាប់ត្រង់ទីចុងកន្ទុយរបស់ដំរីនោះ ក្នុងកន្លែងដំរីមង្គល ។

**មហាកំណប់ទី ១៥**

ត្រង់រាជបណ្ដាំថា "កំណាប់ក្នុងទឹក" គឺស្ដេចមហាជនកឲ្យបាចទឹកចេញអំពីស្រះមង្គលបោក្ខរណី[៩១] ហើយទ្រង់បង្ហាញកំណាប់ក្នុងបាតស្រះនោះ ។

**មហាកំណប់ទី ១៦**

ត្រង់រាជបណ្ដាំថា "កំណាប់ធំត្រង់ចុងឈើ" គឺស្ដេចមហាជនក

---

[៩០] ចម្ងាយប្រវែងមួយនឹមរទេះស្មើនឹង ២ ម៉ែត្រ: ព្រះភិក្ខុនិមន្តដើរឬអង្គុយក្នុងចន្លោះផ្ទះអាចមើលបានចម្ងាយមួយជួរនឹម។

[៩១] (ន.) (បា.),(សំ.) (បោក-ខ:រ៉:ណី) (បុក្ខរិនិ ឬ បុក្ខរិណី) ស្រះមានឈូក (ស្រះឈូក) ។

ឲ្យទៅយកកំណាប់ខាងក្នុងស្រមោលនៃដើមឈើជាបរិមណ្ឌល[៩២] វេលាថ្ងៃកំពុងត្រង់ នាគល់មហាសាលព្រឹក្សក្នុងឧទ្យាន។

ក្រោយពីប្រើគេឲ្យយកកំណាប់ធំ ៗ ទាំង ១៦ បានមករួចរាល់យ៉ាងនេះហើយ ស្ដេចមហាជនកទ្រង់សួរថា ៖

"មានអ្វីដទៃទៀតទេ ? "

ពួកអាមាត្យក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព អស់ហើយ អត់មានទៀតទេ ក្រាបទូល" ។

ប្រជាជនដែលមកចូលរួមស្ដាប់ការដោះស្រាយប្រស្នាកំណាប់ទ្រព្យទាំង ១៦ នោះ មានសេចក្ដីត្រេកអររីករាយក្រៃលែង ដោយបានឃើញកិត្យានុភាព[៩៣]របស់ព្រះបាទមហាជនក ។

បន្ទាប់មក ស្ដេចមហាជនក មានព្រះតម្រិះថា "យើងនឹងបរិច្ចាគទ្រព្យទាំងនេះទៅជាទាន" រួចទ្រង់ចាត់ឲ្យជាងសាងសង់សាលាទាននៅកណ្ដាលនគរ ១ ខ្នង និងទៀបទ្វារនគរទាំង ៤ ទិស ៤ ខ្នង រួមជា ៥ កន្លែងនេះ ស្ដេចទ្រង់តែងតែចំណាយធនធានជាព្រះរាជទ្រព្យដ៏សម្បើមក្នុងការធ្វើទាន ។

---

[៩២] (ន.) (សំ.),(បា.) (ប៉ៈរ៉ិមន់-ឌល់) វង់មូល, អ្វី ៗ ដែលមានសំណុំមូល : ដើមស្វាយនេះមានបរិមណ្ឌលល្អណាស់ ។ ដំណើររៀបរយចុះបែបបទ : ស្លៀកដណ្ដប់ជាបរិមណ្ឌល គឺស្លៀកដណ្ដប់ត្រឹមត្រូវតាមបែបបទ, ស្លៀកដណ្ដប់ចុះបែប ។

[៩៣] (ន.) (បា.) (កិត-ត្យា--) (កិត្តិ + អានុភាវ) អានុភាពនៃកេរ្ដិ៍ឈ្មោះ ។

ចំណែកឯព្រះមាតារបស់ព្រះអង្គ និងអាចារ្យទិសាបាមោក្ខ ឯណោះវិញ ក៏ស្ដេចទ្រង់ចាត់ពួកមន្ត្រីឲ្យទៅអញ្ជើញពួកគាត់អំពីក្រុងកាលចម្ប៉ានគរមករស់ជួបជុំគ្នាជាមួយនឹងព្រះអង្គដែរ ហើយទ្រង់តែងចាត់ចែងកិច្ចការបម្រើដោយយកព្រះទ័យទុកដាក់ជាទីបំផុតចំពោះលោកអ្នកមានគុណទាំងនោះ ។ ដោយសារកិត្យានុភាពរបស់ព្រះបាទមហាជនកបានល្បីរន្ទឺ[94] ទូទៅក្នុងរាជាណាចក្ររបស់ព្រះអង្គ បណ្ដាលឲ្យមហាជនទូទាំងដែនវិទេហរដ្ឋ មានការភ្ញូកភ្ញឹក[95] នឹកចង់ឃើញថា ៖

"បុត្ររបស់ស្ដេចអរិដ្ឋជនក ព្រះនាមថាមហាជនក បានឡើងជាស្ដេចផែនដីគ្រប់គ្រងរាជាណាចក្រ, ឮថាស្ដេចអង្គនោះ ជាបណ្ឌិត ឈ្លាសវៃក្នុងឧបាយកល[96] ពួកយើងនឹងចូលទៅគាល់ព្រះអង្គ" ។

មនុស្សទាំងឡាយបាននាំយកនូវគ្រឿងបណ្ណាការ[97] ដ៏ច្រើនសន្ធឹកសន្ធាប់ អំពីតំបន់ផ្សេង ៗ មកថ្វាយចំពោះព្រះមហាក្សត្រវ័យក្មេង ។

---

[94] (កិ.) លេចឮកេរ្តិ៍ឈ្មោះល្អឬអាក្រក់ ទៅគ្រប់ទិសទី ។

[95] ភ្ញូកយ៉ាងសម្បើមគួរភ្ញឹក ច្រើននិយាយថា ផ្អើលភ្ញូក, បាក់ភ្ញូក, ភ្ញូកបុះចូល, ជឿភ្ញូក...។

[96] ល្បិចល្បងយ៉ាងល្អិត, ល្បិចបញ្ឆោត ។

[97] (ន.) (បា.),(សំ.) (ប័ន-ណាកា ឬ ប៉ុន--) (បណ៌ាការ) ជំនូន, កស្តុការ, តង្វាយ; ច្រើននិយាយក្លាយជា បណ្ដាការ (គួរប្រើ បណ្ណាការ វិញទើបត្រឹមត្រូវតាមប្រភពនៃពាក្យ) ។

ចំណែកអ្នកក្រុងនាំគ្នារៀបចំលេងមហោស្រព[៩៨] យ៉ាងគគ្រឹកគគ្រេង អបអរសាទរ ។ នៅក្នុងរាជនិវេសន៍ មានក្រាលកម្រាលព្រំជាដើម ចង រំយោលចង្កោមផ្កានិងកម្រងផ្កានានា ប្រាយលាជ បាចផ្កាម្លិះ បាញ់ទឹកអប់ មានក្លិនក្រអូបឈ្ងុយឈ្ងប់ និងមានដាក់តាំងគ្រឿងផឹកគ្រឿងហូបចុកជាច្រើនមុខច្រើនប្រភេទ រង់ចាំទទួលភ្ញៀវ ។ ខាទនីយភោជនីយាហារ[៩៩] ទឹកឃ្មុំទឹកអំពៅ និងផ្លែឈើជាដើមមានច្រើនជាអនេកប្បការ[១០០] នៅលើភាជន៍ប្រាក់ភាជន៍មាសជាដើម ដើម្បីធ្វើជាបណ្ណាការតង្វាយថ្វាយព្រះមហាក្សត្រ ។

មនុស្សទាំងឡាយដែលមកជួបជុំគ្នាកុះករនៅទីនោះ ៗ បាននាំគ្នាឈរកាន់ចោមរោមជុំជិតព្រះមហាក្សត្រ ។ មន្ត្រីនាហ្មឺនទាំងឡាយអង្គុយជាវង់មួយក្រុម ព្រាហ្មណ៍ក៏ជាវង់មួយក្រុមសេដ្ឋីជាដើមក៏ជាវង់មួយក្រុម ស្រីរបាំដែលមានរូបល្អល្អះក៏អង្គុយរៀបជាជួរមួយកន្លែង ។

---

[៩៨] (ន.) (សំ.),(បា.) (មៈហោស្រប់) (មហោត្សវ < មហា + ឧត្សវ; មហុស្សវ < មហា + ឧស្សវ) របាំយ៉ាងធំ, ការលេងល្បែងរបាំគគ្រឹកគគ្រេង; ការរីករាយសប្បាយខ្លាំងដោយល្បែងរបាំ; ការបញ្ចេញរបស់ប្លែក ៗ ដាក់តាំងជារបៀបយ៉ាងធំឲ្យមហាជនមើល; ពិធីសម្ភោឡយ៉ាងធំ : លេងមហោស្រព, មើលមហោស្រព, រៀបពិធីមហោស្រព (ប្រើក្លាយជា មហោរស្រព ក៏មាន ប៉ុន្តែគួរលែងប្រើ) ។

[៩៩] អាហារដែលគួរបរិភោគនិងខាំទំពា គឺបង្អែមនិងចម្អាប ។

[១០០] ប្រការច្រើន; ដែលមានប្រការច្រើន ។

ចំណែកព្រាហ្មណ៍ទាំងឡាយ ពោលជ័យមង្គលសិរីសួស្តីថ្វាយ ។ ពួកនារីដែលឈ្លាសក្នុងការរាំនិងច្រៀងជាដើម ក៏ចាប់ផ្ដើមរាំច្រៀងថ្វាយ ។ តូរ្យតន្ត្រីរាប់រយវង់ ប្រគុំឡើងយ៉ាងគគ្រឹកគគ្រេងទ្រហឹងអឺងកងពេញនគរ ។

នៅពេលនោះ ស្នូរឈូឆរលាន់ព្រមគ្នាពេញរាជនិវេសន៍ ហាក់ដូចជាផ្ទៃសាគរត្រូវកម្លាំងខ្យល់យុគន្ធរបោកបក់យ៉ាងខ្លាំង ។ គ្រប់ទីកន្លែងដែលគយគន់មើលទៅ មានអាការកគ្រើករំពើកញាប់ញ័រ ។

គ្រានោះ ព្រះមហាសត្តប្រថាប់គង់លើរាជាសនៈខាងក្រោមព្រះមហាស្វេតច្ឆត្រ គន់មើលភាពរុងរឿងដ៏មហាស្ចារ្យរបស់ព្រះអង្គប្រៀបបានទៅនឹងភាពរុងរឿងរបស់សក្កទេវរាជ ទ្រង់ក៏ចាប់ក្លឹកនឹកឃើញទៅដល់សេចក្ដីព្យាយាមដែលទ្រង់បានធ្វើនៅក្នុងមហាសមុទ្រ ។ កាលកំពុងតែរលឹកនូវសេចក្ដីព្យាយាមនោះ បីតិ (ភាពត្រេកអរនៃចិត្ត) កើតឡើងដល់ព្រះអង្គថា ៖

> “វីរិយំ នាម កាតព្វយុត្តកំ,
> សចាហំ មហាសមុទ្ទេ វីរិយំ ឆាការិស្សំ,
> ន ឥមំ សម្បត្តឹ អលភិស្សំ” ។

“ដែលហៅថា សេចក្ដីព្យាយាមគឺជាគុណជាតត្រូវតែបំពេញឲ្យខាងតែបាន បើកុំតែអញបានបំពេញសេចក្ដីព្យាយាមក្នុងមហា-

សមុទ្រ ម៉្លេះសមអញនឹងមិនបាននូវមហាសម្បត្តិបែបនេះ
ឡើយ” ។

កម្លាំងនៃបីតិនោះ ជំរុញឲ្យព្រះអង្គទ្រង់បានបន្លឺនូវឧទាន[១០១] មួយអង្គ ឯងថា ៖

“អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ យថា ឥច្ឆិំ តថា អហុ។
“អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ ឧទកា ថលមុព្ភតំ។
“វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ យថា ឥច្ឆិំ តថា អហុ។
“វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ ឧទកា ថលមុព្ភតំ។

---

[១០១] (ន.) (សំ.),(បា.) (អ៊ុទាន) (< ឧត្ត > ឧទ្ទិ “ខ្ពស់; ឮខ្លាំង” + អានិ “ការដកដង្ហើមចេញ”; < ឧ + ទ អាគម + អាន “ការបញ្ចេញសំឡេងឮខ្លាំង”) ការបន្លឺ, ការកម្ទរ គឺការបន្លឺឬកម្ទរសម្ដីឮខ្លាំង ៗ ដោយមានអំណរឬទុក្ខព្រួយ, ដោយមានសេចក្ដីអស្ចារ្យ, ដោយមានកំហឹងជាដើម : បញ្ចេញឧទានកណ្ដាលប្រជុំជន ។-ឈ្មោះគម្ពីរសុត្តន្តបិដកមួយផ្នែក ក្នុងពួកខុទ្ទកនិកាយ ដែលនិយាយអំពីឧទានកថានៃព្រះសម្មាសម្ពុទ្ធ : គម្ពីរឧទាន ។-ឈ្មោះអង្គមួយប្រភេទ រាប់ចូលក្នុងអង្គ ៩ នៃពុទ្ធសាសនា ។-សូរលាន់មាត់ឬសម្រែកសត្វជាដើម, ដូចជា អ៉ា !, អ៊ូយ !, យី !, យីអើ !; ខ្វក ៗ ! ចេច ៗ ! ជាដើម ហៅថា ឧទាន ឬ ឧទានសព្ទ ។

"ទុក្ខូបនីតោបិ នរោ សបញ្ញោ អាសំ ន ឆិន្ទេយ្យ សុខាគមាយ
ពហូ ហិ ផស្សា អហិតា ហិតា ច អវិតក្កិតា មច្ចុមុបព្វជន្តិ។
"អចិន្តិតម្បិ ភវតិ ចិន្តិតម្បិ វិនស្សតិ
ន ហិ ចិន្តាមយា ភោគា ឥត្ថិយា បុរិសស្ស វា"។

*"បុរសជាបណ្ឌិតត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើង ឃើញច្បាស់ដោយខ្លួនឯងផ្ទាល់ យើងប្រាថ្នាយ៉ាងណាក៏បាន យ៉ាងនោះ ។ បុរសជាបណ្ឌិតត្រូវតែប្រាថ្នា មិនត្រូវនឿយណាយ ទេ យើងឃើញច្បាស់ដោយខ្លួនឯងថា មានទេវតាស្រង់យើង អំពីទឹកមកដាក់លើគោក ។ បុរសជាបណ្ឌិតត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ដោយខ្លួនឯងថា យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ ។ បុរសជាបណ្ឌិតត្រូវ តែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ដោយខ្លួន ឯងថា មានទេវតាស្រង់យើងអំពីទឹកមកដាក់លើគោក ។ នរជន មានប្រាជ្ញា ទោះបីមានសេចក្តីទុក្ខបៀតបៀនក៏ដោយ ក៏មិនត្រូវ បោះបង់គោលបំណងដែលជាមាគ៌ាឆ្ពោះទៅរកសេចក្តីសុខទេ ព្រោះថា ផស្សៈមានច្រើន ផស្សៈជាសុខក៏មាន ជាទុក្ខក៏មាន សត្វទាំងឡាយដែលត្រូវសេចក្តីទុក្ខបៀតបៀន មិនបានគិតថា ផស្សៈជាសុខមាន ពួកគេនឹងបាន កាលបើធ្វើនូវសេចក្តីព្យាយាម ប៉ុន្តែពួកគេមិនធ្វើសេចក្តីព្យាយាមទេ មិនបានត្រិះរិះដល់មាគ៌ា*

នោះទេ រមែងមិនបានទូវផស្សៈជាសុខ ហើយដល់នូវសេចក្តីស្លាប់ ព្រោះហេតុនោះ សេចក្តីព្យាយាម ចាំបាច់ត្រូវតែធ្វើ ។ អ្វីដែលមិនបានគិត អាចកើតមានឡើងក៏មាន អ្វីដែលគិតហើយ អាចវិនាសទៅក៏មាន ។ ជាការពិតណាស់ អញពុំដែលគិតថានឹងបានរាជ្យដោយការមិនធ្វើសង្គ្រាមសោះ ប៉ុន្តែ អញបានគិតថា អញនឹងច្បាំងដណ្តើមរាជ្យជារបស់ព្រះបិតាមកវិញ បន្ទាប់ពីធ្វើជំនួញបានទ្រព្យច្រើនពីដែនដីសុវណ្ណភូមិ មកទល់ពេលនេះ អ្វីដែលអញបានគិត វិនាសបាត់ទៅ អ្វីដែលមិនបានគិត ស្រាប់តែកើតឡើង ។ ភោគៈទាំងឡាយរបស់ស្ត្រីឬបុរស មិនមែនសម្រេចដោយត្រឹមតែការគិតទេ ព្រោះហេតុនោះ សេចក្តីព្យាយាមចាំបាច់ត្រូវតែធ្វើ ព្រោះអ្វីដែលមិនបានគិត អាចកើតមានឡើង ដោយសារសេចក្តីព្យាយាម" ។

តាំងអំពីកាលនោះមក មហាជនករាជា ទ្រង់សោយរាជ្យដោយសមធម៌ និងស្របច្បាប់ ទ្រង់ពុំដែលប្រព្រឹត្តខុសនឹងទសពិធរាជធម៌[១០២] ១០ ប្រការ

---

[១០២] (ទៈ សៈពិធៈរាជៈ ធ័រ, ឬតាមទម្លាប់ថា ទស់សៈពិត--) ន. (បា. ទសវិធ + រាជធម្ម) រាជធម៌ ១០យ៉ាង គឺធម៌ ១០ ប្រការ សម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតីមន្ត្រីធំតូចនិងពួករាស្ត្រប្រជាឲ្យប្រព្រឹត្តផង ។ទសពិធរាជធម៌នោះគឺ ១- ទានៈ ការធ្វើអំណោយ; ២- សីលៈ ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល ១០ មួយដងមួយកាល; ៣- បរិច្ចាគៈ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ; ៤- អាជ្ជវៈ

ឡើយ ហើយព្រះអង្គគតែងតែយកព្រះទ័យទុកដាក់ទំនុកបម្រុងដល់ព្រះបច្ចេកពុទ្ធទាំងឡាយផងដែរ ។

ចំណេរកាលក្រោយមក សីវលីទេវីបានប្រសូតរាជបុត្រមួយអង្គដល់ព្រមដោយលក្ខណៈបុណ្យ ដែលនាំឲ្យធញ្ញជាតិស្រុកទេស កើតល្អបរិបូរ មាតាបិតាបានដាក់នាមឲ្យថា **ទីឃាវុកុមារ** ។ កាលដែលរាជបុត្រនោះពេញវ័យ ព្រះរាជាទ្រង់ប្រទានឋានៈជាព្រះឧបរាជ ហើយទ្រង់បានសោយរាជ្យបន្តរហូតមកបាន ៧.០០០ ឆ្នាំ ។

---

មានសេចក្ដីត្រង់; ៥- មទ្ទវៈ មានសេចក្ដីទន់ភ្លន់ស្លូតសុភាពរាបសា; ៦- តបៈ ការកាន់ឧបោសថសីលតាមកាលកំណត់ម្ដងៗ (ម. ព. តបៈ ឬ តបះ ផង); ៧- អក្កោធនៈ មិនកម្ដៅក្រហាយអ្នកដទៃ; ៨- អវិហឹសា មិនបៀតបៀនអ្នកដទៃ; ៩- ខន្ដិ មានសេចក្ដីអត់ធន់; ១០- អវិរោធនៈ មិនបំពានលើធម៌លើច្បាប់ ។ ច្រើនប្រើកាត់ខ្លីត្រឹមតែទសពិធ ឬទសពិធធម៌ ។

# ជំពូកទី ៤

## ព្រះបាទមហាជនកលះបង់រាជ្យសាងផ្នួស

### ដើមស្វាយពីរដើម

ក្នុងថ្ងៃមួយ មាននាយឧទ្យានបាល[១០៣]ម្នាក់ បានបេះផ្លែឈើធំតូច និងកាច់ផ្កាដែលមានសម្រស់នានាមកថ្វាយព្រះបាទមហាជនក ទ្រង់ទតព្រះនេត្រាឃើញនូវផលាផលនិងបុប្ផជាតិទាំងនោះ ក៏ទ្រង់មានព្រះទ័យត្រេកអរ បានធ្វើការរាប់អានចំពោះនាយឧទ្យានបាលនោះ រួចព្រះអង្គត្រាស់ថា ៖

"ម្នាលឧទ្យានបាលសម្លាញ់ ! ខ្ញុំគ្រោងនឹងទតមើលឧទ្យាន, អ្នកចូរតុបតែងឧទ្យាននោះឲ្យមានសោភណភាព" ។

នាយឧទ្យានបាលទទួលព្រះរាជឱង្ការថា ព្រះករុណាថ្លៃវិសេស ក៏បានរៀបចំចាត់ចែងតាមព្រះរាជបញ្ជារួចរាល់ហើយ គេបានចូលគាល់ទូលថ្វាយព្រះរាជាឲ្យទ្រង់ជ្រាប ។ ស្ដេចមហាជនក ទ្រង់ឡើងគង់ដំរី យាងចេញអំពីព្រះនគរដោយមានបរិវារដ៏ច្រើនហែហមអមព្រះរាជដំណើរទៅជាមួយផង ធ្វើដំណើររហូតដល់ទ្វារឧទ្យាន ។ នៅទីនោះ មានដើមស្វាយពីរដើម ពណ៌ខៀវស្រស់ ដើមមួយឥតមានផ្លែ ដើមមួយទៀត

---

[១០៣] ឧទ្យានបាល (អ៊ុត-ទ្យានៈបាល) អ្នករក្សាឬអ្នកថែឧទ្យាន (បើស្ត្រីជា ឧទ្យានបាលី ឬ--បាលិកា អ. ថ. --ប៉ាលី ឬ ប៉ាលិកា) ។

មានផ្លែរយើងរយោង ជាចង្កោម ៗ ថែមទាំងមានរសជាតិផ្អែមឆ្ងាញ់ក្រៃលែង ដោយហេតុតែព្រះរាជាទ្រង់ពុំទាន់បានសោយផ្លែស្វាយដ៏ល្អនោះនៅឡើយ ទើបនរណា ៗ ក៏មិនហ៊ានបេះផ្លែស្វាយនោះឡើយ ។ ព្រះរាជាកាលទ្រង់កំពុងប្រថាប់គង់នៅលើ-កដំរី ទ្រង់បានឈោងព្រះហស្តបេះផ្លែស្វាយមួយអំពីដើមនោះ សោយសាកមើលទៅ ដោយគ្រាន់តែដាក់លើចុងអណ្តាតភ្លាម ស្រាប់តែរសជាតិផ្លែស្វាយនោះប្រាកដដូចឱជា[១០៤] ទិព្វ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ៖

"យើងនឹងសោយឲ្យបានច្រើនក្នុងពេលត្រឡប់មកវិញ" ។ ជនជុំវិញមានលោកឧបរាជជាដើម រួមទាំងអ្នកបរដំរីបរសេះផងនោះ ក្រោយពីដឹងថា "ផ្លែស្វាយថ្មោងថ្មី[១០៥] គឺព្រះរាជាទ្រង់បានសោយហើយ"ដូច្នេះហើយ ក៏នាំគ្នាឈោងបេះបរិភោគដែរ ។ រីឯអ្នកដទៃ ៗ ណាដែលឈោងបេះពុំបានដូចគេ ក៏រកកំណាត់ឈើមកគប់គ្រវែងបណ្តាលឲ្យបាក់មែក ជ្រុះស្លឹក ក្លាយទៅជាឈើរ៉ាង[១០៦] រកត្រឹមតែស្លឹកមួយគ្មាន ។ ចំណែកឯដើមមួយឥតផ្លែនៅទន្ទឹមគ្នានោះវិញ នៅឈរយ៉ាងស្រស់

[១០៤] (ន.) (បា.) (សំ. ឱជសិ; ឱជា) អ្វី ៗ ដែលបង្កើតកម្លាំង, គ្រឿងបង្កើតកម្លាំង, ជំនួយកម្លាំង គឺរសដែលនាំឲ្យមានកម្លាំង, រសឆ្ងាញ់; ជីជាតិ; កម្លាំងកាយ ឬទឹកកម្លាំងក្នុងខ្លួន : ឱជៈជី   រសជាតិជី (សរសេរជា ឱជៈ ក៏បាន) ។

[១០៥] (គុ.) ថ្មី, ដំបូង, ចំពើប : ចំណីថ្មោង ។ ថ្មោងថ្មី ដែលថ្មោងហើយទើបបានថ្មី ។

[១០៦] ឈើដែលជ្រុះស្លឹកអស់ នៅសល់តែមែក ។ ពាក្យនេះ មិនសូវជាមានប្រើទូទៅទេ មានដោយតំបន់ខ្លះ ។

សង្ខា[១០៧] ពណ៌ខៀវស្រស់ ហាក់ដូចត្បូងកែវមណី ។

## ស្ដេចមហាជនកធ្វើសមណធម៌នៅលើប្រាសាទ

ព្រះរាជា កាលស្ដេចយាងចេញអំពីឧទ្យានមក ទ្រង់បានទតមើលឃើញដើមស្វាយដែលមានផ្លែ បែរជាមានស្ថានភាពដូច្នោះវិញ ក៏ត្រាស់សួរពួកអាមាត្យថា ៖

"តើមានរឿងអ្វីកើតឡើង ធ្វើឲ្យដើមស្វាយក្លាយជាបែបនេះ ?"

ពួកអាមាត្យ ក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព មហាជនក្រោយពេលដឹងថា ព្រះសម្មតិទេពសោយផ្លែស្វាយដ៏ថ្លោងថ្លៃរួចហើយ ពួកគេក៏ដណ្ដើមប្រជែងគ្នាបេះបរិភោគ មានអ្នកខ្លះគប់គ្រវែងធ្វើឲ្យមែកស្វាយជ្រុះស្វិតអស់" ។

ព្រះរាជាត្រាស់សួរបន្តថា ៖

"ម្នាលប្រស្តែង, មកអំពីហេតុអ្វីហ្ន៎ បានជាដើមស្វាយមួយនេះ លែងមានស្លឹក លែងមានពណ៌ដែលជាសម្រស់របស់ខ្លួន ឯដើមមួយទៀតនោះ មើលទៅគ្មានឃើញបាត់សម្រស់ត្រង់ណាបន្តិចសោះ ?"

---

[១០៧] (គុ.) (សង់-ហា) ដែលរុងរឿង មានរូបល្អអង់អាច ឆើតឆាយ, ស្រស់, ស្រស់បស់ : រូបឆោមសង្ខា, តែងខ្លួនយ៉ាងសង្ខា) ។ សង្ខាពសី គឺពសីរុងរឿង : មានសង្ខាពសី ។

ពួកអាមាត្យក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព ដើមស្វាយដែលមិនបាត់សម្រស់នោះ ព្រោះដើមនោះគ្មានផ្លែ ក្រាបទូល" ។

លុះទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះរាជាទ្រង់កើតសេចក្ដីសង្វេគថា ៖

"ឱហ្ន៎ ! ដើមស្វាយនេះនៅមានពណ៌ខៀវស្រស់ក្លឹថ្លា ព្រោះតែខ្លួនឥតមានផ្លែ ប៉ុន្តែដើមមួយនេះវិញ មែកបាក់ ជ្រុះស្លឹករាត់រាយ ព្រោះតែខ្លួនមានផ្លែ, ឯរាជសម្បត្តិនេះវិញ ក៏ប្រៀបដូចដើមឈើមានផ្លែនោះដែរ រីឯដំណើរចេញសាងផ្នួសវិញ ស្មើនឹងឈើដែលឥតផ្លែ, ភ័យតែងមានដល់បុគ្គលអ្នកមានសេចក្ដីខ្វល់ខ្វាយតែប៉ុណ្ណោះ ពុំមានដល់បុគ្គលអ្នកឥតខ្វល់ខ្វាយឡើយ, ព្រោះហេតុនោះ អាត្មាអញមិនត្រូវធ្វើខ្លួនដូចឈើមានផ្លែឡើយ ត្រូវធ្វើខ្លួនឲ្យដូចឈើឥតផ្លែ, គឺលះបោលសម្បត្តិនេះចេញទៅសាងផ្នួសវិញ" ។

ព្រះមហាក្សត្រស្ដេចទ្រង់សមាទាន[១០៨]អធិដ្ឋានព្រះទ័យយ៉ាងមុតមាំ ស្ដេចយាងចូលទៅកាន់នគរ ប្រថាប់ឈរទៀបទ្វារប្រាសាទ បង្គាប់រាជបម្រើឲ្យទៅហៅសេនាបតីចូលគាល់ រួចទ្រង់ប្រាប់សេនាបតីថា ៖

[១០៨] (ន.) (សំ.)(បា.) ការកាន់ដោយប្រពៃ, ការទទួលកាន់តាម, ការបញ្ចេញវាចាប្ដេជ្ញាទទួលកាន់តាម ។ ខ្មែរច្រើនប្រើជា កិ. បញ្ចេញវាចាប្ដេជ្ញាទទួលកាន់តាម ដូចជា

"ហៃសេនាបតី, ចាប់ពីថ្ងៃនេះទៅ ចូរលោកកុំឲ្យអ្នកដទៃណា ៗ ចូលគាល់យើងឡើយ លើកលែងតែអ្នកបម្រើម្នាក់ដែលត្រូវនាំក្រយាស្ងោយ ទឹកលុបព្រះភក្ត្រ និងឈើស្ទន់[១០៩] មកថ្វាយប៉ុណ្ណោះ, ហើយចូរលោកដឹកនាំអាមាត្យអ្នកកាត់ក្ដីចាស់ ៗ របស់យើង មើលការខុសត្រូវប្រទេសជាតិផងចុះ, ពីឥឡូវនេះទៅ យើងនឹងសំងំធ្វើសមណធម៌នៅប្រាសាទជាន់លើ" ។

លុះផ្ដាំផ្ញើដូច្នេះហើយ ទ្រង់ស្ដេចយាងឡើងកាន់ប្រាសាទមួយអង្គឯង សំងំធ្វើសមណធម៌ ។ ពេលវេលាចេះតែកន្លងទៅយ៉ាងនេះ អាណាប្រជានុរាស្ត្រទាំងឡាយ មកជួបជុំគ្នាកុះករនៅទីធ្លាព្រះលានហ្លួង[១១០] កាលមិនបានឃើញព្រះមហាសត្ត នាំគ្នាពោលថា ៖

"ព្រះរាជារបស់យើង មិនមែនដូចមនុស្សចាស់ទេ" ។

រួចនាំគ្នាពោលដូច្នេះថា ៖

"អចោរាណំ វត ភោ រាជា សព្វកុម្មោ ធិសម្បតិ

---

កំពុងសមាទានសីល, សមាទានធុតង្គ, សមាទានវត្ត (សរសេរក្លាយជា ស្មាទាន តាមសំនៀងថាដោយស្រួលមាត់ តាមដំណើរកាព្យក៏មាន) ។

[១០៩] (ន.) ប្រដាប់សម្រាប់ដុសជម្រះធ្មេញ តាមបែបបុរាណ : ទំពាឈើស្ទន់ស្រស់, ដំឈើស្ទន់ (ខ្មែរច្រើនប្រើវល្លិស្រស់ឬមែកឈើស្រស់ដែលមានរសប្រហាតឬស្អែងដូងស្អែងស្វាស្រស់ក៏ប្រើ) ។(សព្វថ្ងៃ ប្រើច្រាសដុសធ្មេញ) ។

[១១០] ទីធ្លាធំទូលាយនៅមុខព្រះបរមរាជវាំង ។

នដ្ឋ នច្ចេ និសាមេតិ ន គីតេ កុរុតេ មនោ ។
"ន មិគេ នបិ ឧយ្យានេ នបិ ហំសេ ឧទិក្ខតិ
មូគោវ តុណ្ហិមាសីនោ ន អត្ថមនុសាសតិ" ។

"ម្នាលគ្នាយើងដ៏ចម្រើន ព្រះរាជាត្រួតនូវផែនដីទាំងមូល ព្រះអង្គជាទិសាធិបតី មិនដូចអំពីដើមសោះ ថ្ងៃនេះទ្រង់មិនក្រសាលរបាំ ទ្រង់មិនយកព្រះហឫទ័យទុកដាក់ចំពោះចម្រៀង មិនទតម្រឹគ មិនទតឧទ្យាន មិនទតហង្ស ទ្រង់គង់នៅស្ងៀមហាក់ដូចជាមនុស្សគ ទ្រង់មិនបើកសវនាការកាត់ក្តីទេ" ។

រីឯអង្គព្រះមហាក្សត្រស្តេចផែនដី ទ្រង់មានព្រះហឫទ័យពុំជាប់ស្អិតក្នុងកាមទាំងឡាយ ទន់ទោរ[១១១]ទៅក្នុងវិវេក[១១២]តែម្យ៉ាង ទ្រង់នឹករលឹកដល់ព្រះបច្ចេកពុទ្ធជាជីតុន[១១៣]របស់ព្រះអង្គថា ៖

---

[១១១] (គុ.)ដែលមានចិត្តបង្អោនទៅរក ឬមានចិត្តអនុលោមទៅរក ។

[១១២] (ន.) (សំ.) (បា.) សេចក្តីស្ងាត់ ការស្ងាត់ចាកអារម្មណ៍សៅហ្មង ការពិចារណាឃើញសេចក្តីពិត ។ គុ. ស្ងាត់ ។ វិវេកដ្ឋាន ឬ--ស្ថាន ឋានស្ងាត់ ។ វិវេកភាព (--ក:-ភាប) ភាវ:ស្ងាត់ ។ វិវេការម្មណ៍ (បា. វិវេក + អារម្មណ) អារម្មណ៍ស្ងាត់ (ចាកសេចក្តីសៅហ្មង) ។ (ព. ពុ.) : កាយវិវេក (--យ៉:--) សេចក្តីស្ងាត់កាយ ចិត្តវិវេក (ចិត-ត:--) សេចក្តីស្ងាត់ចិត្ត ឧបធិវិវេក (អ៊ុ-ប៉:-ធិ--) សេចក្តីស្ងាត់កិលេស ។

[១១៣] (ន.)ពាក្យសម្រាប់គ្រហស្ថហៅអ្នកបួសដែលជាញាតិឬដែលស្និទ្ធស្នាលដោយបានផ្គត់ផ្គង់ចតុប្បច្ច័យផង ។

"តើនរណានឹងប្រាប់យើងពីលំនៅរបស់ពួកអ្នកឥតកង្វល់[១១៤] ទាំងឡាយនោះ ដែលប្រកបដោយគុណមានសីលជាដើម" ។ លុះទ្រង់មានព្រះរាជតម្រិះដូច្នេះហើយ ក៏បន្លឺនូវឧទាននេះ ៖

"សុខកាមា រហោសីលា វធពន្ធា ឧបារតា
កស្ស នុ អជ្ជ អារាមេ ទហរា វុទ្ធា ច អច្ឆរេ ។
"អតិក្កន្តវនថា ធីរា នមោ តេសំ មហេសិនំ
យេ ឧស្សុកម្ហិ លោកម្ហិ វិហរន្តិ មនុស្សុកា ។
"តេ ឆេត្វា មច្ចុនោ ជាលំ តតំ មាយាវិនោ ទឡ្ហំ
ឆិន្នាលយត្តា គច្ឆន្តិ កោ តេសំ គតិមាបយេ" ។

"ព្រះបច្ចេកពុទ្ធទាំងឡាយ ទាំងក្មេងទាំងចាស់ សុទ្ធតែប្រាថ្នាសេចក្ដីសុខ មានសេចក្ដីស្ងប់ស្ងាត់ជាប្រក្រតី[១១៥] ប្រាសចាកចំណងគឺកិលេស គង់នៅក្នុងអារាមបុគ្គលណាហ្ន៎ ក្នុងថ្ងៃនេះ ។ អ្នកប្រាជ្ញទាំងឡាយណា បានកន្លងនូវតណ្ហា ជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយនៅក្នុងលោកដែលកំពុងខ្វល់ខ្វាយ ខ្ញុំសូម

---

[១១៤] (ន.) សេចក្ដីខ្វល់ចិត្ត ខ្វល់គំនិត : ខ្ញុំមានកង្វល់ (កុំប្រើថាខ្ញុំមានសេចក្ដីកង្វល់) ។ ស្រុកកើតកង្វល់ គឺស្រុកដែលមានកើតសឹកសង្គ្រាម ឬ មានកើតបះបោរចលាចលអ្វីមានកង្វល់ មានក្ដីខ្វល់ ។

[១១៥] (ន.)ធម្មតា ការប្រព្រឹត្តទៅតាមចំណាំ តាមទម្លាប់ សេចក្ដីមិនប្លែកអំពីដំណើរដើម ដំណើរដែលតាំងនៅដូចដែល : នៅធ្វើការតាមប្រក្រតី ។

ថ្វាយបង្គំអ្នកប្រាជ្ញទាំងនោះ ជាអ្នកស្វែងរកនូវគុណដ៏ធំ ។ អ្នកប្រាជ្ញទាំងឡាយនោះ កាត់ទម្លាយនូវតម្បាញជាបណ្ដាញដ៏មាំរបស់មច្ចុដែលមានមាយា ចេញទៅរួច បុគ្គលណាគប្បីញ៉ាំងយើងឲ្យដល់នូវគតិ (លម្អាន) នៃអ្នកប្រាជ្ញទាំងនោះបាន" ។

ព្រះបាទមហាជនកបានបង្អោនព្រះទ័យទៅរកផ្នួស ។ ព្រះរាជាទ្រង់សំងំធ្វើសមណធម៌[116] នៅលើប្រាសាទនោះអស់រយៈពេល ៤ ខែ ។ គ្រានោះ ព្រះហឫទ័យរបស់ព្រះមហាក្សត្ររឹតតែបង្អោនទៅក្នុងការសាងផ្នួសក្រៃលែងឡើងៗ, ពេលនោះ សម្រាប់ព្រះអង្គ រាជវាំងប្រាកដដូចជាលោកន្តរនរក, ភព ៣ ហាក់ដូចជាត្រូវភ្លើងឆេះសន្ធោសន្ធៅ ។ ព្រះរាជា ហេតុតែមានព្រះហឫទ័យឆ្ពោះទៅរកផ្នួស ទ្រង់បានព្រះចិន្តាថា ៖

"តើពេលណាហ្ន៎ ទើបអញអាចលះបង់ក្រុងមិថិលាដែលតុបតែងល្អដូចឋានសក្កទេវរាជនេះ ហើយចូលទៅកាន់ព្រៃហិមពាន្ត[117] កាន់ភេទជាអ្នកបួសរស់ក្នុងព្រៃ !" ។

---

[116] ធម៌សម្រាប់សមណៈ សមថធម៌, ធម៌សម្រាប់អប់រំចិត្តឲ្យបានស្ងប់រម្ងាប់នូវកិលេសទាំងពួង

[117] ប្រទេសឬភ្នំមានទឹកសន្សើម ៖ ព្រៃហិមពាន្ត ភ្នំហិមពាន្ត ។ ខ្មែរប្រើក្លាយជាហេមពាន្ត ក៏មាន ប្រើក្លាយឃ្លាតទៅទៀតជា ហេម្ពពាន្ត ក៏មាន ព. កា. ប្រើជាហិមវ័ត ហេមវ័ត ហិមវ័ន្ត ហេមវ័ន្ត ហេមវា ក៏មាន សម័យសព្វថ្ងៃនេះលេចឮឈ្មោះក្នុងសកលលោកថា ហិមាល័យ ឬហិមាលយា ។

លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ព្រះអង្គបានពិពណ៌នាក្រុងមិថិលា
បន្តដូច្នេះ ៖

"កទាហំ មិថិលំ ផីតំ  វិភត្តំ ភាគសោ មិតំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ  វិសាលំ សព្វតោបភំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ  ពហុបាការតោរណំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ  ទឡ្ហមដ្ដាលកោដ្ឋកំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ  សុវិភត្តំ មហាបថំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ  សុវិភត្តន្តរាបណំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ  គវាស្សរថបីឡិតំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ  អារាមវនមាលិនិំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ  ឧយ្យានវនមាលិនិំ

បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ    ចាសាទវេធមាលិនិំ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិថិលំ ផីតំ    តិបុរំ រាជពន្ធុនិំ
មាបិតំ សោមនស្សេន    វេទេហេន យសស្សិនា
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ វេទេហេ ផីតេ    និចិតេ ធម្មរក្ខិតេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ វេទេហេ ផីតេ    អជេយ្យេ ធម្មរក្ខិតេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ អន្តេបុរំ រម្មំ    វិភត្តំ ភាគសោ មិតំ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ អន្តេបុរំ រម្មំ    សុធាមត្តិកលេបនំ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ អន្តេបុរំ រម្មំ    សុចិគន្ធំ មនោរមំ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ កូដាគារេ ច    វិភត្តេ ភាគសោ មិតេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ កូដាគារេ ច    សុធាមត្តិកលេបនេ

បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ កូដាគារេ ច សុចិគន្ធេ មនោរមេ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ កូដាគារេ ច លិត្តេ ចន្ទនផោសិតេ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ សោណ្ណបល្លង្កេ គោនកេ ចិត្តសន្ថតេ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មណិបល្លង្កេ គោនកេ ចិត្តសន្ថតេ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ កប្បាសកោសេយ្យំ ខោមកោដុម្ពានិ ច
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ បោក្ខរណី រម្មា ចក្កវាកបកូជិតា
មន្ទាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ ហត្ថិគុម្ពេ ច សព្វាលង្ការភូសិតេ
សុវណ្ណកច្ឆេ មាតង្គេ ហេមកប្បនវាសសេ ។
"អារូឡ្ហេ គាមណីយេហិ តោមរង្កុសបាណិភិ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ អស្សគុម្ពេ ច សព្វាលង្ការភូសិតេ

អាជានីយេវ ជាតិយា  សិន្ធវេ សីឃវាហនេ ។
“អារុឡ្ហេ គាមណីយេហិ  ឥល្លិយាចាបធារិភិ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
“កទាហំ រថសេនិយោ  សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ  សព្វាលង្ការភូសិតេ ។
“អារុឡ្ហេ គាមណីយេហិ  ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
“កទាហំ សោវណ្ណរថេ  សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ  សព្វាលង្ការភូសិតេ ។
“អារុឡ្ហេ គាមណីយេហិ  ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
“កទាហំ សជ្ឈុរថេ ច  សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ  សព្វាលង្ការភូសិតេ ។
“អារុឡ្ហេ គាមណីយេហិ  ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
“កទាហំ អស្សរថេ ច  សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ  សព្វាលង្ការភូសិតេ ។
“អារុឡ្ហេ គាមណីយេហិ  ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។

"កទាហំ ឱដ្ឋរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ ។
"អារូឡ្ហេ គាមណីយេហិ ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ គោណរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ ។
"អារូឡ្ហេ គាមណីយេហិ ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ អជរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ ។
"អារូឡ្ហេ គាមណីយេហិ ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មេណ្ឌរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ ។
"អារូឡ្ហេ គាមណីយេហិ ចាបហត្ថេហិ វម្មិភិ
បហាយ បព្វជិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ មិគរថេ ច សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ ។
"អារូឡ្ហេ គាមណីយេហិ ចាបហត្ថេហិ វម្មិភិ

បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។

"កទាហំ ហត្ថារោហេ ច    សព្វាលង្ការភូសិតេ
នីលវម្មធរេ សូរេ    តោមរង្កុសចាណិនេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។

"កទាហំ អស្សារោហេ ច    សព្វាលង្ការភូសិតេ
នីលវម្មធរេ សូរេ    ឥល្លិយាចាបធារិនេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។

"កទាហំ រថារោហេ ច    សព្វាលង្ការភូសិតេ
នីលវម្មធរេ សូរេ    ចាបហត្ថេ កលាបិនេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។

"កទាហំ ធនុគ្គហេ ច    សព្វាលង្ការភូសិតេ
នីលវម្មធរេ សូរេ    ចាបហត្ថេ កលាបិនេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។

"កទាហំ រាជបុត្តេ ច    សព្វាលង្ការភូសិតេ
ចិត្រវម្មធរេ សូរេ    កញ្ចនាវេឡធារិនេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។

"កទាហំ អរិយគណេ ច    វតវន្តេ អលង្កតេ
ហរិចន្ទនលិត្តង្គេ    កាសិកុត្តមធារិនេ
បហាយ បព្វជិស្សាមិ    តំ កុទាស្សុ ភវិស្សតិ ។

"កទាហំ អមច្ចគណេ ច  សព្វាលង្ការភូសិតេ
បីតវម្មធរេ សូរេ  បុរតោ គច្ឆមាលិនេ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ សត្តសតា ភរិយា  សព្វាលង្ការភូសិតា
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ សត្តសតា ភរិយា  សុសញ្ញា តនុមជ្ឈិមា
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ សត្តសតា ភរិយា  អស្សវា បិយភាណិនី
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ សតបលំ កំសំ  សោវណ្ណំ សតរាជិកំ
បហាយ បព្វជិស្សាមិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ ហត្ថិគុម្ពា  សព្វាលង្ការភូសិតា
សុវណ្ណកច្ឆា មាតង្គា  ហេមកប្បនវាសសា ។
"អារូឡ្ហា គាមណីយេហិ  តោមរង្កុសចាណិភិ
យន្តំ មំ នានុយិស្សន្តិ  តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ អស្សគុម្ពា  សព្វាលង្ការភូសិតា
អាជានីយាវ ជាតិយា  សិន្ធវា សីឃវាហនា ។
"អារូឡ្ហា គាមណីយេហិ  ឥល្លិយាចាបធារិភិ
យន្តំ មំ នានុយិស្សន្តិ  តំ កុទាស្សុ ភវិស្សតិ ។

"កទាស្សុ មំ រថសេនី　　សន្នទ្ធា ឧស្សិតទ្ធជា
ទីថា អថោបិ វេយ្យគ្ឃា　　សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ　　ចាបហត្ថេហិ វម្មិភិ
យន្តំ មំ ឆានុយិស្សន្តិ　　តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ សោណ្ណរថា　　សន្នទ្ធា ឧស្សិតទ្ធជា
ទីថា អថោបិ វេយ្យគ្ឃា　　សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ　　ចាបហត្ថេហិ វម្មិភិ
យន្តំ មំ ឆានុយិស្សន្តិ　　តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ សជ្ឈរថា　　សន្នទ្ធា ឧស្សិតទ្ធជា
ទីថា អថោបិ វេយ្យគ្ឃា　　សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ　　ចាបហត្ថេហិ វម្មិភិ
យន្តំ មំ ឆានុយិស្សន្តិ　　តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ អស្សរថា　　សន្នទ្ធា ឧស្សិតទ្ធជា
ទីថា អថោបិ វេយ្យគ្ឃា　　សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ　　ចាបហត្ថេហិ វម្មិភិ
យន្តំ មំ ឆានុយិស្សន្តិ　　តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ ឱដ្ឋរថា　　សន្នទ្ធា ឧស្សិតទ្ធជា
ទីថា អថោបិ វេយ្យគ្ឃា　　សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ　　ចាបហត្ថេហិ វម្មិភិ

យន្តំ មំ នានុយិស្សន្តិ	តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ គោណរថា	សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា	សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ	ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ	តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ អជរថា	សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា	សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ	ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ	តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ មេណ្ឌរថា	សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា	សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ	ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ	តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ មិគរថា	សន្នទ្ធា ឧស្សិតទ្ធជា
ទីបា អថោបិ វេយ្យគ្ឃា	សព្វាលង្ការភូសិតា ។
"អារូឡ្ហា គាមណីយេហិ	ចាបហត្ថេហិ វម្មិភិ
យន្តំ មំ នានុយិស្សន្តិ	តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ ហត្ថារោហា	សព្វាលង្ការភូសិតា
នីលវម្មធរា សូរា	តោមរង្កុសបាណិនោ

យន្តំ មំ នានុយិស្សន្តិ    តំ កុទាស្សុ ភវិស្សតិ ។
“កទាស្សុ មំ អស្សារោហា សព្វាលង្ការភូសិតា
នីលវម្មធរា សូរា    ឥល្លិយាចាបធារិនោ
យន្តំ មំ នានុយិស្សន្តិ    តំ កុទាស្សុ ភវិស្សតិ ។
“កទាស្សុ មំ រថារោហា    សព្វាលង្ការភូសិតា
នីលវម្មធរា សូរា    ចាបហត្ថា កលាបិនោ
យន្តំ មំ នានុយិស្សន្តិ    តំ កុទាស្សុ ភវិស្សតិ ។
“កទាស្សុ មំ ធនុគ្គហា    សព្វាលង្ការភូសិតា
នីលវម្មធរា សូរា    ចាបហត្ថា កលាបិនោ
យន្តំ មំ នានុយិស្សន្តិ    តំ កុទាស្សុ ភវិស្សតិ ។
“កទាស្សុ មំ រាជបុត្តា    សព្វាលង្ការភូសិតា
ចិត្រវម្មធរា សូរា    កញ្ចនាវេឡធារិនោ
យន្តំ មំ នានុយិស្សន្តិ    តំ កុទាស្សុ ភវិស្សតិ ។
“កទាស្សុ មំ អរិយគណា វតវន្តា អលង្កតា
ហរិចន្ទនលិត្តង្គា    កាសិកុត្តមធារិនោ
យន្តំ មំ នានុយិស្សន្តិ    តំ កុទាស្សុ ភវិស្សតិ ។
“កទាស្សុ មំ អមច្ចគណា សព្វាលង្ការភូសិតា
បីតវម្មធរា សូរា    បុរតោ គច្ឆមាលិនោ
យន្តំ មំ នានុយិស្សន្តិ    តំ កុទាស្សុ ភវិស្សតិ ។

"កទាស្សុ មំ សត្តសតា ភរិយា សព្វាលង្ការភូសិតា
យន្តំ មំ នានុយិស្សន្តិ តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ សត្តសតា ភរិយា សុសញ្ញា តនុមជ្ឈិមា
យន្តំ មំ នានុយិស្សន្តិ តំ កុទាស្សុ ភវិស្សតិ ។
"កទាស្សុ មំ សត្តសតា ភរិយា អស្សវា បិយភាណិនី
យន្តំ មំ នានុយិស្សន្តិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ បត្តំ គហេត្វាន មុណ្ឌោ សង្ឃាដិបារុតោ
បិណ្ឌិកាយ ចរិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ បំសុកូលានំ ឧជ្ឈិតានំ មហាបថេ
សង្ឃាដឹ ធារយិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ សត្តាហសម្មេឃេ ឱវដ្ឋោ អល្លចីវរោ
បិណ្ឌិកាយ ចរិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ សព្វត្ថ គន្ត្វា រុក្ខា រុក្ខំ វនា វនំ
អនបេក្ខោ គមិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ គិរិទុគ្គេសុ បហីនភយភេរវោ
អទុតិយោ គមិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ វីណំវ រុជ្ជកោ សត្តតន្តឹ មនោរមំ
ចិត្តំ ឧជុំ ករិស្សាមិ តំ កុទាស្សុ ភវិស្សតិ ។
"កទាហំ រថការោវ បរិកន្តំ ឧបាហនំ

កាមសញ្ញោជនេ ឆេត្វា       យេ ទិព្វេ យេ ច មានុសេ” ។

“ក្រុងមិថិលា ជាក្រុងសម្បូណ៌ដោយសំពត់និងគ្រឿងអលង្ការដ៏ស្រស់ស្អាត ដែលចែកចេញជាស្ថានទាំងឡាយ មានរាជនិវេសនដ្ឋានជាដើម ហើយស្ថានទាំងនោះត្រូវបានខណ្ឌចែកដោយចំណែកនៃទ្វារហើយនិងថ្នល់ ជាក្រុងទូលាយ មានពន្ទឹជុំវិញ មានកំពែងនិងខ្លោងទ្វារដ៏ច្រើន មានប៉មនិងស៊ុមទ្វារដ៏មាំមួន ជាក្រុងចែកល្អ មានផ្លូវធំ មានរានផ្សារ ដ៏កុះករដោយគោ សេះ និងរថ ព្រៃសួនឧទ្យានក៏មានរបៀបរៀបរយល្អ ប្រាសាទមានកំពែង ៣ ជាន់ មានព្រះរាជវង្សានុវង្សជាច្រើនគង់អាស្រ័យនៅ ដែលតមកពីព្រះបាទវិទេហៈនាមសោមនស្សទ្រង់សាងទុក ។ ដែនវិទេហៈជាដែនបរិបូណ៌ដោយការសន្សំនូវធញ្ញាហារ[១១៨]ជាដើម ជាដែនដែលត្រូវបានរក្សាដោយធម៌ ដែលបច្ចាមិត្រ[១១៩]ផ្ចាញ់មិនបាន ។ រីឯខាងក្នុងបុរីវិញ ជាទីរីករាយ មានការបែងចែកជាចំណែក ៗ បូកលាបដោយកំបោនិងដី មានក្លិនក្រអូបជាទីរីករាយចិត្ត ។ ដំណាក់កំពូលទាំងឡាយ ចែកជាផ្នែក ៗ បូកលាប

---

[១១៨] អាហារកើតពីស្រូវគ្រប់ប្រភេទ មានស្រូវស្រងែ និងពោតជាដើម ។

[១១៩] អមិត្ត សត្រូវ បច្ចាមិត្តតូចតាច អាចនឹងបង្កឲ្យកើតជាទោសសត្រូវធំបាន ដូចជាបូសទ្រនិចតូចមួយ ឬដូចជារលកកែវតូចមួយ អាចនឹងក្លាយទៅជាជំងឺធ្ងន់បានដូច្នោះដែរ ។

ដោយកំបោនិងដី មានក្លិនក្រអូបជាទីរីករាយនៃចិត្ត ប្រោះព្រំ[១២០] ដោយខ្លឹមចន្ទន៍ក្រហម[១២១] ។ គ្រែមាសទាំងឡាយ និងបល្ល័ង្កកែវមណី មានព្រំជាកម្រាលដ៏វិចិត្រ ។ សំពត់អំបោះ សំពត់សូត្រ និងសំពត់ផ្សេងទៀត សុទ្ធតែនាំមកអំពីដែនខោមៈ និងដែនកោទុម្ពរៈ ។ ស្រះបោក្ខរណី[១២២] ទាំងឡាយ ជាទីរីករាយ មានសត្វចាក្រពាកយំទ្រហឹង ដេរដាសដោយចង្កុលណី[១២៣] ផង ដោយឈូក និងព្រលឹត[១២៤] ផង ។ ហ្វូងដំរីមាតង្គៈដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ មានខ្សែដង្កន់[១២៥] មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរីឡើងជិះ មានលំពែងស្នែងក្របីនិងកង្វេរក្នុងដៃ ។ ហ្វូងសេះអាជានេយ្យអំពីកំណើតជា

---

[១២០] ប្រោះទឹកបំព្រំ គឺប្រោះទឹកថែមហើយថែមទៀតញយ ៗ ។

[១២១] ចន្ទន៍ក្រហម ជាឈើមានខ្លឹមក្លិនក្រអូប ។

[១២២] ស្រះមានឈូក ស្រះឈូក ។

[១២៣] ឈ្មោះវារិជជាតិមួយប្រភេទ ពួកឈូក មានកេសរផ្កាច្រើនស្រទាប់ ផ្កាបែកជាខ្នែងតពីគ្នាជាបី ឬ ជាបួនទៅទៀតក៏មាន ។

[១២៤] ឈ្មោះឧប្បលពួកមួយដុះក្នុងទឹក លូតតាមទឹក មានដើមមូលត្រសូល ប្រើធ្វើជាបន្លែឬអន្ទក់បាន ព្រលឹតមានច្រើនប្រភេទ ខ្លះដើមស្រួយ ខ្លះដើមស្វិត ខ្លះផ្កា-ស ខ្លះផ្កាលឿង ។ល។

[១២៥] (ន.) ខ្សែផ្តៅវេញទាំងមូល សម្រាប់ចងរឹតកូបឬរយាង, ញ៉ែងពទ្ធតាមទ្រូងដំរី ។

សេះសិន្ធពមនោម័យ[១២៦] ស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ ជាវាហនៈលឿនរហ័សទាន់ចិត្ត ដែលអ្នកបង្ហាត់សេះ កាន់សែ៊[១២៧]និងធ្នូឡើងជិះ ។ ពួករថ រថមាស រថប្រាក់ រថសេះ រថឱដ្ឋ រថគោ រថកែស រថពពែ រថម្រឹគ ប្រដាប់ហើយមានទង់លើកឡើង ទាំងបិទបាំងដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីឡើងជិះ ទាំងមានធ្នូនិងខែលក្នុងដៃ ។ ពួកអ្នកជិះដំរីពួកអ្នកជិះសេះ ពួកអ្នកជិះរថ ពួកខ្មាន់ធ្នូ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នែងក្របី កង្វេរ សែ៊ ធ្នូ និងបំពង់ព្រួញក្នុងដៃ ។ ពួករាជបុត្រី ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាសនិងកែវពិទូរ្យ[១២៨] ។ ពួកអរិយជន គឺព្រាហ្មណ៍ដែលមានសំពត់ មានគ្រឿងប្រដាប់ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ស្លៀកដណ្តប់ដោយសំពត់ ដែលបានមកអំពីដែនកាសីដ៏ឧត្តម ។

---

[១២៦] សេះសិន្ធពដែលមានល្បឿនលឿនរហ័សទាន់ចិត្ត ។

[១២៧] (ន.) ប្រដាប់ធ្វើដោយសំណុំសក់កន្ទុយសេះមានដងសម្រាប់កាន់វាយវាត់កម្ចាត់សុខុមសត្វមានស្វាប មានមូស រុយជាដើម (រាជសព្ទ ហៅថា ព្រះវាលវីជនី) ។ (គុ.) ដែលមានខ្នងអែន គូទ-ងបន្តិច : ខ្នងអែនស្បៃ រាងសែ៊ ។

[១២៨] (ន.) (សំ.), (បា.) (វៃទូយ៌ វេឡុរិយ) ពេជ្រក្នែកឆ្មា : កែវពិទូរ្យ, ត្បូងពិទូរ្យ ។

ពួកអាមាត្យ បំពាក់ដោយគ្រឿងអលង្ការទាំងពួង កាន់ខែល មានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ ។ ពួកស្រីស្នំ ៧០០ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាអ្នកសង្រួមល្អ មានចង្កេះរៀវ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ។ ភាជន៍មាសទម្ងន់ ១០០ បលៈ ប្រកបដោយក្បាច់ចម្លាក់ ១០០ ។ តើឱកាសលះបង់ពួកមនុស្សនិងរបស់អស់ទាំងនេះ ហើយចេញសាងផ្នួស នឹងសម្រេចដល់អញក្នុងកាលណាហ្ន៎ ? តើពេលណាទៅ ហ្វូងដំរីមាតង្គៈ ហ្វូងសេះ ពួករថ ពួករថមាស ពួករថប្រាក់ រថសេះ រថឱដ្ឋ រថគោ រថកែស រថពពែ រថម្រឹគ របស់អញ ប្រដាប់ហើយ មានទង់លើកឡើង ទាំងបិទបាំងដោយស្បែកខ្លាដំបងនិងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីឡើងជិះ ទាំងមានលំពែងស្នែងក្របី កង្វេរ ស៊ែ ធ្នូ ខែល និងបំពង់ព្រួញក្នុងដៃ មិនទៅតាមអញពេលចេញបួស ? តើពេលណាទៅ ពួកអ្នកជិះដំរី អ្នកជិះសេះអ្នកជិះរថ ពួកខ្មាន់ធ្នូរបស់អញ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែល មានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នែងក្របី កង្វេរ ស៊ែ ធ្នូ ខែលនិងបំពង់ព្រួញក្នុងដៃ មិនទៅតាមអញ ពេលចេញបួស ? តើពេលណាទៅ ពួករាជបុត្រស្អិតស្អាង

ដោយគ្រឿងអលង្ការ[១២៩] ទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាសនិងកែវពិទូរ្យ មិនទៅតាមអញ ពេលចេញបួស ? តើពេលណាទៅ ពួកអរិយជន គឺព្រាហ្មណ៍អ្នកមានសំពត់ មានគ្រឿងប្រដាប់ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ស្លៀកដណ្ដប់ដោយសំពត់ដ៏ឧត្តមដែលបានមកអំពីដែនកាសី មិនទៅតាមអញ ពេលចេញបួស ? តើពេលណាទៅ ពួកអាមាត្យរបស់អញដែលបំពាក់ដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ មិនទៅតាមអញ ពេលចេញបួស ? តើពេលណាទៅ ពួកស្រីស្នំ ៧០០ របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាស្ត្រីសង្រួមល្អ មានចង្កេះរៀវ ជាស្ត្រីស្ដាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ មិនទៅតាមអញ ពេលចេញបួស ? តើពេលណាទៅ អញបានកោរព្រះកេសា ឃុំសង្ឃាដី[១៣០] កាន់

[១២៩] គ្រឿងប្រដាប់សម្រាប់តាក់តែងខ្លួន (មានចិញ្ចៀន កង ខ្សែដៃ ខ្សែខ្លួន ជាដើម) : ព្រះមហាក្សត្រិយ៍ទ្រង់តែងព្រះអង្គដោយអលង្ការដ៏បវរអន័ឃ្ស ។

[១៣០] (ន.) (បា.) (តាមទម្លាប់ សង់ឃ្ដី ដើង ដ) (សង្ឃាដិ) សំពត់ឃ្លុបឬសំពត់សម្រាប់ពាក់ពាត គឺសំពត់ដែលដេរត្របគ្នាជាពីរជាន់ឬបួនជាន់ មានផ្ទាំង ខ្នង់ សង្កាត់ដូចគ្នានឹងឧត្តរាសង្គៈដែរ, ជាបរិក្ខាររបស់បព្វជិតពុទ្ធសាសនិក, សម្រាប់ប្រើឃ្លុំការពាររងា, សម្រាប់បត់ជាផ្នត់ពាក់ពាតលើឧត្តរាសង្គៈក្នុងកាលធ្វើសង្ឃកម្ម ឬបត់ប្រើជាកម្រាល

បាត្រ ត្រាច់ចរបិណ្ឌបាត ? តើពេលណាទៅ អញបានទ្រទ្រង់សង្ឃាដី ជាសំពត់បង្សុកូល[១៣១] ដែលគេចោលក្នុងផ្លូវធំ ? តើពេលណាទៅ អញបានត្រាច់ទៅបិណ្ឌបាតទាំងចីវរទទឹក ពេលកំពុងធ្លាក់ភ្លៀង ៧ ថ្ងៃ ជាប់គ្នា ? តើពេលណាទៅ អញបានចេញពី

---

សិងមួយដងមួយកាលក៏បាន : ភិក្ខុតម្រួតសង្ឃាដីជាមួយនឹងឧត្តរាសង្គៈ ឃ្លុំចូលទៅក្នុងភូមិ ភិក្ខុពាក់សង្ឃាដីធ្វើឧបោសថកម្ម ។

[១៣១] (ន.) គំនរអាចម៍ដី, គំនរធូលីឬអ្វី ៗ ដែលប្រឡាក់, ដែលសៅហ្មងដោយអាចម៍ដី, ដោយធូលី ។ សំពត់ដែលគេចោលលើគំនរសំរាមជាដើម ប្រឡាក់សៅហ្មងដោយអាចម៍ដី, ដោយធូលីដែលបព្វជិតក្នុងពុទ្ធសាសនា ទស់ដោយសម្គាល់ថា ជារបស់ឥតម្ចាស់ ព្រោះគេបោះបង់ចោល លែងត្រូវការហើយទាញយកមកផ្សែផ្សំធ្វើជាចីវរប្រើប្រាស់តាមពុទ្ធានុញ្ញាត (ចំពោះតែសំពត់មានពណ៌សឬលឿង ដែលល្មមយកមកជ្រលក់សម្រួលពណ៌បាន រាប់ថាជាសំពត់ថ្លៃថ្លាវិសេស សម្រាប់បព្វជិតអ្នកមានសន្តោសស្ងប់រម្ងាប់) ។ លុះដល់មកក្នុងសម័យសព្វថ្ងៃនេះ សូម្បីសំពត់ដែលទាយកគេពាក់ឬគ្របលើក្តារមឈូសជាដើម គេនិមន្តឲ្យបព្វជិតទាញយកទៅទីចំពោះមុខគេ ឬកំបាំងពីមុខគេក៏ហៅសំពត់បង្សុកូលដែរ ។ ខ្មែរយើងប្រើតាមទម្លាប់ប្រទេស, ហៅដំណើរដែលគេនិមន្តភិក្ខុសាមណេរ ឲ្យចាប់កាន់អំបោះ ឬផ្គាំងសំពត់ដែលតភ្ជាប់ពីសាកសព ឬពីអដ្ឋិធាតុមកសូត្រធម៌ អនិច្ចា វត សង្ខារា... ក៏ហៅបង្សុកូល ដែរ ច្រើនប្រើជា កិ. ឬ គុ. ថា និមន្តលោកបង្សុកូល, ធម៌បង្សុកូល បើក្នុងព្រះបរមរាជវាំង ច្រើនប្រើពាក្យថា និមន្តលោកសត្តប្បករណ៍ ជាពាក្យហៅកាត់ខ្លីក្លាយមកពីពាក្យថា និមន្តលោកសូត្រសត្តប្បករណាភិធម្ម គឺនិមន្តលោកសូត្រព្រះអភិធម្ម ៧ គម្ពីរ (ដោយសង្ខេប) ។ល។

ដើមឈើមួយ ទៅដើមឈើមួយ ពីព្រៃមួយទៅព្រៃមួយ រហូតថ្ងៃនិងយប់ ត្រាច់ទៅឥតអាឡោះអាល័យ[១៣២] ? តើពេលណាទៅ អញបានលះបង់នូវភ័យគួរខ្លាច ហើយមានខ្លួនតែម្នាក់ឯងដើរទៅលើជ្រោះភ្នំទាំងឡាយ ? តើពេលណាទៅ អញបានធ្វើចិត្តឲ្យត្រង់ដូចជាអ្នកដេញពិណ អាចដេញខ្សែទាំង ៧ ឲ្យជាទីរីករាយចិត្តបាន ? តើពេលណាទៅ អញបានកាត់នូវកាមសំយោជន៍[១៣៣]ជាទិព្វ ទាំងជារបស់មនុស្សបាន ដូចជាជាងរថកាត់ស្បែកជើង ? តើបំណងទាំងនេះ នឹងសម្រេចក្នុងកាលណាហ្ន៎ ?

## ស្តេចមហាជនកយាងចេញសាងផ្នួស

តាមដែលបានឮមកថា មហាជនកពោធិសត្វកើតក្នុងសម័យមនុស្សអាយុ ១០.០០០ ឆ្នាំ សោយរាជ្យ ៧.០០០ ឆ្នាំ, សាងផ្នួសក្នុងព្រះជន្មដែលសេសសល់ ៣.០០០ ។ ប៉ុន្តែមុននឹងចេញសាងព្រះផ្នួស ស្តេចមហាជនកនៅក្នុងប្រាសាទ នារាជវាំង អស់ ៤ ខែ រាប់ចាប់តាំងពីកាល

---

[១៣២] អាឡោះអាល័យ អាល័យក្រៃពេក អាល័យខ្លាំង អាល័យមិនដាច់ នឹកស្រណោះស្រងោចចិត្តទៅរក ។

[១៣៣] កិលេសជាគ្រឿងប្រកបចិត្ត ឲ្យជាប់ក្នុងកាមគឺកិលេសរឹងត្អឹងជាគ្រឿងទាក់ទាក់រួបរឹតចិត្តទុកក្នុងកាម កិលេសដែលអាស្រ័យនៅនឹងចិត្ត ហើយបណ្តាលចិត្តរមៀលធ្លាក់ទៅក្នុងកាម ។

ដែលទ្រង់បានទតឃើញនូវដើមស្វាយទៀបទ្វារឧទ្យាន ទ្រង់បានព្រះតម្រិះថា ៖

"ភេទអ្នកបួស ប្រសើរជាងភេទស្ដេចគ្រប់គ្រងផែនដីនេះ
អញនឹងត្រូវតែបួស" ។

លុះមានរាជតម្រិះដូច្នេះហើយ ទ្រង់ត្រាស់បញ្ជារាជបម្រើភ្ជាមថា ៖

"នែប្រស្ដែង[១៣៤]អើយ, ឯងចូរកុំឲ្យនរណាម្នាក់ដឹងឲ្យសោះ,
ចូរទៅទិញសំពត់កាសាយៈនិងបាត្រដី អំពីផ្សារមក" ។

បុរសជារាជបម្រើបានធ្វើតាមព្រះរាជបញ្ជាដូច្នោះ ហើយត្រូវព្រះរាជាប្រើមួយសាទៀត ឲ្យទៅហៅខ្មាន់ព្រះកេស មកឲ្យកោរកេសា ពុកមាត់ពុកចង្កា ហើយទ្រង់ព្រះរាជទានស្រុកសួយដល់ខ្មាន់ព្រះកេស រួចឲ្យខ្មាន់ព្រះកេសត្រឡប់ទៅវិញ, បន្ទាប់មក ទ្រង់ស្លៀកសំពត់កាសាវៈមួយផ្ទាំង ដណ្ដប់មួយផ្ទាំង ពាក់ឆៀងស្មាមួយផ្ទាំង ប្រកបាត្រដីក្នុងស្លាករួចពាក់លើស្មា ។ តមក ស្ដេចទ្រង់កាន់ឈើច្រត់ដើរចង្ក្រម[១៣៥]ជា

---

[១៣៤] អ្នក នាយ ចៅ បា ឬរ៉ឺយ រ៉ី ពាក្យសម្រាប់ឥស្សរជនហៅមនុស្សស្និទ្ធស្នាលដែលនៅក្រោមបង្គាប់របស់ខ្លួន : ម្នាលព្រះស្ដែង! នែព្រះស្ដែង ហៅដោយមេត្តាប្រណីទៅរកអ្នកតូចទាបទន់ខ្សោយក៏បាន : ម្នាលប្រស្ដែងប្រេតអើយ! ។

[១៣៥] ដំណើរដើរទៅដើរមក ដំណើរទៅមក ៗ គឺដំណើរទៅហើយដើរមកវិញយឺត ៗ ច្រើនបកច្រើនសា : ព្រះមហាថេរដើរចង្ក្រម ផ្លូវចង្ក្រម ។ ប្រើជា កិ. ក៏មាន : ព្រះមហាថេរកំពុងចង្ក្រម ។

បែបព្រះបច្ចេកពុទ្ធទៅមក ៗ ពីរបីគ្រឡប់ ក្នុងព្រះរាជមន្ទីរ ។ ព្រះមហាក្សត្រស្នាក់នៅទីនោះអស់ពេលមួយថ្ងៃ លុះដល់មកថ្ងៃបន្ទាប់ វេលាព្រះអាទិត្យរះឡើង ទ្រង់យាងចុះចាកប្រាសាទ ។

# ជំពូកទី ៥

# ចេតិយអនុស្សាវរីយ៍

## សីវលីទេវីរត់តាមតាបសមហាជនក

*គ្រានោះ ព្រះរាជអគ្គមហេសីសីវលីទេវី ប្រើគេឲ្យទៅហៅស្រីស្នំ ទាំង ៧០០ នាក់ចូលមកជួបខ្លួន ហើយមានព្រះសវនីយ៍[១៣៦]ប្រាប់ថា ៖*

*"ពួកយើងខានចូលគាល់អង្គព្រះមហាក្សត្រយូរហើយ គិតមកត្រឹមនេះ ៤ ខែទៅហើយ, ថ្ងៃនេះ ពួកយើងនឹងចូលគាល់ព្រះមហាក្សត្រម្ដង, សូមពួកនាងតុបតែងខ្លួនដោយគ្រឿងអលង្ការទាំងពួងសម្ដែងនូវដំណើរកែក្រាយ[១៣៧] ញែងញ៉ង លាយដោយសំណើចនិងចរិតទាក់ទាញតាមកិច្ចកលរបស់ស្ត្រី ឲ្យអស់ពីសមត្ថភាព ចូរព្យាយាមយ៉ាងណាដើម្បីចងព្រះអង្គឲ្យបានដោយចំណងគឺកិលេស" ។*

*ត្រាស់បង្គាប់ដូច្នេះហើយ ព្រះនាងសីវលីទេវីមួយអន្ទើដោយស្រីស្នំទាំងនោះ ដែលតុបតែងខ្លួនរួចរាល់ហើយ បាននាំគ្នាឡើងទៅប្រាសាទ*

---

*[១៣៦] ដែលគួរស្ដាប់ ដែលត្រូវស្ដាប់ ។ ន. សម្ដីដែលគួរឬត្រូវស្ដាប់ ។ ខ្មែរប្រើជា រ. ស. ចំពោះតែព្រះបន្ទូលរបស់សម្ដេចព្រះវររាជជននី ឬសម្ដេចព្រះអគ្គមហេសី សម្ដេចព្រះមហាក្សត្រិយានី : ទទួលព្រះសវនីយ៍ ។*

*[១៣៧] (កិ.) ដើរយាងយាសទៅមក ដូចដំណើរល្ខោនរាំ : កែក្រាយចូលទៅ ។*

*(គុ.) ដែលមានដំណើរយាងយាស បែបដំណើរល្ខោនរាំ : ដំណើរកែក្រាយ ។*

ដើម្បីគាល់ព្រះរាជា គាប់ចួនបានឃើញព្រះរាជានៅតាមជណ្ដើរប្រាសាទ ដែលស្ដេចកំពុងយាងចុះមកមួយអង្គឯង ម្នាក់ ៗ ក៏ពុំចាប់ភ្ញីកចំណាំបានឡើយ នឹកស្មានថា "ជាព្រះបច្ចេកពុទ្ធនិមន្តមកផ្ដល់ឱវាទចំពោះព្រះរាជា" ក៏នាំគ្នាក្រាបថ្វាយបង្គំ រួចឈរក្នុងទីដ៏សមគួរ ។

ចំណែកព្រះមហាក្សត្រ ក៏ស្ដេចទ្រង់យាងចុះចាកប្រាសាទមក ។ រីឯព្រះនាងសីវលីទេវី យាងឡើងទៅដល់ប្រាសាទ ចោលនេត្រាទៅលើស្រីសយនាក្រឡាព្រះបន្ទំអង្គព្រះមហាក្សត្រ ឃើញតែព្រះកេសាដ៏រលោងដូចពណ៌សត្វកមរជាតិ[១៣៨] និងឃើញនូវគ្រឿងប្រសាធន៍[១៣៩]ផងទាំងពួង បាននឹកចាប់ភ្ញីកទៅដោយមានព្រះសវនីយ៍ថា ៖

"ឱ ! អ្នកដែលដើរចុះចាកប្រាសាទនោះ ពុំមែនជាព្រះបច្ចេកពុទ្ធទេ, ជាក់ជាព្រះរាជស្វាមីសម្លាញ់ចិត្តរបស់យើងហើយ តោះពួកនាងខ្ញុំនឹងអង្វរឲ្យព្រះអង្គវិលត្រឡប់មកវិញ" ។

លុះទ្រង់មានព្រះសវនីយ៍ដូច្នេះហើយ ព្រះនាងក៏ប្រញាប់រូតរះចុះចាកមហាតលដ្ឋាន ស្រូតដំណើរទៅដល់ព្រះលានហ្លួង ។ លុះទៅដល់ហើយ ព្រះនាងព្រមទាំងស្រីស្នំទាំងអស់នោះ ម្នាក់ ៗ រំសាយកេសាឲ្យ

---

១៣៨ (ន.) (បា.) (សំ.) (ក:ម:រ:ជាត) (ក្រមរ--) សត្វល្អិតពួកកន្ធង់ ឃ្មុំ ព្រួត, ម្រោម, យុក ជាកមរជាតិ ។

១៣៩ (ន.) (សំ.)(បា.) --ធ:ន:) (ប្រសាធន់ សាធន) អលង្ការ (គ្រឿងប្រដាប់កាយ) : ប្រដាប់កាយដោយប្រសាធន:ផ្សេងៗ ។

ធ្លាក់រាត់រាយលើព្រះបិដ្ឋិ[១៤០] ហត្ថាទាំងទ្វេគក់ព្រះឱរា ខ្សឹកខ្សួល មុខគួរឲ្យអាណិតអាសូរជាពន់ពេក រត់តាមព្រះរាជាជង្ហោយ[១៤១] ហៅថា ៖

"បពិត្រមហារាជ តើហេតុអ្វីបានជាព្រះអង្គធ្វើអំពើបែបនេះ" ។ មហាជននៅទូទាំងនគរ ក៏កើតសេចក្តីភ្ញាក់ផ្អើលគ្រប់ ៗ គ្នា យំត្អូញត្អែរអាឡោះអាល័យថា ៖

"ស្ដេចយើងចេញបួសហើយ, តើយើងនឹងបានស្ដេចគ្រប់គ្រង
រាស្ត្រដោយធម៌បែបនេះ អំពីទីណាទៀត" ដូច្នេះហើយម្នាក់ ៗ
នាំគ្នារត់តាមព្រះរាជាដែរ ។

ពួកស្រីស្នំ[១៤២] ទាំង ៧០០ នាក់ជាស្ត្រីសង្ហមល្អ មានចង្កេះរៀវ ជាស្ត្រីស្តាប់បង្គាប់ មានសម្តីគួរជាទីស្រឡាញ់ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង បានផ្គងដើមដៃ[១៤៣] ទួញយំថា ៖

"ព្រះអង្គនឹងបោះបង់ចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី ?"

ចំណែកព្រះបាទមហាជនក ទ្រង់បានលះបង់ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាស្ត្រីសង្ហម

---

[១៤០] ចំណែករាងកាយមនុស្ស និងសត្វត្រង់ប៉ែកខាងក្រោយពីត្រឹមស្មាទាំងពីរចុះទៅដល់ចង្កេះ : ខ្នងមនុស្ស, ខ្នងសត្វ ។

[១៤១] បន្លឺកហៅពីចម្ងាយ : ស្រែកជង្ហោយ, ជង្ហោយហៅ ។

[១៤២] (ន.) ស្ត្រីអ្នកបម្រើក្សត្រិយ៍ទ្រង់រាជ្យ ស្ត្រីក្នុងព្រះរាជវាំង : ស្រីស្នំ ពួកព្រះស្នំ ។

[១៤៣] (ន.) គល់ដៃ ភាគខាងដើមនៃដៃ គឺបន្ទាប់ពីស្មាចុះមក ។

ល្អ មានចង្កេះរៀវ ជាស្ត្រីស្តាប់បង្គាប់ មានសម្តីគួរជាទីស្រឡាញ់ ចេញសាងព្រះផ្នួសហើយ ។ ព្រះបាទមហាជនកទ្រង់លះបង់ភាជន៍[១៤៤]មាសទម្ងន់ ១០០ បល្វៈ វិចិត្រ[១៤៥]ដោយចម្លាក់ ១០០ ស្នាម បានកាន់យកនូវបាត្រដី[១៤៦] ។ ការកាន់នូវបាត្រដីនោះ ទុកជាការអភិសេកលើកទី ២ របស់ព្រះអង្គ ។

## សីវលីទេវីក្លែងធ្វើភ្លើងឆេះវាំង

ថ្លែងអំពីព្រះនាងសីវលីទេវីឯណោះវិញ ទោះបីព្រះនាងទ្រង់ព្រះកន្សែង[១៤៧]ខ្សឹកខ្សួល ដោយក្តីក្ដុកក្តួល វិយោគ[១៤៨]សោកស្តាយ[១៤៩]

---

[១៤៤] (ន.) (ភាជៈនៈ ឬ ភាច) ភាជន៍ប្រដាប់សម្រាប់ដាក់ភោជនាអាហារមានបាយជាដើម : ភោជនមួយភាជនៈ ភាជន៍មាស ។ សរសេរជា ភាជន៍ ។

[១៤៥] (គុ.) (សំ.បា.)(--ចិត) វិចិត្រ វិចិត្ត ឬ វិចិត្រ ក៏មានខ្លះ ដោយយក សំ. មកប្រើ ដែលលាយចម្រុះ ឬរំលេចពណ៌ ដែលរំលេច ឬឆ្លាស់ក្បាច់រចនា ដែលឆ្លុះឆ្លាស់ ល្អប្លែក (ច្រើនប្រើ វិចិត្រ ជាង) : របស់វិចិត្រ ការវិចិត្រ ក្បាច់វិចិត្រ ល្អវិចិត្រ ។ ប្រើជា កិ. ក៏បាន : ខំវិចិត្រឲ្យល្អប្លែក ។ អាចប្រើជាបទសមាសដោយផ្សំជាមួយនឹងសព្ទដទៃបានតាមការគួរដល់ការប្រកបប្រើដូចជា វិចិត្តកម្ម វិចិត្តការ ឬ វិចិត្រការ្យ វិចិត្តកណ្ឋ ។ល។

[១៤៦] បាត្រធ្វើដោយដីមានរាងជ្រៅក្រឡូមសម្រាប់បព្វជិតក្នុងពុទ្ធសាសនាប្រើការទទួលចង្ហាន់ : បាត្រដី ។

[១៤៧] (កិ.) យំ (រ. ស.) : ទ្រង់ព្រះកន្សែង ហៅតាមការដែលទ្រង់យកព្រះកន្សែងជូតព្រះអស្សុជល ទឹកព្រះនេត្រ ។

អាឡោះអាល័យយ៉ាងណា ក៏ពុំអាចញ៉ាំងព្រះភស្តា[១៥០] ជាព្រះរាជស្វាមីសំណព្វព្រះទ័យឲ្យត្រឡប់វិញបាន ព្រះនាងក៏ទ្រង់ព្រះចិន្តាថា ៖

"មានតែប្រើឧបាយកលទេ ទើបញ៉ាំងព្រះស្វាមីឲ្យត្រឡប់វិញបាន" ។

លុះទ្រង់ព្រះចិន្តាដូច្នេះហើយ ព្រះនាងក៏ត្រាស់ប្រើរាជបម្រើឲ្យទៅហៅលោកមហាសេនគុត្តមកជួប រួចបង្គាប់ថា "លោកសេនាបតីអើយ, លោកចូរដុតផ្ទះចាស់ ៗ និងរោងចាស់ ៗ ជាដើម ត្រង់ទិសទៅខាងមុខរបស់ព្រះរាជា ហើយប្រមូលស្មៅនិងស្លឹកឈើដុតបង្ហុយផ្សែងក្នុងទីនោះ ៗ ផងចុះ" ។ លោកសេនាបតីមហាសេនគុត្តនោះ ក៏ចាត់សេនាខ្លួនឲ្យរៀបចំធ្វើដូច្នោះ ។ ចំណែកព្រះនាងសីវលីទេវីយាងទៅសម្មាក់ព្រះរាជា ពុតធ្វើជាដួលទៀបព្រះបាទាព្រះអង្គ រាយការណ៍អំពីភ្លើងឆេះទូទៅក្នុងក្រុងមិថិលាថា ៖

---

[១៤៨] (ន.) (សំ.បា.) ការព្រាត់ប្រាស (ចាកបុគ្គលឬអ្វី ៗ ដែលស្រឡាញ់ពេញចិត្ត) : មានវិយោគ, កើតវិយោគ ។

[១៤៩] យំស្តាយអាល័យរបស់ជាទីស្រឡាញ់ដែលបាត់បង់ព្រាត់ប្រាស ។ ស្តាយខ្លាំងរហូតដល់យំសោក : សោកស្តាយកូនដែលស្លាប់ សោកស្តាយទ្រព្យដែលបាត់។ បើស្តាយល្មម ៗ មិនដល់យំសោកទេគួរកុំប្រើថាសោកស្តាយឡើយ ប្រើត្រឹមពាក្យថាស្តាយបានហើយ ។

[១៥០] ស្វាមី (ប្ដី) ខ្មែរប្រើជារាជសព្ទ : ព្រះភស្តា សម្ដេចព្រះភស្តា (ច្រើនប្រើក្នុងកាព្យទេស្នា ឬ កាព្យ) ។

"ឃ្លាំងទាំងឡាយគឺឃ្លាំងប្រាក់ ឃ្លាំងមាស ឃ្លាំងកែវមុក្តា ឃ្លាំងកែវពិទូរ្យ ឃ្លាំងកែវមណី ឃ្លាំងសង្ខ[១៥១] ឃ្លាំងកែវមុក្តាដ៏ច្រើន ឃ្លាំងសំពត់ ឃ្លាំងខ្លឹមចន្ទន៍ក្រហម ឃ្លាំងស្បែកខ្លាឃ្មុំ ឃ្លាំងរបស់ធ្វើអំពីក្អុក ឃ្លាំងទង់ដែង និងឃ្លាំងដែកខ្មៅដ៏ច្រើន ជាឃ្លាំងដែលរាជបុរសរៀបចំឲ្យនៅដាច់ដោយឡែកពីគ្នា ត្រូវភ្លើងឆេះមានអណ្តាតភ្លើងស្មើគ្នា គួរខ្លាចពេកក្រៃ បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យទ្រព្យរបស់ព្រះអង្គនោះវិនាស" ។

គ្រានោះ ព្រះមហាសត្តត្រាស់បំភ្លឺថា ៖

"ម្នាលនាងទេវី នាងថាម៉េច, បុគ្គលទាំងឡាយដែលមានសេចក្តីក្រវល់ក្រវាយ សេចក្តីក្រវល់ក្រវាយនោះ នឹងដុតនូវបុគ្គលទាំងឡាយនោះ, រីឯអាត្មាមិនមានសេចក្តីក្រវល់ក្រវាយឡើយ" ។

បំភ្លឺដូច្នេះហើយ ទ្រង់ត្រាស់បន្តថា ៖

"កាលបើយើងមិនមានកង្វល់ យើងនឹងរស់នៅជាសុខ កាលបើក្រុងមិថិលាត្រូវភ្លើងឆេះ ភ្លើងមិនមែនឆេះនូវទ្រព្យរបស់អាត្មា

---

[១៥១] (ន.) ខ្យងសមុទ្រមួយបែប គូទស្រួចមានស្នាមវិលស្រួល សម្បុរ-ស, សម្រាប់ពួកបារគូផ្លុំ ឬសម្រាប់ដងទឹកសក្តិសិទ្ធិស្រោចក្នុងព្រះរាជពិធីជាដើម : ពួកបារគូផ្លុំសង្ខ, ស្រោចទឹកក្នុងទឹកសង្ខថ្វាយ ។ ឈ្មោះសារាយសមុទ្រមួយប្រភេទដើមល្អិតល្វន់ សម្បុរ-ស : សារាយសង្ខ (ហៅ សារាយអំបោះ ក៏បាន) ។

សូម្បីបន្តិចឡើយ" ។

## សីវលីទេវីក្លែងធ្វើចោរប្លន់អ្នកស្រុក

ក្រោយពេលត្រាស់ដូច្នេះហើយ ព្រះមហាសត្វយាងចេញទៅតាមទ្វារខាងជើង ។ សូម្បីពពួកស្រីស្នំទាំង ៧០០ នាក់ ក៏ចេញទៅតាមព្រះមហាក្សត្រដែរ ។

រីឯព្រះនាងសីវលីទេវីគិតរកនូវឧបាយមួយសាទៀត ហើយបង្គាប់អាមាត្យទាំងឡាយថា ៖

"អស់លោកចូរសម្តែងធ្វើដូចជាមានអំពើឃាតកម្មរបស់ពួកចោរប្លន់ក្នុងដែនចុះ" ។

ក្នុងខណៈនោះឯង ពួកប្រុស ៗ មានអាវុធក្នុងដៃ ស្ទុះរត់ប្រសេចប្រសាចអំពីតំបន់មួយទៅតំបន់មួយ ធ្វើហាក់ដូចជាកំពុងប្រព្រឹត្តសកម្មភាពប្លន់អ្នកស្រុក, អ្នកស្រុកក៏លាបលក្ខពណ៌ក្រហមតាមខ្លួនប្រាណ ពុតធ្វើជាដេកស្លាប់ផ្កាប់ផ្ងារលើផែនក្តា ហាក់ដូចជាត្រូវពួកចោរប្រហារដោយអាវុធ នៅចំពោះព្រះភក្ត្រព្រះមហាក្សត្រ ។ មហាជននាំគ្នាថ្កោលទោសថា ៖

"បពិត្រមហារាជ នាកាលព្រះអង្គកំពុងគង់ព្រះជន្មនៅផង ពួកចោរមកប្លន់រដ្ឋ មនុស្សម្នា ត្រូវពួកវាចាក់សម្លាប់កាប់សម្លេះអស់ច្រើនណាស់" ។

គ្រានោះ ព្រះនាងទេវីម្ចាស់ទៅថ្វាយបង្គំព្រះកស្ដា ពោលនូវគាថានេះ ដើម្បីយាងព្រះអង្គឲ្យត្រឡប់វិញថា ៖

"ចោរក្នុងដងព្រៃកើតឡើងហើយ បំផ្លាញដែនរបស់ព្រះអង្គ
បពិត្រព្រះរាជា សូមព្រះអង្គស្ដេចមក សូមស្ដេចយាងត្រឡប់
វិលវិញ កុំឲ្យដែននេះវិនាសឡើយ ក្រាបទូល" ។

ព្រះរាជាទ្រង់ឮដូច្នោះ មានព្រះរាជតម្រិះថា ៖

"កាលដែលអាត្មាអញគង់ព្រះជន្មនៅ ពួកចោរដែលតាំងឡើង
កម្ចាត់កម្ចាយដែនយើង រមែងមិនមាន, ស្ថានភាពនុ៎ះ ជាក់ជា
មានឡើងដោយល្បិចកលរបស់នាងសីវលីទេវីពុំខាន" ។

មានព្រះរាជតម្រិះដូច្នេះហើយ អង្គក្សត្រមហាជនកបវរពោធិសត្វបាន ត្រាស់ពាក្យផ្ដុញផ្ដាល់ព្រះនាងឲ្យអស់តម្រិះតវ៉ាថា ៖

"កង្វល់មិនមានដល់យើង យើងឈ្មោះថារស់នៅជាសុខ កាល
បើដែនត្រូវពួកចោរលួចប្លន់ទ្រព្យសម្បត្តិ ចោរទាំងនោះមិនបាន
យកទ្រព្យរបស់អាត្មាសូម្បីបន្តិច ។ កង្វល់មិនមានដល់យើង
យើងឈ្មោះថារស់នៅជាសុខ យើងជាអ្នកមានបីតិជាអាហារ

ដូចពួកអាភស្សរទេវតា[១៥២]" ។

## សីវលីទេវីយំបម្រះនឿល

បើទុកណាអង្គព្រះមហាក្សត្របានត្រាស់យ៉ាងនេះក៏ដោយ ក៏មហាជននៅតែដើរតាមព្រះរាជាពុំត្រឡប់ក្រោយឡើយ ។ គ្រានោះ ព្រះរាជាមានព្រះរាជតម្រិះថា ៖

"ពួកមហាជនមិនព្រមត្រឡប់ទៅវិញសោះ អញនឹងឲ្យពួកគេត្រឡប់វិញ" ។

ក្នុងពេលព្រះអង្គយាងទៅបានចម្ងាយប្រមាណកន្លះគាវុធ ស្តេចមហាជនកទ្រង់បែរព្រះកាយឈរនៅលើផ្លូវធំ រួចត្រាស់សួរអាមាត្យទាំងឡាយថា ៖

"តើរាជាណាចក្រនេះជារបស់នរណា ?"

ពួកអាមាត្យក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព ជារបស់ព្រះអង្គ ក្រាបទូល" ។

លំដាប់នោះ ព្រះមហាជនកបរមពោធិសត្វ ទ្រង់យកឈើច្រត់គូសទទឹងផ្លូវប្រាប់ថា ៖

---

[១៥២] (ន.) (បា.),(សំ.) (--ភ័ស-ស:រ៉ៈ) (អាភស្សរ; អាភាស្វរ) ឈ្មោះព្រហ្មលោកជាន់ទី ៦ ក្នុងឋានរូបព្រហ្ម ១៦ ជាន់ : ឋានអាភស្សរៈ ។ ពួកព្រហ្មដែលកើតនៅក្នុងឋាននោះ ហៅ អាភស្សរព្រហ្ម (កើតដោយផលនៃទុតិយជ្ឈាន) ។ ព. ពុ. ។

"បើដូច្នោះ អស់លោក ចូរដាក់រាជអាជ្ញាចំពោះជនណាដែល
ហ៊ានឈានកន្ទង់ស្នាមគំនូសនេះ" ។

ស្នាមគំនូសដែលស្ដេចទ្រទ្រង់អំណាចនោះ គូសហើយ គឺគ្មាននរណាម្នាក់ហ៊ានដើរកន្ទង់ឡើយ ។ ពពួកជនជាច្រើន ទុកស្នាមគំនូសនោះដូចជាក្បាលដំណោកនៃក្រឡាព្រះបន្ទំ (ពុំហ៊ានដើររំលង) នាំគ្នាស្រែកទ្រហោយំខ្សឹកខ្សួលយ៉ាងខ្លាំង ។ សូម្បីព្រះនាងសីវលីទេវី ក៏ពុំហ៊ានយាងរំលងស្នាមគំនូសនោះដែរ បានត្រឹមតែចោលព្រះនេត្រាទតមើលទៅខ្នងព្រះរាជស្វាមីដែលកំពុងយាងទៅមុខឥតងាកក្រោយ ។ ព្រះនាងសីវលីទេវី ទ្រង់ព្រះវិយោគសោកា គក់ព្រះឱរាស្ដាយព្រះរាជស្វាមីជាពន់ពេក ទ្រង់ពុំអាចនឹងទប់ទល់តម្កល់អាត្មាបាន ក៏ប្រះប្រាណដួលទទឹងខ្លួននៅលើផ្លូវធំ ហើយបម្រះននៀលទៅតាមព្រះរាជស្វាមី ។ រីឯមហាជននិយាយគ្នាថា ៖

"ស្នាមគំនូសរបស់ព្រះមហាក្សត្រ ត្រូវព្រះរាជអគ្គមហេសីរបស់
ព្រះអង្គធ្វើឲ្យរលុបបាត់ហើយ" ។

និយាយដូច្នេះហើយបាននាំគ្នាដើរទៅតាមផ្លូវ ដែលព្រះនាងទេវីយាងទៅនោះឯង ។

លំដាប់នោះ ព្រះមហាសត្វ ស្ដេចយាងឆ្ពោះចូលទៅរកព្រៃហិមពាន្តខាងជើង ។ ចំណែកព្រះនាងទេវីនាំយកពាហនៈនៃកងទ័ពទាំងអស់ ធ្វើដំណើរទៅជាមួយនឹងស្ដេចមហាជនក ។ ស្ដេចមហាជនក

មិនអាចញ៉ាំងមហាជនឲ្យត្រឡប់វិញបានទាល់តែសោះ ម៉្លោះហើយ ស្ដេចចេះតែយាងទៅ ៗ រហូតផ្លូវ ៦០ យោជន៍ ។

## មហាជនកជួបនារទតាបស

គ្រានោះ មានតាបសមួយរូបគង់នៅក្នុងសុវណ្ណគុហាក្នុងព្រៃហិមពាន្ត[១៩៣] ។ តាបសនោះបានសម្រេចអភិញ្ញា ៥ ញ៉ាំងកាលឲ្យកន្លងទៅដោយសេចក្ដីសុខក្នុងឈានរំលង ៧ ថ្ងៃមក លោកចេញអំពីឈាន បន្លឺនូវឧទានថា "សុខអីម៉្លេះហ្ន៎ ! សុខអីម៉្លេះហ្ន៎ !" ។ នារទតាបសនោះប្រមើលមើលដោយទិព្វចក្ខុថា "លើផ្ទៃជម្ពូទ្វីប មានជនណាខ្លះដែលកំពុងស្វែងរកនូវសុខបែបនេះ" ក៏ឃើញស្ដេចមហាជនកជាពុទ្ធង្កុរ[១៩៤] បណ្ដូលជិនវង្ស[១៩៥] ហើយនារទតាបសត្រិះរិះថា ៖

---

[១៩៣] (ន.) (បា.) (ហិ-មៈពាន) (ហិមវន្តុ "មានទឹកសន្សើម" > ហិមវន្ត; ខ្មែរប្រើ វ > ព, ព > ពា) ប្រទេសឬភ្នំមានទឹកសន្សើម : ព្រៃហិមពាន្ត, ភ្នំហិមពាន្ត ។ ខ្មែរប្រើក្លាយជា ហេមពាន្ត ក៏មាន, ប្រើក្លាយឃ្លាតទៅទៀតជា ហេម្ពពាន្ត ក៏មាន, ពាក្យកាព្យ ប្រើជា ហិមវ័ត, ហេមវ័ត, ហិមវ័ន្ត, ហេមវ័ន្ត, ហេមវា ក៏មាន; សម័យសព្វថ្ងៃនេះលេចឮឈ្មោះក្នុងសកលលោកថា ហិមាល័យ ឬ ហិមាលយា (ម. ព. នេះទៀតផង) ។

[១៩៤] ន. (បា. ពុទ្ធង្កុរ < ពុទ្ធ "ព្រះពុទ្ធ" + អង្កុរ "ពន្លក, ទំពាំង"; សំ. ពុទ្ធាង្កុរ) ពន្លកព្រះពុទ្ធ គឺព្រះពោធិសត្វដែលបម្រុងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលជាប្រាកដ ឧ. ម្នាលភិក្ខុទាំងឡាយ, សុមេធតាបសនេះជាពុទ្ធង្កុរនឹងបានត្រាស់ជាព្រះពុទ្ធមាននាមថា គោតម... (ទំនាយព្រះពុទ្ធទីបង្ករទាយឲ្យសុមេធតាបស) ។

[១៩៥] (ន.) (សំ.), (បា.) (ជិនៈវង់) (ជិន + វំស) បណ្ដូលជាវង្សនៃព្រះជិនស្រី គឺព្រះពោធិសត្វដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងពេលអនាគត ។ ជាពាក្យពន្យល់សេចក្ដីឲ្យពាក្យថា ពុទ្ធង្កុរ : ពុទ្ធង្កុរបណ្ដូលជិនវង្ស ដែលមានន័យថា ពន្លកព្រះពុទ្ធ ។

"ស្ដេចមហាជនកកំពុងយាងចេញសាងមហាភិនេស្រ្កមន៍ តែទោះយ៉ាងណា ទ្រង់ពុំអាចញ៉ាំងមហាជនដែលមានព្រះនាងសីវលីទេវីជាប្រមុខឲ្យត្រឡប់វិញបាន, ដំណើរនោះគប្បីធ្វើសេចក្ដីអន្តរាយចំពោះព្រះអង្គ, ឥឡូវនេះ អាត្មាអញនឹងទៅឲ្យឱវាទចំពោះព្រះរាជា ដើម្បីឲ្យទ្រង់ប្រកាន់ជំហរខ្ជាប់ខ្ជួនកាន់តែក្រៃលែងឡើង" ។

លុះគិតដូច្នេះហើយ នារទតាបសទៅដោយកម្លាំងឫទ្ធិ ឈរនៅឰដ៏អាកាសចំពីខាងមុខព្រះរាជា ពោលនូវគាថាខាងក្រោមនេះ ដើម្បីបង្កើនសេចក្ដីឧស្សាហ៍របស់ព្រះរាជា ៖

"ថីក៏មានសំឡេងគឹកកងខ្លាំងម៉្លេះ ដូចជាហ្វូងដំរី ? ស្ត្រីដែលមកលេងឡិកឡក់ដូចក្មេងអ្នកស្រុកនុ៎ះ ត្រូវជាអ្វីនឹងលោក ? បពិត្រសមណៈ មហាជនដែលដេញតាមចោមរោមលោកនុ៎ះ ដើម្បីអ្វីទៅ ?"

ក្រោយពេលឮពាក្យរបស់នារទតាបស ស្ដេចមហាជនកឆ្លើយតបថា ៖

"ខ្ញុំបានលះបង់នូវមហាជន ហើយចេញមកទីនេះ ពួកគេមានក្ដីអាល័យខ្ញុំ ទើបមកប្រជុំគ្នាក្នុងទីនេះ ខ្ញុំកន្លងនូវដែនគឺកិលេស ហើយទៅបួសដើម្បីបាននូវមោនធម៌ ពោលគឺញាណរបស់

អនាគារិយមុនី[១៥៦] ខ្ញុំកាលទៅកាន់ទីប្រទ្បូកប្រទ្បំដោយសេចក្ដី
រីករាយទាំងឡាយ អ្នកដឹងហើយ ទើបសួរខ្ញុំឬ ឬក៏មិនដឹង ?"

គ្រានោះ ដើម្បីឲ្យស្ដេចមហាជនកសមាទានកាន់តែមាំ នារទតាបស
ពោលនូវគាថាបន្ថែមទៀត ៖

"កាលព្រះអង្គកោរសក់ ស្លៀកដណ្ដប់សំពត់កាសាវៈនេះ សូម
ទ្រង់កុំសម្គាល់ថា ខ្លួនព្រះអង្គឆ្លងផុតចាកកិលេស ដោយហេតុ
ត្រឹមតែកាន់ភេទបព្វជិតនេះឡើយ ដែលហៅថា កិលេស ៗ
នេះ មិនមែនឆ្លងរួចដោយហេតុត្រឹមប៉ុណ្ណោះទេ ព្រោះថា
កិលេសជាគ្រឿងអន្តរាយដែលរាំងផ្លូវសួគ៌ មានច្រើនណាស់
ចំពោះព្រះអង្គ" ។

គ្រានោះ ព្រះមហាសត្តស្ដាប់នូវពាក្យរបស់នារទតាបសហើយ ក៏សាក
សួរអំពីកិលេសជាគ្រឿងអន្តរាយនោះថា ៖

"ខ្ញុំមិនប្រាថ្នានូវកាមទាំងឡាយក្នុងមនុស្សលោកជាបច្ចុប្បន្ន
ហើយក៏មិនប្រាថ្នានូវកាមទាំងឡាយក្នុងទេវលោកនាអនាគត
ដែរ សេចក្ដីអន្តរាយដូចម្ដេចហ្ន៎ នឹងមានដល់ខ្ញុំដែលមាន
ប្រក្រតីរស់នៅម្នាក់ឯងយ៉ាងនេះ" ។

គ្រានោះ នារទតាបសបង្ហាញអន្តរាយដល់ព្រះអង្គថា ៖

---

[១៥៦] (ន.) (បា.) (អៈនាគា-រិយៈ) អ្នកដែលមិនមានប្រយោជន៍ដោយផ្ទះឬដោយការ
គ្រប់គ្រងផ្ទះ (បព្វជិត) ។

"ដ្បិតថា សេចក្តីអន្តរាយតាំងឡើងច្រើនគឺ ការដេកលក់ សេចក្តីខ្ជិល ការមិតពត់ សេចក្តីអផ្សុក ការពុលបាយតាំងនៅក្នុងសរីរៈ រមែងកើតក្នុងសរីរៈវិញ" ។

គ្រានោះ ព្រះមហាសត្វថ្លែងសេចក្តីសរសើរចំពោះតាបសនារទថា ៖

"ល្អអ្វីម៉្លេះទេ ពាក្យទូន្មានដែលលោកបានផ្តល់ចំពោះខ្ញុំ! បពិត្រអ្នកនិរទុក្ខ[១៥៧] តើលោកជានរណា ?"

នារទតាបសតបថា ៖

"ជនទាំងឡាយហៅអាត្មាថានារទៈ គោត្តនាមអាត្មា គឺកស្សបៈ អាត្មាមកក្នុងសម្នាក់ព្រះអង្គនេះ ដោយដឹងច្បាស់ថាការចូលរួមជាមួយនឹងសប្បុរសទាំងឡាយ ជាកិច្ចញ៉ាំងប្រយោជន៍ឲ្យសម្រេច ។ សេចក្តីត្រេកអរក្នុងបព្វជ្ជានិងព្រហ្មវិហារធម៌ទាំង ៤ ចូរកើតដល់ព្រះអង្គនោះចុះ បរិកម្ម[១៥៨]និងឈាន[១៥៩]ណា ការខ្វះខាតដោយ

[១៥៧] (គុ.) (សំ.),(បា.) (និទ៌ុះខ; និទ្ទុក្ខ) ដែលឥតទុក្ខ, ឥតព្រួយ ។ សរសេរក្លាយជា នេរទុក្ខ ក៏មាន ។

[១៥៨] (ន.) (បា.),(សំ.) (បរិក័ម ឬ ប៉ៈរ៉ិ) (បរិកម៌ន៑) ការចម្រើនភាវនា; ការគក់ប្រឫបាច់; ការលាបថ្នាំពណ៌ផ្សេង ៗ...។

[១៥៩] (កិ.) លើកជើងដើរ, យាសជើងបោះជំហានទៅ : ឈានជើងដើរ ។

(ន.) (បា.),(សំ.) (ធ្យាន) ការសម្ងំអារម្មណ៍ ដែលជាអប្បនាសមាធិ : ចម្រើនឈាន, ចូលឈាន : ឈានមាន ៤ ថ្នាក់ គឺថ្នាក់ទី ១ ហៅ បឋមជ្ឈាន មានអង្គ ៥ គឺ ១- វិតក្កៈ សេចក្តីនឹកសំដៅឆ្ពោះទៅរកអារម្មណ៍ដែលកំពុងភាវនា; ២- វិចារៈ សេចក្តីរំពឹង

សីលនិងឈានណា ព្រះអង្គចូរបំពេញនូវការខ្វះខាតនោះចុះ
ព្រះអង្គចូរប្រកបដោយអធិវាសនក្ខន្តី[១៦០] និងឧបសមៈ[១៦១] ។
ព្រះអង្គចូររំសាយចោលនូវសេចក្តីមើលងាយនិងសេចក្តីក្រអឺត

---

ពិចារណាអារម្មណ៍ដែលកំពុងភាវនា; ៣- បីតិ សេចក្តីស្កប់ចិត្ត; ៤- សុខៈ សេចក្តីសប្បាយក្នុងចិត្ត; ៥- ឯកគ្គតា ដំណើរមូលចិត្តស្ទុងទៅក្នុងអារម្មណ៍តែមួយ (អង្គទាំង ៥ នេះ សំដៅចំពោះអារម្មណ៍ ដែលស្ងប់ស្ងាត់ចាកកាមគុណ); ថ្នាក់ទី ២ ហៅ ទុតិយជ្ឈាន មានអង្គ ៣ គឺលះ វិតក្កៈ វិចារៈ ចេញ នៅសល់តែ បីតិ និង សុខៈ ដែលកើតមកអំពីសមាធិរបស់បឋមជ្ឈាន ជា ៣ នឹង ឯកគ្គតា, ថ្នាក់ទី ៣ ហៅ តតិយជ្ឈានមានអង្គ ២ គឺលះ បីតិ ចេញ នៅសល់តែ សុខៈ និង ឯកគ្គតា; ថ្នាក់ទី ៤ ហៅ ចតុត្ថជ្ឈាន មានអង្គ ២ ដែរ លះ សុខៈ ចេញ ចិត្តក្លាយទៅជា ឧបេក្ខា គឺដើយព្រងើយ ជា ២ នឹង ឯកគ្គតា ។ ឈានទាំងបួនថ្នាក់នេះ ហៅថា រូបជ្ឈាន មានរូបធម៌ជាអារម្មណ៍រាប់បញ្ចូលក្នុងរូបាវចរភូមិ ។ បុគ្គលអ្នកចម្រើនភាវនា បានសម្រេចផ្លូវឈាន សូម្បីត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ក៏ចួបប្រទះសេចក្តីសុខសប្បាយធម្មតា ឆ្ងាញ់ពិសាជាងរសជាតិអ្វី ៗ ទាំងអស់ ។ បើរៀងភ្ជាប់ពីខាងដើមសព្ទឯទៀត អានថា ឈានៈ ដូចជា ឈានចិត្ត (--ចិត) ចិត្តដែលបានសម្រេចឈាន ។ ឈានផល (--ផល់) ផលរបស់ឈាន, សេចក្តីសម្រេចប្រយោជន៍ដែលកើតអំពីឈាន ។ ឈានពល (--ពល់) កម្លាំងនៃឈាន ។ ឈានសុខ (--សុក) សុខដែលកើតអំពីឈាន ។ ឈានឫទ្ធិ (--រឹត; បា. ឈាន + ឥទ្ធិ; សំ. ធ្យាន + ឫទ្ធិ) ឫទ្ធិនៃឈាន, ឫទ្ធិដែលកើតអំពីឈាន ។ ឈានានុភាព (--ភាប; បា. ឈាន + អានុភាវ) អានុភាព, អំណាច, តេជះនៃឈាន ។ល។

[១៦០] (ន.) (សំ.),(បា.) ការបិុនអត់ទ្រាំយ៉ាងក្រៃលែង, ខន្តីមានកម្លាំង, ខន្តីយ៉ាងឧក្រិដ្ឋ ។
[១៦១] សេចក្តីស្ងប់, ការចូលទៅរកសេចក្តីស្ងប់ ។

ក្រទម[១៦២] ចូរធ្វើនូវការគោរពក្នុងកុសលកម្ម ក្នុងវិជ្ជានិងធម៌" ។ ក្រោយពេលឲ្យឱវាទដល់ព្រះមហាសត្តយ៉ាងនេះ នារទតាបស បានហោះតាមអាកាសវិលទៅកាន់លំនៅអាត្មាវិញ ។

## មហាជនកជួបមិគាជិនតាបស

កាលនារទតាបសនេះទៅបាត់ហើយ មានតាបសមួយរូបទៀត នាមថា **មិគាជិន** លោកចេញចាកសមាបត្តិ[១៦៣]ប្រមើលមើលទំនងដូច នារទៈដែរ លោកបានឃើញព្រះពោធិសត្វ ក៏ត្រិះរិះថា "អញនឹងទៅ ឲ្យឱវាទ[១៦៤] ដល់ស្ដេចមហាជនក ដើម្បីញ៉ាំងមហាជនឲ្យត្រឡប់វិញ" ដូច្នេះ លោកបានមកទីនោះ បង្ហាញខ្លួននៅឰដ៏អាកាស ពោលថា ៖

"បពិត្រព្រះជនក ព្រះអង្គលះបង់ដំរីសេះ ពួកអ្នកនគរ និងជន-បទជាច្រើន ហើយទ្រង់ព្រះផ្នួស ដល់នូវសេចក្ដីត្រេកអរនឹង

---

១៦២ (គុ.) ដែលសំដែងឫកពា, កិរិយាឃឹតយ៉ាវ ធ្វើក្រអឺត ក្រប្រែតវិយាបថ : ឫក ក្រអឺតក្រទម (ម. ព. ក្រអឺត ) ។

១៦៣ (ន.) (សំ.),(បា.) (ស:ម៉ាប័ត) ការដល់ព្រម; ការបណ្ដាលឲ្យកើតមានឡើង; ការ សមប្រកប; ការចួបប្រទះ, ការចួបប្រសព្វ; ការបានសម្រេច ។ ព. ពុ. ការចូលឈាន តាមលំដាប់ថ្នាក់ទាំង ៨ គឺ រូបជ្ឈាន ៤ អរូបជ្ឈាន ៤ : ព្រះអរហន្តចូលសមាបត្តិ, ព្រះ បច្ចេកពុទ្ធចេញចាកសមាបត្តិ ។

១៦៤ (ន.) (បា.) (--វ៉ាត) (អវ > ឱ; សំ. អវវាទ) ដំបូន្មាន, អនុសាសន៍ : ឲ្យឱវាទ, ស្ដាប់ ឱវាទ ។

អំបែង[១៦៥] បពិត្រព្រះជនក ពួកអ្នកជនបទ មិត្រអាមាត្យ និង ព្រះញាតិ បានធ្វើនូវការទ្រុស្តចំពោះព្រះអង្គខ្លះដែរឬ? ហេតុអ្វី ក៏ព្រះអង្គពេញព្រះហឫទ័យនឹងអំបែងរបស់ព្រះអង្គនោះ?”

គ្រានោះ ព្រះមហាសត្វពោលថា ៖

“បពិត្រមិគាជិន ក្នុងកាលណាក៏ដោយ ខ្ញុំមិនដែលផ្ចាញ់ញាតិណាមួយដោយអធម៌[១៦៦] ទាល់តែសោះ ទាំងពួកញាតិក៏មិនដែលផ្ចាញ់ខ្ញុំដោយអធម៌ដែរ ដូច្នេះហើយ ពុំមាននរណាម្នាក់ធ្វើការប្រទូសចំពោះខ្ញុំឡើយ” ។

---

[១៦៥] (ន.) បន្ទះបំណែកនៃក្អម, ឆ្នាំង, ចានជាដើម : អំបែងក្អម, អំបែងចាន ។ ក្អមដីឬឆ្នាំងដីដែលគោះចោះត្រង់ក្អែងម្ខាងឲ្យមានចន្លោះធំល្មមដល់ការ សម្រាប់លីងអ្វី ៗ : លីងពោតពីរបីអំបែង ។

[១៦៦] (គុ.) (បា.),(សំ.) (អៈធ័ម) (អធម៌) ដែលពុំមែនធម៌, ដែលខុសធម៌, ក្រៅគន្លងធម៌, ខុសច្បាប់; អាក្រក់, ពុំប្រសើរ : មនុស្សអធម្ម (ប្រើជា អធម៌ ក៏បាន) ។ ន. ដំណើរខុសធម៌, ខុសច្បាប់; ការពុំប្រសើរ; ទុច្ចរិត : ចៅក្រមវិនិច្ឆ័យក្ដីដោយអធម្ម (ប្រើជា អធម៌ ក៏បាន) បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ អ. ថ. អៈធ័ម-មៈដូចជា អធម្មកម្ម កម្មអាក្រក់, អំពើពុំប្រសើរ ។ អធម្មការី អ្នកធ្វើអំពើពុំប្រសើរ (បើស្ត្រីជា អធម្មការិនី) ។ អធម្មវាចា --វាទ សម្ដីខុសធម៌, ខុសច្បាប់ ។ អធម្មវាទី អ្នកនិយាយខុសធម៌, ខុសច្បាប់ (បើស្ត្រីជា អធម្មវាទិនី) ។ល។ (ព. កា.) : អធម្មវាទី និយាយញាំញី ព្រះពុទ្ធសាសនា ព្រោះលោភជិះជាន់ កន្ដក្វេចសិក្ខា លែងកាន់រក្សា ថាឥតអៀនខ្មាស ។ ពោលតាមទំនើង ដែលចិត្តខ្លួនទើង ពាយផាយផ្ដេសផ្ដាស ខុសខ្លះត្រូវខ្លះ ប្រឡេសប្រឡាស ព្រោះឥតក្ដីខ្មាស ហៅអលជ្ជី ។

បន្ទាប់ពីបានបដិសេធសំណួររបស់មិគាជិនតាបសយ៉ាងនេះហើយ ព្រះមហាជនក បានលើកយកមូលហេតុដែលនាំឲ្យព្រះអង្គចេញសាងផ្នួសក្នុងបច្ចុប្បន្នថា ៖

"បពិត្រមិគាជិន ខ្ញុំបានឃើញនូវប្រវេណីនៃសត្វលោកដែលល្ងង់វង្វេងនៅក្នុងវដ្តសង្សារ ត្រូវកិលេសទំពាស៊ីខ្ទេចខ្ទីដូចជាភក់ បុថុជ្ជននោះផុងលិចក្នុងកិលេសវត្ថុ[១៦៧]យ៉ាងពពាក់ពពូន ទាំងជាប់ដោយចំណងខ្នោះជាដើម ប្រសិនបើខ្ញុំជាប់ក្នុងកិលេសវត្ថុនោះ ខ្ញុំនឹងត្រូវគេបៀតបៀន និងជាប់ចំណងដូចពួកសត្វទាំងនោះដែរ ខ្ញុំបានយកហេតុការណ៍នេះ មកជាឧបមាដល់ខ្លួនឯង ទើបឃើញសត្វលោកនោះដូចជាភក់ ហើយក៏សម្រេចចិត្តចេញបួសដើរសុំចង្ហាន់គេវិញ" ។

មិគាជិនតាបស ចង់ស្តាប់នូវការណ៍នោះឲ្យបានពិស្តារ ក៏ពោលថា ៖

"បពិត្រព្រះអង្គប្រសើរលើរថ បុគ្គលមានជោគណា ជាសាស្តារបស់ព្រះអង្គ ? ពាក្យដ៏ពីរោះនេះជាពាក្យរបស់អ្នកណា ? ព្រោះថា អ្នកប្រាជ្ញទាំងឡាយ មិនរៀរនូវតាបសអ្នកសម្រេចអភិញ្ញា ឬនូវព្រះបច្ចេកពុទ្ធដែលប្រកបដោយវិជ្ជា ពោលនូវសមណៈថា អ្នកមានវត្ត ជាគ្រឿងកន្លងនូវទុក្ខទេ" ។

---

[១៦៧] (ន.) វត្ថុដែលនាំឲ្យកើតកិលេសបានដល់វត្ថុ ៦ យ៉ាងគឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វ ធម្មារម្មណ៍ ។

ព្រះមហាសត្តតបថា ៖

"បពិត្រមិគាជិន ខ្ញុំមិនដែលចូលទៅគោរពសមណព្រាហ្មណ៍ណាមួយ ដោយដាច់ខាតក្នុងកាលណាម្ដងឡើយ" ។

លុះពោលយ៉ាងនេះហើយ ទ្រង់ក៏ពោលបំភ្លឺនូវមូលហេតុដែលនាំឲ្យទ្រង់សាងព្រះផ្នួស តាំងអំពីដើមទីមកថា ៖

"បពិត្រមិគាជិនៈ ខ្ញុំកាលទៅដោយអានុភាពដ៏ធំ រុងរឿងដោយសិរី កាលចម្រៀងដែលបុគ្គលកំពុងច្រៀង កាលតន្ត្រីមានសំឡេងដ៏ពីរោះដែលបុគ្គលកំពុងប្រគំ ខ្ញុំបានឃើញស្វាយមានផ្លែ ខាងក្រៅកំពែងដែលពួកមនុស្សអ្នកត្រូវការផ្លែ បេះនៅជិតឧទ្យានដែលគឹកកងដោយការប្រគំតន្ត្រី ជាឧទ្យានប្រកបដោយសូរប្រគំដ៏ពីរោះ បពិត្រមិគាជិន ខ្ញុំនោះបានលះបង់សិរីនោះហើយចុះ (អំពីដំរី) ចូលទៅកាន់គល់ស្វាយមានផ្លែដែលបុគ្គលបៀតបៀនហើយ កម្ចាត់ហើយ ធ្វើមិនឲ្យមានស្លឹក និងស្វាយមួយដើមក្រៅនេះ មានពន្លឺខៀវជាទីរីករាយនៃចិត្ត សត្រូវទាំងឡាយអាចសម្លាប់យើងដែលជាឥស្សរៈ[១៦៨]មានបន្ទាច្រើនដោយ

[១៦៨] (គុ.) (សំ. ក្ង.) (អ៊ិ--) (បា. សំ.) (ឦ្លគ្វរ; ខ្មែរប្រើ វ > ; ឥស្សរ) ដែលជាធំ, ជាចម្បង, ជាកំពូលលើគេ, ជាម្ចាស់លើគេ : ពង្សពុទ្ធង្កូរ ឥស្សរកំពូល លើអស់អ្នកផង គោរពមាតា កុំឲ្យមានហ្មង ពុំដែលកន្ទង ទសពិធធម៌ថ្លៃ ។ (ន.) អ្នកធំ; អ្នកដែលជាចម្បងលើសអស់អ្នកផង, ម្ចាស់លើគេ, ម្ចាស់ផែនដី (ក្សត្រិយ៍ទ្រង់រាជ្យ); ចៅហ្វាយធំ ។

ពិត ដូចដើមស្វាយដែលមានផ្លែដែលបុគ្គលសម្លាប់ហើយ ខ្លាដំបងត្រូវគេសម្លាប់ព្រោះស្បែក ដំរីត្រូវគេសម្លាប់ព្រោះភ្លុក បុគ្គលអ្នកមានទ្រព្យត្រូវគេសម្លាប់ព្រោះទ្រព្យ តើនរណានឹងសម្លាប់ បុគ្គលអ្នកមិនមានផ្ទះ មិនមានសន្ថវៈ[១៦៩] ដើមស្វាយមានផ្លែនិងមិនមានផ្លែទាំងពីរនោះ ជាសាស្តារបស់ខ្ញុំ" ។

## សាច់សំណល់សុនខ

ក្រោយពេលឮដូច្នោះ មិគាជិនតាបសផ្តល់ឱវាទចំពោះព្រះរាជាថា ៖

"សូមព្រះអង្គកុំធ្វេសប្រហែសឡើយ" ។

រួចតាបសលោកត្រឡប់ទៅកាន់លំនៅខ្លួនវិញ ។ កាលបើតាបសទៅវិញ សីវលីទេវីក្រាបចុះទៀបបាទមូលនៃព្រះរាជា ពិតទូលថា ៖

"ជនទាំងពួងគឺពលដំរី ពលសេះ ពលរថ ពលថ្មើរជើង បានឮថា ព្រះរាជាទ្រង់ផ្នួសហើយក៏តក់ស្លុត សូមព្រះអង្គលួងលោមនូវប្រជុំជន ហើយតាំងទុកនូវការរក្សារួចតាំងព្រះរាជឱរសក្នុងរាជសម្បត្តិសិន សឹមទ្រង់ព្រះផ្នួសក្នុងកាលជាខាងក្រោយចុះ" ។

ពេលនោះ ព្រះពោធិសត្វតបថា ៖

---

[១៦៩] (ន.) (បា.),(សំ.) (សន់-ថៈវ៉ៈ) (សន្ថវ; សំស្តវ) ដំណើរជិតដិតនឹងគ្នា, ការស្និទ្ធជិតនឹងគ្នា ។ ការរួមសុខទុក្ខ, ការធ្វើមេថុនសេវនកិច្ច : ធ្វើសន្ថវៈ, សេពសន្ថវៈ ។ សន្ថវកិច្ច មេថុនសេវនកិច្ច ។ សន្ថវមិត្ត ឬ --មិត្រ មិត្រដែលមានសេចក្តីស្និទ្ធជិតដិតយ៉ាងមាំ ។ សន្ថវរតិ (--រៈតិ) តម្រេកក្នុងការធ្វើសន្ថវកិច្ច ។ល។

"ពួកអ្នកជនបទ មិត្រអាមាត្យនិងញាតិទាំងឡាយដែលយើង លះបង់ហើយ កូនរបស់អ្នកដែនវិទេហៈឈ្មោះទីឃាវុកុមារអ្នក ញ៉ាំងដែនឲ្យចម្រើន ម្នាលបជាបតិ[១៧០] កូននោះនឹងសោយរាជ្យ ក្នុងក្រុងមិថិលាចុះ" ។

ព្រះទេវីសួរថា ៖

"បពិត្រព្រះសម្មតិទេព កាលបើព្រះអង្គទ្រង់ព្រះផ្នួសទៅ ហើយ ខ្ញុំម្ចាស់នឹងធ្វើដូចម្ដេច" ។

គ្រានោះ ស្ដេចមហាជនកនោះត្រាស់នឹងព្រះនាងថា ៖

"ម្នាលប្អូនស្រីដ៏ចម្រើន អាត្មាឲ្យអនុសាសន៍ដល់នាង, ចូរនាងធ្វើតាមពាក្យរបស់អាត្មាចុះ" ។

ហើយទ្រង់ទូន្មានព្រះនាងថា ៖

"នាងចូរមកនេះ ពាក្យដែលអាត្មាពេញចិត្ត អាត្មានឹងប្រាប់នូវ ពាក្យនោះ នាងនឹងទៅកាន់ទុគ្គតិ[១៧១] ដោយកាយវាចាចិត្តណា នាងកាលសោយរាជ្យ ឈ្មោះថាធ្វើនូវបាបទុច្ចរិតដ៏ច្រើនដោយ កាយវាចាចិត្តនោះ អាត្មានឹងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយ

---

[១៧០] ព្រះអគ្គមហេសី, ប្រពន្ធ ។

[១៧១] (ន.) (បា.),(សំ.) (ទុក-គៈតិ) (ទុគ៌តិ) ដំណើរទៅអាក្រក់; ផ្លូវជាទីទៅកាន់កំណើត អាក្រក់, កំណើតអាក្រក់; បានខាងកំណើតក្នុងអបាយភូមិ ៤ នរក, ប្រេត, អសុរកាយ, តិរច្ឆាន ។

ដុំបាយដែលបុគ្គលដទៃឲ្យហើយ ដែលបុគ្គលដទៃសម្រេច
ហើយ នេះជាបវេណីរបស់អ្នកប្រាជ្ញ" ។

ព្រះមហាសត្វ បានព្រះរាជទាននូវដំបូន្មាន ដល់ព្រះនាងសីវលីទេវី យ៉ាងនេះ ហើយពួកទ្រង់ទាំងពីរអង្គយាងបណ្ដើរចរចាគ្នាបណ្ដើរដរាប សុរិយាអស្ដង្គត ។

ចំណែកព្រះនាងទេវី ក៏បានបោះបន្ទាយក្នុងកន្ទៃងដ៏សមគួរ ។ ចំណែកព្រះមហាសត្វ ស្ដេចទ្រង់យាងចូលទៅកាន់គល់ឈើមួយដើម ។ លុះស្ដេចនៅទីនោះមួយរាត្រី ព្រឹកឡើង ទ្រង់ធ្វើកិច្ចជម្រះព្រះកាយ ហើយបន្តដំណើរទៅមុខទៀត ។ ចំណែកព្រះទេវីក៏ប្រាប់ពួកទាហាន ថា ៖

"ទាហាន ចូរទៅតាមក្រោយឲ្យជាប់" ។

ហើយខ្លួនព្រះនាងផ្ទាល់ក៏យាងទៅតាមក្រោយស្ដេចមហាជនកដែរ ។

ជនទាំងអម្បាលនោះបានដើរទៅដល់នគរមួយឈ្មោះថា ថូណនគរ ក្នុងវេលាត្រាច់ភិក្ខា ។ ក្នុងខណៈនោះ នៅខាងក្នុងនគរ មានបុរសម្នាក់ ទិញសាច់មួយដុំដ៏ធំ អំពីរោងសម្លាប់សត្វមកដោត អណ្ដោតអាំងលើរងើកភ្លើងធ្និនហើយ គាត់លើកមកទុកលើចុងក្ដារ ដើម្បីឲ្យវាត្រជាក់ ។ ពេលបុរសនោះរវល់គិតទៅរឿងផ្សេង ស្រាប់តែ មានសុនខមួយ មកខាំពាំសាច់នោះរត់ទៅ ។ បុរសជាម្ចាស់ដឹង ក៏រត់ ដេញតាមឆ្កែនោះ ដេញរហូតទៅដល់ខាងក្រៅទ្វារខាងត្បូង អស់ចិត្ត

នឹងដេញតាម ហើយគាត់ក៏វិលត្រឡប់វិញ ។ និយាយពីស្ដេចមហាជនក និងព្រះនាងសីវលីទេវីវិញ កំពុងតែដើរទន្ទឹមគ្នាពីខាងមុខសុនខនោះ, សុនខនោះហេតុតែភ័យ ក៏វាជម្រុះដុំសាច់រត់ចោលទៅ ។ ព្រះមហាសត្ត ឃើញដូច្នោះ គិតថា ៖

"សុនខនេះលះចោលឥតអាល័យ វារត់ទៅហើយ ទាំងម្ចាស់នៃ
ដុំសាច់នេះ ក៏មិនប្រាកដ, ជាធម្មតាបិណ្ឌបាតបង្សុកូលបែបនេះ
ជាបិណ្ឌបាតគ្មានទោស , អាត្មាអញនឹងបរិភោគដុំសាច់នោះ" ។

ព្រះពោធិសត្វទាញបាត្រដីចេញ រើសនូវដុំសាច់នោះបោសធូលីស្អាត ហើយដាក់ចូលក្នុងបាត្រ រួចទ្រង់យាងទៅកាន់កន្លែងមានទឹកគួរជាទីរីករាយ ហើយបរិភោគនូវដុំសាច់នោះ ។ គ្រានោះព្រះនាងទេវីគិតថា ៖

"ប្រសិនបើមហាជនកនេះ មានសេចក្ដីត្រូវការដោយរាជ្យ ដាក់
ជាមិនសោយរបស់ដែលក្ដៅ ដែលគួរឲ្យខ្ពើម ប្រឡាក់ដោយ
ធូលីទេ, ប្រសិនបើទ្រង់សោយវិញ, ទ្រង់នឹងលែងជាស្វាមីរបស់
យើងឥឡូវនេះ" ។

លុះឃើញស្ដេចសោយដូច្នោះ ព្រះនាងក៏ពោលថា ៖

"បពិត្រមហារាជ ព្រះអង្គសោយរបស់ដែលគួរឲ្យខ្ពើម
បែបនេះ គួរបើដែរឬ?"

ស្ដេចមហាជនកតបថា ៖

"នៃនាងទេវី នាងមិនយល់អំពីសេចក្ដីវិសេសនៃបិណ្ឌបាតនេះទេ ព្រោះនាងល្ងង់ណាស់" ។

ថាដូច្នេះហើយ ទ្រង់ពិចារណានូវទីធ្លាក់នៃដុំសាច់នោះឯង រួចសោយដូចរបស់អមតៈ ។ រួលរាល់ហើយទ្រង់ខ្ពុរព្រះឱស្ឋ លាងព្រះហស្ត ។ ក្នុងខណៈនោះ ព្រះនាងទេវីតិះដៀលថា ៖

"បុគ្គលណាមិនបរិភោគអាហារក្នុងកាលកត្តជាគម្រប់ ៤ បុគ្គលនោះគប្បីស្លាប់ដោយសេចក្ដីស្រេកឃ្លាន ដូចបុគ្គលដល់នូវសេចក្ដីស្លាប់ដ៏ពិត មានសភាពជាកុលបុត្រមិនគប្បីបរិភោគដុំបាយដែលប្រឡាក់ដោយធូលី មិនស្អាតទេ ឬការបរិភោគនោះមិនល្អទេ មិនប្រសើរទេ បពិត្រមហាជនក ព្រះអង្គសោយនូវដុំសាច់ដែលសល់អំពីឆ្កែ" ។

ព្រះមហាសត្តតបថា ៖

"ម្នាលសីវលី វត្ថុណាដែលគ្រហស្ថឬសុនខលះបង់ វត្ថុនោះមិនមែនអាត្មាមិនគួរឆាន់ទេ ភោគៈទាំងឡាយណានីមួយក្នុងលោកនេះ ដែលបានដោយធម៌ ភោគៈទាំងអស់នោះ លោកពោលថាជាអាហារមិនមានទោស" ។

## ស្លូវកាចដៃនគ្និចគ្នា

កាលតាបសមហាជនកនិងព្រះអគ្គមហេសីសីវលីទេវីចរចាគ្នាបណ្ដើរយាងទៅបណ្ដើរយ៉ាងនេះ ក៏បានទៅដល់ទ្វារថូណនគរ ។ ក្នុង

ទីនោះ បណ្ដាទារិកាទាំងឡាយកំពុងលេងប្រលែងគ្នា មានកុមារិកាម្នាក់កំពុងស្ទែគ្រាប់ខ្សាច់ដោយកូនកញ្ជ្រែង ។ ក្នុងដៃម្ខាងរបស់នាងពាក់កងមួយ, ក្នុងដៃម្ខាងទៀតពាក់កងពីរ ។ កងពីរនោះបានទង្គិចទង្គុកគ្នា ញុំាងស្នូរក្រេងក្រឹងឲ្យឮឡើង ឥតឈប់, ឯកងមួយក្រៅនេះស្ងាត់សំឡេងឈឹង ។ ព្រះរាជាជ្រាបហេតុការណ៍នោះ មានព្រះតម្រិះថា ៖

"សីវលីទេវីដើរតាមក្រោយអញ, ធម្មតាស្ត្រីជាមន្ទិលរបស់អ្នកបួស, អញនឹងត្រូវអ្នកផងរិះគន់ថា តាបសនេះសូម្បីបួសហើយមិនអាចលះបង់ប្រពន្ធបាន, ប្រសិនបើកុមារិកានេះឆ្លាតឈ្លាសនាងនឹងសម្ដែងនូវហេតុត្រឡប់វិញ ចំពោះសីវលីទេវី រីអញលុះឮសម្ដីរបស់កុមារិកានេះហើយនឹងបញ្ជូនសីវលីទេវីឲ្យត្រឡប់ទៅវិញ" មានព្រះតម្រិះដូច្នេះហើយ ទ្រង់ត្រាស់ចំពោះនាងកុមារិកាថា ៖

"ម្នាលនាងកុមារិកា ជាក្មេងដេកជិតមាតានៅឡើយ មានគ្រឿងប្រដាប់មិនឃ្លាតអំពីខ្លួនជានិច្ច ដៃម្ខាងរបស់នាងលាន់ឮសំឡេងដៃម្ខាងមិនលាន់ឮសំឡេង តើព្រោះហេតុអ្វី ?"

នាងកុមារិកាឆ្លើយថា ៖

"បពិត្រសមណៈ កងពីរដែលពាក់នឹងដៃរបស់ខ្ញុំនេះ ប៉ះទង្គិចគ្នាសំឡេងក៏កើតឡើង នោះជាគតិនៃកងទាំងពីរ បពិត្រសមណៈ

កង់មួយដែលពាក់នឹងដៃរបស់ខ្ញុំនេះ កងនោះមិនមានកងឯទៀត ជាគម្រប់ពីរ ទើបមិនលាន់ឮសំឡេង ដូចអរិយបុគ្គល ជាអ្នកស្ងប់ស្ងៀម ឯបុគ្គលមានគ្នាជាគម្រប់ពីរនាក់ រមែងដល់នូវការជជែកគ្នា បុគ្គលមួយនាក់នឹងជជែកជាមួយនឹងបុគ្គលណាកើត ព្រះអង្គជាអ្នកប្រាថ្នានូវឋានសួគ៌ សូមទ្រង់ពេញចិត្តនឹងភាពនៃបុគ្គលម្នាក់ឯងចុះ" ។

តាបសមហាជនកស្ដាប់ពាក្យរបស់កុមារិកានោះ ក៏បានសម្ដីនោះធ្វើជាបច្ច័យ ត្រាស់ជាមួយនឹងព្រះនាងសីវលីទេវីថា ៖

"ម្នាលនាងសីវលី នាងឮគាថាដែលនាងកុមារិកាពោលហើយឬទេ នាងកុមារិកាតិះដៀលនូវអាត្មាដូចជាអ្នកបម្រើ នោះឯងជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចម្រើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវតែងដើរទៅ បណ្ដាផ្លូវទាំងពីរនោះ នាងចូរកាន់ផ្លូវ១ អាត្មានឹងកាន់ផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់នាង ទាំងអាត្មាក៏មិនហៅនាងថាជាប្រពន្ធអាត្មាដែរ" ។

ព្រះនាងសីវលីទេវី ឮពាក្យបែកផ្លូវគ្នាដើរ របស់ព្រះស្វាមីដូច្នោះ ក៏ក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព ព្រះអង្គជាឧត្តមភេទ[១៧២], សូមស្ដេចកាន់ផ្លូវខាងស្ដាំចុះ, រីឯខ្ញុំនឹងកាន់ផ្លូវខាងឆ្វេង" ។

---

[១៧២] ភេទខ្ពង់ខ្ពស់ ភេទប្រសើរ សំដៅយកភេទបព្វជិត អ្នកបួស ។

ព្រះនាងឈានជើងយាងបែកពីព្រះមហាសត្វតែបន្តិច ក៏ពុំអាចទប់សំណោកដែលគិតស្តាយព្រះអង្គយ៉ាងគ្រលួចក្នុងចិត្តបាន ក៏បែរភក្រ្តាមករកព្រះរាជស្វាមីវិញ ហើយចរចាជាមួយនឹងព្រះរាជាចូលទៅកាន់ថូណនគរដោយដំណើររួមគ្នា ។

## ជំបូន្មានជាងព្រួញ

លុះចូលទៅដល់ថូណនគរ ព្រះមហាសត្វត្រាច់ចរបិណ្ឌបាតក្នុងវេលាជិតកត្ត ទ្រង់ឈរជិតទ្វារផ្ទះនៃជាងព្រួញ ។ ជាងព្រួញនោះកំពុងធ្មេចភ្នែកម្ខាងសម្លឹងមើលដងព្រួញវៀចមួយ ដែលនឹងត្រូវធ្វើវាឲ្យត្រង់ ដោយប្រឹងប្រើខ្សែភ្នែកម្ខាង ។ ចំណែកព្រះនាងសីវលីទេវីឈរនៅទីម្ខាង ។ ក្នុងពេលនោះ ជាងព្រួញកម្តៅព្រួញលើអំបែងភ្លើង រួចលើកឡើងធ្មេចស្រវេង[១៧៣]ភ្នែកម្ខាង ពត់ព្រួញឲ្យត្រង់ដោយសម្លឹងមើលដោយភ្នែកតែម្ខាង ។ ឃើញដូច្នោះ ព្រះមហាសត្វគិតថា ៖

"ប្រសិនបើជាងនេះជាបណ្ឌិត មុខតែប្រាប់ការណ៍មួយចំពោះយើង, យើងនឹងសួរគេលោមើល" ។

បន្ទាប់មក ទ្រង់យាងចូលទៅសួរជាងព្រួញថា ៖

"ម្នាលជាងព្រួញ អ្នកចូរស្តាប់ពាក្យអាត្មា អ្នកធ្មេចភ្នែកម្ខាងសម្លឹងមើលដងព្រួញវៀច អ្នកមើលយ៉ាងនេះស្រួលឬ ?"

---

[១៧៣] (គុ.) (--ង៉េវ) ដែលមានភ្នែកតូចម្ខាង (តាមធម្មតាពីកំណើតឬដោយប្រឹងធ្វើ) : ភ្នែកស្រវេង ។

គ្រានោះ ដាំងព្រួញក៏ក្រាបទូលចំពោះព្រះមហាសត្តថា ៖

"បពិត្រសមណៈ កាលបើបុគ្គលបើកភ្នែកទាំងពីរសម្ញឹងពត់ព្រួញ ប្រាកដជាមើលទៅឃើញទីទូលាយពេក នឹងមិនអាចកំណត់ដឹងបានថាចំណុចវៀចនៃព្រួញនៅត្រង់ណាឲ្យប្រាកដ ដូច្នេះ នឹងពត់ព្រួញឲ្យត្រង់មិនបានឡើយ, ទាល់តែធ្មេចភ្នែកម្ខាង បើកភ្នែកម្ខាងសម្ញឹងតម្រង់វិញ ទើបឃើញចំណុចវៀចនៃព្រួញច្បាស់ប្រាកដ ហើយអាចពត់ព្រួញវៀចឲ្យត្រង់បាន ។ បុគ្គលមានគ្នាពីរនាក់ រមែងដល់នូវការជជែកគ្នា បុគ្គលម្នាក់ឯងនឹងជជែកគ្នាជាមួយនឹងអ្នកណាកើត កាលព្រះអង្គប្រាថ្នានូវឋានសួគ៌ សូមពេញព្រះទ័យនឹងភាពនៃបុគ្គលម្នាក់ឯងចុះ" ។

ដាំងព្រួញ ថ្វាយនូវឱវាទចំពោះតាបសមហាជនកយ៉ាងនេះហើយ គាត់ក៏នៅស្ងៀម ឥតនិយាយស្ដីតទៅទៀត ។

ចំណែកព្រះមហាសត្តត្រេចបិណ្ឌបាត ប្រមូលមិស្សកភត្ត[១៧៤] បានល្មមចម្អែតអាត្មា ទ្រង់ក៏យាងចេញចាកនគរ មករកកន្លែងមានទឹកជាទីរីករាយនៃចិត្ត បានហើយទ្រង់គង់សោយភត្ត លុះស្រេចហើយ

[១៧៤] ចង្ហាន់ ឬបាយដែលដាក់លាយឡូកឡំគ្នានឹងម្ហូប ត្រី សាច់ សម្ល ផ្សេង ៗ ច្រើនមុខ ដែលបានទទួលពីទាយកដាក់ចូលក្នុងបាត្រតែមួយ ជាមួយគ្នា ជាការប្រតិបត្តិដ៏តឹងរឹងរបស់បព្វជិតអ្នកកាន់ធុតង្គ ។

ទ្រង់ខ្ចរព្រះឱស្ឋ ប្រកបាត្រក្នុងស្មោក[១៧៥] ហៅព្រះនាងសីវលីមកប្រាប់បញ្ជាក់ថា ៖

"នែនាងសីវលី នាងឮពាក្យជាងព្រួញនិយាយឬទេ ? ជាងព្រួញតិះដៀលអាត្មាដូចជាអ្នកបម្រើ ។ នោះជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចម្រើន ផ្លូវបែកជាពីរនេះ តែងមានអ្នកដំណើរដើរទៅមក បណ្តាផ្លូវទាំងពីរនោះ នាងចូរយកផ្លូវ ១ អាត្មានឹងយកផ្លូវ ១ ដទៃពីនាង ។ នាងកុំហៅអាត្មាថាស្វាមី ៗ ទាំងអាត្មាក៏មិនហៅនាងថាភរិយាដែរ" ។

## ដំណាច់នៃស្មៅយាប្លង

ព្រះនាងសីវលីទេវី បើទោះបីព្រះរាជាទ្រង់ហាមមិនឲ្យហៅព្រះអង្គថាស្វាមីក៏ដោយ ព្រះនាងនៅតែយាងតាមពីក្រោយជាប់ព្រះមហាសត្តដដែល ។ ព្រះរាជាក៏មិនអាចញ៉ាំងនាងឲ្យត្រឡប់វិញបាន ។ ទាំងមហាជនក៏ដើរតាមយ៉ាងកុះករ ។ ប៉ុន្តែក្នុងតំបន់នោះ មានដងព្រៃមួយនៅក្បែរ ។ ព្រះមហាសត្ត ប្រទះឃើញនូវជួរព្រៃស៊ុមទ្រុមខៀវស្រងាត់មួយ ទ្រង់មានបំណងឲ្យព្រះនាងសីវលីត្រឡប់វិញ ហើយទ្រង់បេះតែ

[១៧៥] (ន.) ថង់សម្រាប់ប្រកបាត្រ : ស្មោកបាត្រ; បាត្ររបស់ខ្ញុំករុណាមានតែស្មោកឥតយោគ ។

យាងស្រូតទៅ ៗ ឃើញស្មៅយាប្លង[១៧៦] នៅក្បែរផ្លូវនោះ ព្រះអង្គលូកដៃក្តិចមួយកំណាត់ប្រវែងមួយថ្នាំងពីទីនោះមក បញ្ជាក់ចំពោះព្រះនាងសីវលីម្តងទៀតថា ៖

"ឃើញទេ នាងសីវលី! យាប្លងនេះ មិនអាចនឹងតជាប់គ្នាបានក្នុងទីនេះទៀតទេ ដូចម្តេចមិញ ការដែលអាត្មានៅរួមជាមួយនឹងនាងក៏ត្រូវដាច់គ្នាស្រឡះ មិនអាចតជាប់គ្នាវិញបាន ឧបមាដូចស្មៅយាប្លងដែលដាច់នេះឯង" ។

រួចទ្រង់ពោលបន្ថែម ៖

"ម្នាលនាងសីវលី នាងចូរនៅម្នាក់ឯងចុះ ដូចស្មៅយាប្លងដែលអាត្មាដកហើយ" ។

ឮដូច្នោះ ព្រះនាងសីវលីទេវី វិលវល់គំនិតថា ៖

"ពីថ្ងៃនេះទៅ អញលែងបាននៅរួមរស់ជាមួយនឹងព្រះនរិន្ទមហាជនកជាព្រះស្វាមីរបស់អញហើយ" ។

ដូច្នេះ ព្រះនាងពុំអាចទប់សេចក្តីសោកស្តាយបាន លើកដៃទាំងពីរគក់ព្រះឱរាដួលសន្ធប់នៅលើផ្លូវធំ ។ ព្រះមហាសត្តដឹងថាព្រះនាងសន្ធប់

---

[១៧៦] (ន.) ឈ្មោះស្មៅទឹកមួយប្រភេទដើមជាថ្នាំង ។ មានស្នូលសត្រសុសនៅក្នុងចាក់រុញបញ្ចេញមកក្រៅបានដោយងាយ : ស្មៅយាប្លង (ហៅ យ៉ាប្លង ក៏មាន) ។

បាត់ស្មារតី ទ្រង់គេចខ្លួនចូលទៅក្នុងព្រៃស៊ុមទ្រុម[១៧៧] បាត់ទៅ សូម្បីស្នាមព្រះបាទា ក៏ព្រះអង្គធ្វើឲ្យស្នុកស្នាញក្នុងការតាមដានខ្លួនព្រះអង្គឲ្យឃើញ ។ ពួកអាមាត្យពុំចាប់ភ្លឹកពីដំណើរគេចខ្លួនរបស់ព្រះអង្គ រវល់តែស្រូស្រមកស្រោចព្រះគន្ធវារីលើខ្លួនប្រាណរបស់ព្រះអគ្គមហេសី រឹតរួតគក់ប្រហប់ទួតដៃជើង ញ៉ាំងព្រះនាងឲ្យមានស្មារតីឡើងវិញ ។ ព្រះនាងភ្ញាក់ដឹងស្មារតីឡើង ក៏លាន់ព្រះឱស្ឋសួរថា ៖

"ឯណាព្រះស្វាមីខ្ញុំ អស់លោក !" ។

មនុស្សទាំងឡាយក្រាបទូលថា ៖

"ក្រែងព្រះនាងម្ចាស់ជ្រាបហើយតើ" ។

ព្រះនាងមានព្រះសវនីយ៍ថា ៖

"សូមរកព្រះអង្គមើលក្រែងឃើញណា អស់លោក" ។

អស់អាមាត្យ នាម៉ឺនសព្វមុខមន្ត្រី ស្ទុះរត់ឆ្វេឆ្វារកមើលសព្វទិសទី ក៏រកព្រះមហាសត្តពុំឃើញ ។

## សីវលីទេវីសាងចេតិយអនុស្សាវរីយ៍

សីវលីទេវីទ្រង់ព្រះកន្សែងខ្សឹកខ្សួលអួលណែនឱរាយ៉ាងខ្លាំង បានចាត់ឲ្យជាងធ្វើចេតិយអនុស្សាវរីយ៍ ក្នុងកន្លែងស្ដេចឈរ លុះបូជា

---

[១៧៧] (ន.) (សំ.),(បា.) (ទ្រុម; ទុម "ឈើ, ដើមឈើ") ដើមឈើ, គុម្ពោត, ព្រៃដែលមានវល្លិរួបរឹតទ្រុបទ្រុលសុបប្រឡប : ពួនក្នុងស៊ុមទ្រុម (ស. ប្រើជា សុមទុម) ។ ប្រើជា គុ. ក៏បាន : ឈើស៊ុមទ្រុម, គុម្ពោតស៊ុមទ្រុម, ព្រៃស៊ុមទ្រុម ។

ដោយគ្រឿងក្រអូបនិងផ្កាកម្រងជាដើមហើយ ព្រះនាងត្រឡប់វិញ ។ ចំណែកព្រះមហាសត្ត កាត់ព្រះទ័យពីស្នេហា ឈ្មុសឈ្មុលចូលព្រៃហិមពាន្ត ចម្រើនឈាន សម្រេចនូវអភិញ្ញា ៥ និងសមាបត្តិ ៨ ក្នុងរវាង ៧ ថ្ងៃ ហើយទ្រង់លែងមកបង្ហាញព្រះកាយឲ្យមនុស្សឃើញទៀតហើយ ។ ចំណែកឯសីវលីទេវីអគ្គមហេសី បានសាងព្រះចេតិយអនុស្សាវរីយ៍ ជាទីនឹករលឹក ទុកជាច្រើនកន្លែង មានដូចជា ៖

១- កន្លែងស្ដេចទ្រង់ត្រាស់នឹងជាងព្រួញ

២- កន្លែងស្ដេចទ្រង់ត្រាស់នឹងកុមារិកា

៣- កន្លែងស្ដេចទ្រង់សោយដុំសាច់សំណល់

៤- កន្លែងស្ដេចទ្រង់ត្រាស់នឹងមិគាជិនតាបស

៥- កន្លែងស្ដេចទ្រង់ត្រាស់នឹងនារទតាបស

ក្រោយពេលធ្វើពិធីបុណ្យបូជា ដោយគ្រឿងក្រអូបនិងផ្កាកម្រងជាដើមរួចរាល់ហើយ ព្រះនាងព្រមទាំងទាហានដើរហែហម ជាបរិវារ បានធ្វើដំណើរវិលមកដល់ក្រុងមិថិលា រៀបចំកម្មវិធីអភិសេករាជបុត្រ**ទីឃាវុ** ឡើងគ្រប់គ្រងរាជាណាចក្រស្នងព្រះវររាជបិតា រួចជាស្រេចហើយ ព្រះនាងបញ្ជូនរាជបុត្រឲ្យទៅនគរ ដែលមានអង្គសេនាហែហមអមដំណើរទៅជាមួយ ហើយខ្លួនព្រះនាងផ្ទាល់ សព្វព្រះរាជហឫទ័យសាងផ្នួសជាតាបសិនីនៅក្នុងឧទ្យាននោះតែម្ដង ចម្រើនបរិកម្មកសិណ

ញ៉ាំងឈានឲ្យកើតឡើង ហើយបានទៅកើតក្នុងព្រហ្មលោក ក្រោយអស់ព្រះជន្មាយុសង្ខារ ។

រីឯព្រះមហាសត្តមានឈានមិនសាបសូន្យ ក្រោយពេលអស់ព្រះជន្មសង្ខារ បានទៅកើតនៅឯព្រហ្មលោកដែរ ។

## ព្រះសាស្តាប្រជុំជាតក

ក្រោយពេលនាំធម្មទេសនានេះមកបរិយាយហើយ ព្រះសាស្តាបរមគ្រូនៃយើង ទ្រង់បញ្ជាក់ថា ៖

"ម្នាលភិក្ខុទាំងឡាយ មិនមែនទើបតែឥឡូវនេះទេ សូម្បីពីអតីតជាតិ ក៏តថាគតធ្លាប់យាងចេញសាងមហាភិនេស្រ្កមណ៍ដែរ" ។

បន្ទាប់មក ព្រះអង្គក៏ប្រជុំជាតកថា ៖

"តទា សមុទ្ទរក្ខិកា ទេវធីតា ឧប្បលវណ្ណា អហោសិ,
នារទោ សារិបុត្តោ, មិគាជិនោ មោគ្គល្លានោ,
កុមារិកា ខេមា ភិក្ខុនី, ឧសុការោ អានន្ទោ,
សីវលិទេវី រាហុលមាតា, ទីឃាវុកុមារោ រាហុលោ,
មាតាបិតរោ មហារាជកុលានិ,
មហាជនកនរិន្ទោ បន អហមេវ សម្មាសម្ពុទ្ធោ អហោសិំ"។

-ទេពធីតារក្សាមហាសមុទ្រ បានមកជាឧប្បលវណ្ណាថេរី

-នារទតាបស បានមកជាសារីបុត្រ

-មិគាជិនតាបស បានមកជាមោគ្គល្លាន

-កុមារិកា បានមកជាខេមាភិក្ខុនី

-ជាងព្រួញ បានមកជាអានន្ទ

-សីវលីទេវី បានមកជារាហុលមាតា

-ទីឃាវុកុមារ បានមកជារាហុល

-ព្រះមាតាបិតា បានមកជារាជមហាត្រកូល,

-ព្រះនរិន្ទមហាជនក ជាអង្គអញអរហន្តសម្មាសម្ពុទ្ធនេះឯង ។

មហាជនកជាតកពិស្តារ ចប់តែប៉ុណ្ណេះ ។



នាម៉ឺនសព្វមុខមន្ត្រីក្រាបទូល ស្នើសុំមហាជនក
ឱ្យឡើងគ្រងរាជនៅក្រុងមិថិលា ដែនវិទេហរដ្ឋ ។

ISBN 9789995094669

PUC Press